Woori Financial Group, Korea

WOORI BANK

# របាយការណ៍ប្រចាំឆ្នាំ2023

ធនាគារ អ៊ូរី ជម្រើសហិរញ្ញវត្ថុដ៏ឆ្លាតវៃរបស់អ្នក!

# មាតិកា


## I
## អំពីស្ថាប័ន

យើងជានរណា? ........ 8
សារពីប្រធានក្រុមប្រឹក្សាភិបាល ........ 10
សារពីអគ្គនាយកប្រតិបត្តិ ........ 12
ព្រឹត្តិការណ៍សំខាន់ប្រចាំឆ្នាំ ........ 14
អំពីធនាគារអ៊ូរី ........ 16

## II
## អភិបាលកិច្ចសាជីវកម្ម

រចនាសម្ព័ន្ធរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ........ 20
អំពីក្រុមប្រឹក្សាភិបាល ........ 22
អំពីគណៈគ្រប់គ្រងជាន់ខ្ពស់ ........ 26

## III
## សមិទ្ធផលសម្រេចបាន

ការរចនានិងបន្ថែមមុខងារថ្មីលើសេវាកម្មធនាគារចល័ត ........ 34
ដៃគូអាជីវកម្មឌីជីថលថ្មី ........ 36
ពាណិជ្ជករដៃគូសហការថ្មី ........ 38
ការបើកដំណើរការសាខាព្រៃមៀមថ្មី ........ 39
ការដាក់ដំណើរការផលិតផល និងសេវាកម្មថ្មីៗ ........ 39

## IV
## ចំនុចសំខាន់ៗអំពីអាជីវកម្ម 2023

ទិន្នន័យហិរញ្ញវត្ថុសំខាន់ៗ ........ 42
របាយការណ៍អភិវឌ្ឍន៍ធនធានមនុស្ស ........ 46
សក្ខីកម្មរបស់បុគ្គលិក ........ 47
ព័ត៌មានសំខាន់ៗ ........ 50
អំពីភាពជោគជ័យរបស់អតិថិជន ........ 56
អំពីផលិតផល និងសេវាកម្ម ........ 58
របាយការណ៍ស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម ........ 78
បណ្តាញសាខា និងតំបន់ប្រតិបត្តិការ ........ 80

## V
## របាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ........ 84
របាយការណ៍ចំណេញ ឬ ខាត និងលទ្ធផលលម្អិតផ្សេងៗ ........ 85
របាយការណ៍បម្រែបម្រួលមូលធន ........ 86
របាយការណ៍លំហូរសាច់ប្រាក់ ........ 87
របាយការណ៍របស់សវនករឯករាជ្យ ........ 88
របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ........ 91

# ធនាគារ អ៊ូរី
# ជម្រើសហិរញ្ញវត្ថុដ៏ឆ្លាតវៃរបស់អ្នក!

**ធនាគារ អ៊ូរី (ខេមបូឌា) ម.ក** គឺជាធនាគារពាណិជ្ជដែលមានការរីកចម្រើនលឿនបំផុតមួយនៅកម្ពុជាដែលមានបទពិសោធន៍ក្នុងការផ្តល់សេវាកម្មហិរញ្ញវត្ថុដល់ប្រជាជនកម្ពុជាប្រកបដោយវិជ្ជាជីវៈខ្ពស់ និងបានពង្រីកបណ្តាញប្រតិបត្តិការរហូតដល់ 140សាខាទូទាំងប្រទេស ព្រមទាំងបណ្តាញ ATM/Self-banking រហូតដល់ជាង 100 ម៉ាស៊ីន ។

# អំពីស្ថាប័ន

យើងជានរណា?........8
សារពីប្រធានក្រុមប្រឹក្សាភិបាល........10
សារពីអគ្គនាយកប្រតិបត្តិ........12
ព្រឹត្តិការណ៍សំខាន់ប្រចាំឆ្នាំ........14
អំពីធនាគារអ៊ូរី........16

# យើងជានរណា?

**ធនាគារ អ៊ូរី (ខេមបូឌា) ម.ក** ជាធនាគារពាណិជ្ជដែលឈានមុខមួយក្នុងចំណោមធនាគារក្នុងប្រទេសកម្ពុជា ហើយក៏ជាសមាជិកគ្រួសាររបស់ធនាគារពាណិជ្ជ អ៊ូរី ដែលជាធនាគារឈានមុខមួយនៅប្រទេសកូរ៉េដែលត្រូវបានបង្កើតឡើងនៅឆ្នាំ1899 មកម្លេះ។

**ធនាគារ អ៊ូរី (ខេមបូឌា) ម.ក** បានប្ដេជ្ញាធ្វើឱ្យជីវិតអតិថិជន កាន់តែប្រសើរ តាមរយៈដំណោះស្រាយហិរញ្ញវត្ថុងាយៗ និងវៃឆ្លាតដោយភ្ជាប់ជាមួយបច្ចេកវិទ្យាទាន់សម័យ ជាមួយការផ្តល់ជូននូវផលិតផល និងសេវាដែលឆ្លើយតបនឹងតម្រូវការអតិថិជនគោលដៅរបស់យើង។

## នាខែវិច្ឆិកា ឆ្នាំ2021 ធនាគារអ៊ូរី (ខេមបូឌា) ម.ក បានទទួលអាជ្ញាបណ្ណជាធនាគារពាណិជ្ជពីធនាគារជាតិនៃកម្ពុជា និងបានដាក់ដំណើរការជាផ្លូវការជាធនាគារពាណិជ្ជចាប់ពីខែមករា ឆ្នាំ 2022។

យើងកំពុងតែជំរុញឱ្យមានកំណើនលូតលាស់ ជួយបង្កើតការងារ អភិវឌ្ឍន៍សហគមន៏ ជំរុញការបម្លាស់ប្តូរសេដ្ឋកិច្ច និងដំណោះស្រាយបញ្ហាប្រឈមមុខធំៗនៅក្នុងសង្គមជាមួយនឹងការបន្តការគ្រប់គ្រងហានិភ័យ និងការសងត្រឡប់ទៅវិញជូនអតិថិជន និងម្ចាស់ភាគទុនិករបស់យើង។ យើងជឿជាក់ថា យើងអាចទទួលបានជោគជ័យនៅពេលដែលអតិថិជនម្នាក់ៗ ក្រុមហ៊ុននានា សហគមន៏ និងបុគ្គលិកដែលយើងបានបម្រើសេវាកម្មជូនអាចឈានដល់ភាព ជោគជ័យរបស់ពួកគេ។

**គិតត្រឹមខែ ធ្នូ ឆ្នាំ 2023 ធនាគារអ៊ូរី (ខេមបូឌា) ម.ក បានពង្រីកបណ្តាញប្រតិបត្តិការរបស់ខ្លួនដល់ 140 សាខាទូទាំងប្រទេស ព្រមទាំងបណ្តាញ ATM/Self-banking រហូតដល់ជាង 100 ម៉ាស៊ីន ។**

# ទស្សនៈវិស័យ បេសកកម្ម និង គុណតម្លៃ

## ទស្សនៈវិស័យរបស់យើង៖

**ច្នៃប្រឌិតថ្ងៃនេះ បង្កើតថ្ងៃស្អែក**

## បេសកកម្មរបស់យើង៖

**ចូលរួមចំណែកដល់សេដ្ឋកិច្ចកម្ពុជាតាមរយៈការផ្តល់នូវសេវាហិរញ្ញវត្ថុដ៏ប្រសើរសម្រាប់ អតិថិជនរបស់យើង**

## គុណតម្លៃរបស់យើង៖

**អតិថិជន៖** ធនាគារ អ៊ូរី តែងតែគិតដល់អតិថិជន និងសហគមន៍ជាចម្បង

**ទំនុកចិត្ត៖** ធនាគារ អ៊ូរី កសាងទំនុកចិត្តជាមួយគោលការណ៍ដ៏រឹងមាំ

**ជំនាញ៖** អ៊ូរីហ្វាយនែនស្យលគ្រុបជាស្ថាប័នឯកទេសដឹកនាំទីផ្សារឈានមុខគេ

**ការច្នៃប្រឌិត៖** ធនាគារ អ៊ូរី កសាងអនាគតរីកចម្រើនតាមរយៈភាពច្នៃប្រឌិត

# សារពី
# ប្រធានក្រុមប្រឹក្សាភិបាល

**លោក ជុង សុងវូក**
ប្រធានក្រុមប្រឹក្សាភិបាល
នៃធនាគារ អ៊ូរី (ខេមបូឌា) ម.ក

**ម្ចាស់ភាគទុនិក និងអ្នកពាក់ព័ន្ធជាទីគោរព!**

ក្នុងការឆ្លុះបញ្ចាំងពីដំណើរកាលពីឆ្នាំមុន ខ្ញុំមានកិត្តិយសក្នុងការថ្លែងការស្វាគមន៍ដ៏កក់ក្ដៅបំផុត និងការដឹងគុណដ៏ស្មោះស្ម័គ្រចំពោះអ្នកទាំងអស់គ្នា។ ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាលនៃ ធនាគារ អ៊ូរី ខ្ញុំមានឯកសិទ្ធិបង្ហាញរបាយការណ៍ប្រចាំឆ្នាំ2023 ដែលជាសក្ខីភាពមួយចំពោះកិច្ចខិតខំប្រឹងប្រែងរួមរបស់យើង ភាពធន់នឹងការប្រឈមមុខនឹងការលំបាក និងការប្ដេជ្ញាចិត្តដែលមិនផ្លាស់ប្ដូរដើម្បីវឌ្ឍនភាព។

ឆ្នាំមុនត្រូវបានឆ្លងកាត់ដោយបញ្ហាប្រឈមដែលមិនធ្លាប់មានពីមុនមក ការសាកល្បងភាពធន់នៃអាជីវកម្ម និងសហគមន៍ទូទាំងពិភពលោក។ ប្រឈមមុខនឹងការលំបាកទាំងនេះ ធនាគារ អ៊ូរី ប្រកាន់យ៉ាងខ្ជាប់ខ្ជួនក្នុងការប្ដេជ្ញាចិត្តក្នុងការផ្ដល់នូវតម្លៃ ការគាំទ្ររបស់អតិថិជន និងរួមចំណែកជាវិជ្ជមានដល់សង្គមរបស់យើង។

ភាពជោគជ័យរបស់យើងគឺចាក់ឫសយ៉ាងជ្រៅនៅក្នុងការខិតខំប្រឹងប្រែង និងកាប្ដេជ្ញារបស់ក្រុមការងារដែលមានទេពកោសល្យរបស់យើង។ ចំណង់ចំណូលចិត្ត ជំនាញ និងការស្វែងរកឧត្តមភាពដោយមិនឈប់ឈររបស់ពួកគេ គឺជាកម្លាំងចលករនៅពីក្រោយសមិទ្ធផលរបស់យើង។ យើងបានទទួលយកការច្នៃប្រឌិត សម្របខ្លួនយ៉ាងឆាប់រហ័សទៅនឹងការផ្លាស់ប្ដូរ និងបន្តលើកកម្ពស់ស្តង់ដារសេវាកម្មធនាគារនៅកម្ពុជាឱ្យកាន់តែប្រសើរ។

ធនាគារ អ៊ូរី ទទួលស្គាល់សារៈសំខាន់នៃភាពជាសាជីវកម្មដែលមានការទទួលខុសត្រូវចំពោះសង្គមជាតិ។ យើងនៅតែប្ដេជ្ញាចិត្តក្នុងការធ្វើអាជីវកម្មរបស់យើងប្រកបដោយក្រមសីលធម៌ តម្លាភាព និងសុចរិតភាព ដោយធានាថាសកម្មភាពរបស់យើងរួមចំណែកដល់សុខុមាលភាពយូរអង្វែងរបស់អ្នកពាក់ព័ន្ធ និងសហគមន៍ផងដែរ ។

ជាទស្សនវិស័យទៅថ្ងៃខាងមុខ យើងមានសុទិដ្ឋិនិយមចំពោះឱកាសនៃការរីកចម្រើន។ ជាមួយនឹងចក្ខុវិស័យយុទ្ធសាស្ត្រច្បាស់លាស់ មូលដ្ឋានគ្រឹះដ៏រឹងមាំ និងក្រុមការងារប្រកបដោយថាមពល យើងមានភាពជឿជាក់ក្នុងការប្រឈមនឹងភាពស្មុគស្មាញនៃវិស័យធនាគារដែលកំពុងវិវឌ្ឍន៍ និងចាប់យកមធ្យោបាយថ្មីៗសម្រាប់ការរីកចម្រើន។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះម្ចាស់ភាគទុនិក អតិថិជន បុគ្គលិក និងដៃគូសហការរបស់យើងចំពោះការគាំទ្រ ការជឿទុកចិត្ត និងការសហការដែលមិនផ្លាស់ប្ដូររបស់ពួកគេ។ ទាំងនេះអនុញ្ញាតឱ្យយើងបន្តការច្នៃប្រឌិត បំផុសគំនិត និងបង្កើតគុណតម្លៃដូចដែលយើងធ្វើការឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាងសម្រាប់ ធនាគារ អ៊ូរី និងអ្នកពាក់ព័ន្ធទាំងអស់។

សូមអរគុណ
ដោយក្ដីគោរព,

**លោក ជុង សុងវូក**
ប្រធានក្រុមប្រឹក្សាភិបាល
នៃធនាគារ អ៊ូរី (ខេមបូឌា) ម.ក

# សារពី
# អគ្គនាយកប្រតិបត្តិ

**លោក គីម ហុងជូ**
អគ្គនាយកប្រតិបត្តិ នៃធនាគារ អ៊ូរី (ខេមបូឌា) ម.ក

គិតត្រឹមខែធ្នូ ឆ្នាំ2023
**ធនាគារអ៊ូរី (ខេមបូឌា) ម.ក មាន៖**

**1,462** លានដុល្លារអាមេរិក
ចំនួនទ្រព្យសកម្មសរុប (កំណើន 1.4%)

**444** លានដុល្លារអាមេរិក
ចំនួនប្រាក់បញ្ញើសរុប (កំណើន 26%)

**1,216** លានដុល្លារអាមេរិក
ចំនួនឥណទានសរុប (កំណើន 2.8%)

បានពង្រីកបណ្ដាញប្រតិបត្តិការរបស់ខ្លួនដល់ 140 សាខាទូទាំងប្រទេស ព្រមទាំងបណ្ដាញ ATM/Self-banking រហូតដល់ជាង 100 ម៉ាស៊ីន

**ម្ចាស់ភាគទុនិក អតិថិជន និងអ្នកពាក់ព័ន្ធជាទីគោរព!**

ខ្ញុំបាទឈ្មោះ **គីម ហុងជូ** អគ្គនាយកប្រតិបត្តិនៃ ធនាគារ អ៊ូរី។ ខ្ញុំមានសេចក្តីសោមនស្សរីករាយក្នុងការបង្ហាញជូនលោកអ្នកអ្នកនូវរបាយការណ៍ប្រចាំឆ្នាំ 2023 សមិទ្ធផល បញ្ហាប្រឈម និងចក្ខុវិស័យនាពេល អនាគតរបស់យើង។

ឆ្នាំ 2023 គឺជាឆ្នាំដ៏លំបាក សម្រាប់ធនាគារ អ៊ូរី ដោយសារយើងប្រឈមមុខនឹងផលប៉ះពាល់នៃ ជំងឺរាតត្បាត និងការផ្លាស់ប្តូរលក្ខខណ្ឌទីផ្សារ ប៉ុន្តែជាឆ្នាំដែលសម្រេចបាននូវសមិទ្ធផលជាច្រើនផងដែរ។ ទោះបីជាមានការលំបាកក៏ដោយ ពួកយើងអាចយកឈ្នះលើវិបត្តិនេះ ហើយសម្រេចបាននូវការរីកចម្រើន និងការបង្កើតសមិទ្ធផលថ្មីៗគួរឱ្យកត់សម្គាល់។ ធនាគារសម្រេចបានសំពៀតឥណទានចំនួន 1,216 លានដុល្លារ ប្រាក់បញ្ញើសន្សំចំនួន 444 លានដុល្លារ និងអតិថិជនជិត 455 ពាន់នាក់។ យើងបានដាក់សម្ពោធផលិតផល និងសេវាកម្មថ្មីៗ ដូចជា ប័ណ្ណឥណពន្ធវីសា ប័ណ្ណឥណទានវីសា ផលិតផលសន្សំ និងកម្ចីថ្មីដើម្បីបំពេញតម្រូវការអតិថិជនរបស់យើង។ យើងក៏បានពង្រីកបណ្តាញសាខារបស់យើងទៅកាន់ 140សាខា បណ្តាញ ATM ជាង 100 ម៉ាស៊ីន នៅទូទាំងប្រទេស និងបានបង្កើនបុគ្គលិករបស់យើងដល់ជាង 4,000 នាក់។

ធនាគារ ធនាគារ អ៊ូរី មានការយល់ឃើញយ៉ាងច្បាស់ថាសមិទ្ធផលរបស់យើងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងសុខុមាលភាពរបស់សហគមន៍។ ដូច្នេះហើយ យើងនៅតែខិតខំប្រឹងប្រែងក្នុងការវិនិយោគលើគម្រោងផ្សេងៗប្រកបដោយអត្ថន័យ រាប់បញ្ចូលទាំងការពង្រីកកិច្ចខិតខំប្រឹងប្រែងរបស់យើងក្នុងបរិយាប័ន្នហិរញ្ញវត្ថុ ការធានាថាសេវាកម្មធនាគារអាចប្រើប្រាស់បានសម្រាប់ក្រុមដែលមិនទាន់ទទួលបានសេវាកម្មហិរញ្ញវត្ថុ និងការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ការសម្រេចចិត្ត។ យើងក៏ផ្តល់អាទិភាពដល់ការជួយដល់អាជីវកម្មខ្នាតតូចដោយការផ្តល់ជូននូវដំណោះស្រាយហិរញ្ញវត្ថុដែលសមស្រប ដោយទទួលស្គាល់នូវសារៈសំខាន់របស់ពួកគេនៅក្នុងវិបុលភាពសេដ្ឋកិច្ចរបស់កម្ពុជា។ លើសពីនេះ ការប្តេជ្ញាចិត្តរបស់យើងចំពោះការអភិវឌ្ឍន៍ប្រកបដោយចីរភាព ដោយពង្រីកលើសពីប្រាក់ចំណេញ ដូចជាការគាំទ្ររបស់យើងក្នុងការបង្កើតមណ្ឌលថែទាំសុខភាពក្នុងខេត្តកំពង់ធំ ការផ្តល់អាហារូបករណ៍ដល់និស្សិតចំនួន 100 នាក់នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ការគាំទ្រក្នុងគម្រោង REDD+ របស់រដ្ឋបាលព្រៃឈើ ដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ សហការជាមួយឆាលហ្វាន់កម្ពុជា ដើម្បីបង្កើនចំណេះដឹងផ្នែកឌីជីថលក្នុងការអប់រំ និងសុខុមាលភាពបុគ្គលិក និងការផ្តល់កម្មវិធីបណ្តុះបណ្តាលពន្លកថ្មីជាដើម។

នៅពេលយើងក្រឡេកមើលទៅអនាគត ឌីជីថលភារូបនីយកម្មគឺចំណុចកណ្តាលដែលត្រូវយកចិត្តទុកដាក់ បច្ចេកវិទ្យាមិនគ្រាន់តែជាវាក្យសព្ទប៉ុណ្ណោះទេ វាជាត្រីវិស័យរបស់យើង។ យើងកំពុងវិនិយោគលើដំណោះស្រាយទំនើបៗ ដើម្បីបង្កើនផលិតផលរបស់យើង សម្រួលដំណើរការ និងបង្កើនបទពិសោធន៍អតិថិជន មិនថាសេវាធនាគារចល័ត ឬ ការទូទាត់ដោយរហ័ស ឬសេវាកម្មផ្ទាល់ខ្លួនទេ ពួកយើងប្តេជ្ញាបន្តឆ្ពោះទៅមុខជានិច្ច។

ខ្ញុំសូមបង្ហាញការដឹងគុណដោយស្មោះចំពោះម្ចាស់ភាគទុនិក អតិថិជន និងអ្នកពាក់ព័ន្ធរបស់យើង ចំពោះ ការជឿទុកចិត្ត ការគាំទ្រ និងកិច្ចសហការ របស់អ្នក ដែលជាកម្លាំងចលករដ៏សំខាន់នៅពីក្រោយវឌ្ឍនភាពរបស់យើង។ យើងនឹងរួមគ្នាបន្តកសាងសមិទ្ធផលថ្មីៗ ដោះស្រាយបញ្ហាប្រឈម និងបង្កើតអនាគតដ៏ជោគជ័យ មួយជំហានម្តងៗ តាមរយៈប្រតិបត្តិការ និងការច្នៃប្រឌិតរបស់យើង ។

សូមអរគុណ
ដោយក្តីគោរព,



**លោក គីម ហុងជូ**
អគ្គនាយកប្រតិបត្តិ នៃធនាគារ អ៊ូរី (ខេមបូឌា) ម.ក

# ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ

**1990s**

ត្រូវបានបង្កើតឡើងជាសកម្មភាពមួយរបស់កម្មវិធីកម្មវិធីអភិវឌ្ឍតំបន់របស់អង្គការទស្សនៈពិភពលោកកម្ពុជា

**2000**

ត្រូវបានដាក់ឈ្មោះថាកម្មវិធីអភិវឌ្ឍន៍សហគ្រាសខ្នាតតូច ដែលជាកម្មវិធីឥណទានមួយរបស់អង្គការទស្សនៈពិភពលោកកម្ពុជា

**2003**

បានក្លាយជាក្រុមហ៊ុនមួយបានចុះបញ្ជីដោយមានឈ្មោះថា វីសិនហ្វាន់ (ខេមបូឌា) អិលធីឌី នៅក្រសួងពាណិជ្ជកម្ម

**2004**

បានទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជាដោយមានឈ្មោះថា វីសិនហ្វាន់ (ខេមបូឌា) អិលធីឌី

**2011**

បានទទួលអាជ្ញាបណ្ណប្រកបអាជីវកម្មទទួលប្រាក់បញ្ញើពីធនាគារជាតិនៃកម្ពុជា

**2014**

ធនាគារ អ៊ូរី បានចូលក្នុងទីផ្សារប្រទេសកម្ពុជា និងទិញយកម្ជិះ ហ្វាយនែន ភីអិលស៊ី និងប្តូរឈ្មោះទៅជា អ៊ូរី ហ្វាយនែន ខេមបូឌា ភីអិលស៊ី

**2016**

- ការសម្ពោធជាផ្លូវការអគារការិយាល័យកណ្តាលថ្មី
- ទទួលបានការស្គាល់ថាជាស្ថាប័នបានគោរពតាមគោលការណ៍ការពារអតិថិជនយ៉ាងខ្ជាប់ខ្ជួន និង ត្រូវតាមស្តង់ដាអន្តរជាតិពី Smart Campaign

**2017**

- ទទួលបានវិញ្ញាបនប័ត្រអនុលោមភាពសារពើពន្ធប្រភេទមាស ពីអគ្គនាយកដ្ឋានពន្ធដារ នៃព្រះរាជាណាចក្រកម្ពុជា
- ជាសមាជិកស្ថាបនិកនៃគម្រោងសេវាផ្ទេរមូលនិធិភ្លាមៗរបស់ធនាគារជាតិនៃកម្ពុជា

**2018**

- ផ្លាស់ប្តូរម្ចាស់ភាគហ៊ុន (មិថុនា 2018) ទៅជាធនាគារ អ៊ូរី នៃប្រទេសកូរ៉េខាងត្បូង
- ប្តូរឈ្មោះទៅជា ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក

**2019**

បានទទួលការអនុម័តជាគោលការណ៍ពីធនាគារជាតិនៃកម្ពុជា លើសំណើសុំរួមបញ្ចូលគ្នាជាមួយនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អ៊ូរី ហ្វាយនែន ខេមបូឌា ភីអិលស៊ី

**2020**

- ខែកុម្ភៈ ឆ្នាំ2020 ដំណើរការរួមបញ្ចូលគ្នាដោយជោគជ័យរវាងគ្រឹះស្ថាន ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក និងគ្រឹះស្ថាន អ៊ូរី ហ្វាយនែន (ខេមបូឌា) ភីអិលស៊ី
- ខែធ្នូ ឆ្នាំ2020 បញ្ចូលលដើមទុន 100 លានដុល្លារអាមេរិក បន្ថែមពីម្ចាស់ភាគហ៊ុន ធនាគារអ៊ូរី

**2021**

ខែវិច្ឆិកា ឆ្នាំ2021 ទទួលបានអាជ្ញាប័ណ្ណជាធនាគារពាណិជ្ជពីធនាគារជាតិនៃកម្ពុជា និងខែធ្នូ ឆ្នាំ2021 ទទួលបានសិទ្ធិក្នុងការក្លាយខ្លួនទៅជាធនាគារពាណិជ្ជ ហើយផ្លាស់ប្តូរឈ្មោះទៅជាធនាគារអ៊ូរី (ខេមបូឌា) ម.ក

**2022**

- បានសម្ពោធសេវាធនាគារពាណិជ្ជជាផ្លូវការនៅថ្ងៃទី 03 ខែមករា ឆ្នាំ2022
- បានពង្រីកបណ្តាញប្រតិបត្តិការរបស់ខ្លួនដល់ 138 សាខាទូទាំងប្រទេស

**2023**

គិតត្រឹមខែធ្នូ ឆ្នាំ2023

**ធនាគារអ៊ូរី (ខេមបូឌា) ម.ក មាន៖**

- 1,462 លានដុល្លារអាមេរិក
  ចំនួនទ្រព្យសកម្មសរុប (កំណើន 1.4%)
- 444 លានដុល្លារអាមេរិក
  ចំនួនប្រាក់បញ្ញើសរុប (កំណើន 26%)
- 1,216 លានដុល្លារអាមេរិក
  ចំនួនឥណទានសរុប (កំណើន 2.8%)
- បានពង្រីកបណ្តាញប្រតិបត្តិការរបស់ខ្លួនដល់ 140 សាខាទូទាំងប្រទេស ព្រមទាំងបណ្តាញ ATM/Self-banking រហូតដល់ជាង 100 ម៉ាស៊ីន

# អំពី ធនាគារ អ៊ូរី

**ធនាគារ អ៊ូរី** គឺជាម្ចាស់ភាគទុនិករបស់ ធនាគារអ៊ូរី (ខេមបូឌា) ម.ក ជាធនាគារអន្តរជាតិកូរ៉េដែលមានទីស្នាក់ការកណ្តាលនៅទីក្រុង សេអ៊ូល ប្រទេសកូរ៉េខាងត្បូង ត្រូវបានបង្កើតឡើងក្នុងឆ្នាំ1899 ហើយជាធនាគារពាណិជ្ជឈានមុខមួយនៅប្រទេសកូរ៉េដែលមានបណ្តាញអន្តរជាតិដ៏ធំទូលាយនៅទូទាំងពិភពលោក ផ្តល់ជូននូវការវិនិយោគលើវិស័យពាណិជ្ជកម្ម និងវិស័យធនាគារយ៉ាងទូលំទូលាយតាមរយៈបណ្តាញប្រតិបត្តិការអន្តរជាតិចំនួន 469 សាខា ដែលស្ថិតនៅក្នុង 24 ប្រទេសទូទាំងពិភពលោក ។

**469**
បណ្តាញប្រតិបត្តិការសកល

**24**
ប្រទេស

**124 Years**
**ANNIVERSARY OF WOORI BANK**

ឆ្នាំ 2023 គឺជាឆ្នាំទី124 របស់ធនាគារ អ៊ូរី រក្សាបាននូវប្រវត្តិសាស្រ្តកន្លងមកជាង100ឆ្នាំ។ ធនាគារមានបំណងបន្តរីកលូតលាស់សម្រាប់មួយសតវត្សបន្តទៅមុខទៀត ដើម្បីក្លាយជាម៉ាកយីហោហិរញ្ញវត្ថុដែលតែងតែនៅទីនេះសម្រាប់លោកអ្នក។



II

# អភិបាលកិច្ច សាជីវកម្ម


រចនាសម្ព័ន្ធរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ...................... 20

អំពីក្រុមប្រឹក្សាភិបាល ............................................................22

អំពីគណៈគ្រប់គ្រងជាន់ខ្ពស់ .................................................. 26

# រចនាសម្ព័ន្ធរបស់
# ធនាគារ អ៊ូរី (ខេមបូឌា) ម.ក



# អំពី ក្រុមប្រឹក្សាភិបាល

## លោក ជុង សុងវូក

ប្រធានក្រុមប្រឹក្សាភិបាល

**លោក ជុង** ទទួលបានបរិញ្ញាបត្រផ្នែកអក្សរសាស្ត្រអង់គ្លេស នៅសាកលវិទ្យាល័យកូរ៉េ និង បរិញ្ញាបត្រជាន់ខ្ពស់ផ្នែក ធុរកិច្ចពាណិជ្ជកម្មនៅសាកលវិទ្យាល័យឌូក។

លោកបានចាប់ផ្តើមអាជីពការងារនៅធនាគារ អ៊ូរី ប្រមាណជា20ឆ្នាំមកហើយ ចាប់តាំងពីឆ្នាំ1997។ ជាដំបូងបង្អស់ លោកបានបំពេញការងារនៅការិយាល័យសាខាដែលធ្វើឱ្យលោកទទួលបាននូវចំណេះ និង ជំនាញល្អៗជាច្រើន ក្នុងការចាប់យកតួនាទីថ្មីជាប្រធានផ្នែករតនាគារ បន្ទាប់មកក្លាយជាប្រធានផ្នែកគ្រប់គ្រងហានិភ័យជាន់ខ្ពស់។ ចាប់តាំងពីឆ្នាំ2012 គាត់ត្រូវបានតែងតាំងក្នុងតំណែងជាថ្នាក់ដឹកនាំនៅក្នុង នាយកដ្ឋានយុទ្ធសាស្ត្រពាណិជ្ជកម្មសកល បន្ទាប់មកផ្ទេរមកគ្រប់គ្រងសាខាហ្គេប៉ូជុងហ្គាង ហើយបច្ចុប្បន្ននេះលោកកាន់តួនាទីជាប្រធានគ្រប់គ្រងទូទៅនៅក្នុង នាយកដ្ឋានគាំទ្រពាណិជ្ជកម្មសកល។ **លោក ជុង** ត្រូវបានតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាល ចាប់តាំងពី ធនាគារ អ៊ូរី បានបំលែងខ្លួនទៅជាធនាគារពាណិជ្ជ។

## លោក គីម ហុង ជូ

ម្ចាស់ភាគទុនិក សមាជិកក្រុមប្រឹក្សាភិបាល
និងជាអគ្គនាយកប្រតិបត្តិ

**លោក គីម** បានរៀនចប់ជំនាញផ្នែកគ្រប់គ្រងពាណិជ្ជកម្មនៅសាកលវិទ្យាល័យជាតិ សេអ៊ូលនៃប្រទេសកូរ៉េ។ លោកបានចូលរួមបម្រើការងារជាមួយធនាគារ អ៊ូរី និងមាននូវបទពិសោធន៍យ៉ាងច្រើនលើវិស័យធនាគារ និងហិរញ្ញវត្ថុ ជាពិសេសលោកមានឯកទេសពាក់ព័ន្ធនឹងពាណិជ្ជកម្មសកល។ លោកបានធ្វើការនៅនាយកដ្ឋានយុទ្ធសាស្ត្រសកលជាង 8 ឆ្នាំ។ លោកបានចូលរួមចំណែកក្នុងប្រតិបត្តិការទិញលក់ភាគហ៊ុនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុម្ហិះហ្វាយនែន ក្នុងឆ្នាំ 2014 និងក្រោយមកបានរួមបញ្ចូលគ្នាជាមួយនឹងគ្រឹះស្ថាន អ៊ូរី ហ្វាយនែន ខេមបូឌា និង គ្រឹះស្ថាន ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក នៅដើមឆ្នាំ 2020។ លោកក៏ត្រូវបានតែងតាំងជាអគ្គនាយកហិរញ្ញវត្ថុនៃ ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក។ នៅចុងឆ្នាំ 2021 ក្រោយទទួលបានអនុម័តពីធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្ម លោកក៏បានក្លាយជាម្ចាស់ភាគទុនិករបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក (ពីមុនឈ្មោះថា ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក)។

នៅដើមឆ្នាំ2022 លោក គីម ត្រូវបានតែងតាំងជាអគ្គនាយកប្រតិបត្តិថ្មីនៃធនាគារ អ៊ូរី (ខេមបូឌា) ម.ក.។

## លោកស្រី ហ្វីអូណា វ៉ាយត៍

សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ

**លោកស្រី វ៉ាយត៍** ដែលមានសញ្ជាតិណូវែលសេឡង់បានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក (រួមទាំងអតីតវីសិនហ្វាន់ ខេមបូឌា) តាំងពីខែមករាឆ្នាំ2013។ លោកស្រីមានបទពិសោធន៍ 11ឆ្នាំ ទាក់ទងនឹងការរៀបចំបទប្បញ្ញត្តិនៅប្រទេសណូវែលសេឡង់ដែលមុនការងារនេះផងដែរ លោកស្រីមានបទពិសោធន៍ 23ឆ្នាំ លើផ្នែកធនាគារនៅប្រទេសណូវែលសេឡង់ ដែលបូករួមទាំងបទពិសោធន៍12ឆ្នាំ ទាក់ទងនឹងការងារគ្រប់គ្រងហានិភ័យរូបិយប័ណ្ណអន្តរជាតិ។

**លោកស្រី វ៉ាយត៍** បានសិក្សាផ្នែកធុរកិច្ច និងការគ្រប់គ្រងអន្តរជាតិនៅសាកលវិទ្យាល័យ Massey ក្នុងឆ្នាំ2007។ លោកស្រី បច្ចុប្បន្នធ្វើការជាអ្នកប្រឹក្សាផ្នែកទំនាក់ទំនងកិច្ចការខាងក្រៅនៅក្នុងអាជ្ញាធរទីផ្សារហិរញ្ញវត្ថុក្នុងប្រទេសណូវែលសេឡង់ ប្រធានក្រុមប្រឹក្សានិយ័តករហិរញ្ញវត្ថុ ផ្នែកហានិភ័យបម្រែបម្រួលអាកាសធាតុហើយមុននេះបន្តិចលោកស្រីធ្លាប់ធ្វើជាបរិធនបាលទាយករយៈពេលមួយអាណ្ណត្តិជូនក្រុមប្រឹក្សាភិបាលរបស់អង្គការទស្សនៈពិភពលោកណូវែលសេឡង់។

## លោក គី ប៊ុនទ្រាន

សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ

**លោក ប៊ុនទ្រាន** បានចូលរួមជាមួយធនាគារ អ៊ូរី (ខេមបូឌា) ម.ក ក្នុងនាមជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ។ លោកទទួលបានបរិញ្ញាបត្រ័ជាន់ខ្ពស់ ផ្នែកនីតិសាស្ត្រនិងវិទ្យាសាស្ត្រនយោបាយ ព្រមទាំងវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ មុននេះ លោកជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យនៃគ្រឹះស្ថាន អ៊ូរី ហ្វាយនែន ខេមបូឌា ចាប់ពីឆ្នាំ 2018 ដល់ត្រឹមដើមឆ្នាំ 2020។ ក្រៅពីនេះទៀត លោកក៏ជាសមាជិកមួយរូបនៃគណៈមេធាវីព្រះរាជាណាចក្រកម្ពុជា និងជាសាស្ត្រាចារ្យបង្រៀនក្រៅម៉ោងនៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចផងដែរ។

បន្ទាប់ពីការគួបបញ្ចូលគ្នាដោយជោគជ័យរវាងគ្រឹះស្ថាន អ៊ូរី ហ្វាយនែន ខេមបូឌា និង គ្រឹះស្ថាន ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក **លោក គី ប៊ុនទ្រាន** ត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យនៃធនាគារ អ៊ូរី (ខេមបូឌា) ម.ក។

## លោក ឃូ ខ្វាងហ៊ី

សមាជិកក្រុមប្រឹក្សាភិបាល

**លោក ឃូ** បានចូលរួមជាមួយធនាគារ អ៊ូរី (ខេមបូឌា) ម.ក (អតីត ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក) ចាប់តាំងពីឆ្នាំ 2020 ក្រោយការគួបបញ្ចូលគ្នាក្នុងតួនាទីជានាយកគ្រប់គ្រងយុទ្ធសាស្រ្ត ហើយក្រោយមកជាប្រធានអគ្គនាយកដ្ឋានយុទ្ធសាស្រ្តគ្រប់គ្រង។

លោកធ្លាប់កាន់តួនាទីជានាយកសវនកម្មផ្ទៃក្នុង ខណៈលោកកំពុងធ្វើការឱ្យ អ៊ូរី ហ្វាយនែន (ខេមបូឌា) ភីអិលស៊ី។ មុននឹងធ្វើការនៅប្រទេសកម្ពុជា លោកមានបទពិសោធន៍ជាច្រើនប្រមាណជិត16ឆ្នាំ ជាមួយនឹងធនាគារ អ៊ូរី របស់កូរ៉េ ហើយបទពិសោធន៍ដ៏លេចធ្លោរបស់លោកមួយផងដែរនោះ គឺនៅក្នុងវិស័យយុទ្ធសាស្រ្តប្រតិបត្តិការ ទាក់ទងនឹងធនាគារសាជីវកម្ម និងធុរកិច្ចខ្នាតតូចនិងមធ្យម។

លោកទទួលបានសញ្ញាប័ត្រថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ Sungkyunkwan ក្នុងប្រទេសកូរ៉េ។

# អំពី គណៈគ្រប់គ្រងជាន់ខ្ពស់

## លោក គីម ហុង ជូ

ម្ចាស់ភាគទុនិក សមាជិកក្រុមប្រឹក្សាភិបាល
និងជាអគ្គនាយកប្រតិបត្តិ

**លោក គីម** បានបញ្ចប់ការសិក្សាផ្នែកគ្រប់គ្រងពាណិជ្ជកម្មនៅសាកលវិទ្យាល័យជាតិ សេអ៊ូលនៃប្រទេសកូរ៉េ។ លោកបានចូលរួមបម្រើការងារជាមួយធនាគារ អ៊ូរី និងមាននូវបទពិសោធន៍យ៉ាងច្រើនលើ វិស័យធនាគារ និងហិរញ្ញវត្ថុ ជាពិសេសលោកមានឯកទេសពាក់ព័ន្ធនឹងពាណិជ្ជកម្មសកល។ លោកបានធ្វើការនៅនាយកដ្ឋានយុទ្ធសាស្ត្រសកលជាង 8 ឆ្នាំ។ លោកបានចូលរួមចំណែកក្នុងប្រតិបត្តិការទិញលក់ភាគហ៊ុនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុម៉្លិះហ្វាយនែន ក្នុងឆ្នាំ 2014 និងក្រោយមកបានរួមបញ្ចូលគ្នាជាមួយនឹងគ្រឹះស្ថាន អ៊ូរី ហ្វាយនែន ខេមបូឌា និង គ្រឹះស្ថានដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក នៅដើមឆ្នាំ 2020។ បន្ទាប់មកលោកក៏ត្រូវបានតែងតាំងជាអគ្គនាយកហិរញ្ញវត្ថុនៃ គ្រឹះស្ថានដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក។ នៅចុងឆ្នាំ2021 ក្រោយទទួលបានអនុម័តពីធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្ម លោកក៏បានក្លាយជាម្ចាស់ភាគទុនិក របស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក (ពីមុនឈ្មោះថា ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក)។

នៅដើមឆ្នាំ2022 លោក គីម ត្រូវបានតែងតាំងជាអគ្គនាយកប្រតិបត្តិថ្មីនៃធនាគារ អ៊ូរី (ខេមបូឌា) ម.ក.។

## លោក ស៊ីន ដុង វូ

អគ្គនាយកហិរញ្ញវត្ថុ

**លោក ស៊ីន** បានទទួលបរិញ្ញាបត្រផ្នែក វិទ្យាសាស្ត្រសេដ្ឋកិច្ចពីសាកលវិទ្យាល័យ Kyonggi ប្រទេសកូរ៉េខាងត្បូងនៅក្នុងឆ្នាំពីឆ្នាំ 2001។ លោក ស៊ីន មានបទពិសោធន៍ធ្វើការនៅ ធនាគារ អ៊ូរី ប្រទេសកូរ៉េ អស់រយៈពេលជាង 22 ឆ្នាំមកហើយ ហើយមានបទពិសោធន៍ជាច្រើនក្នុងផ្នែកលក់ ប្រតិបត្តិការ ការអភិវឌ្ឍន៍ផលិតផល យុទ្ធសាស្ត្រ និងផែនការ គ្រប់គ្រងហិរញ្ញវត្ថុ និងរតនាគារ ការជួញដូររូបិយប័ណ្ណបរទេស និងការគ្រប់គ្រងមូលនិធិ។

**លោក ស៊ីន** ត្រូវបានតែងតាំងជាអគ្គនាយកហិរញ្ញវត្ថុថ្មីរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក នៅខែកក្កដា ឆ្នាំ 2023។

## លោក សុខ សុថា

អគ្គនាយកប្រតិបត្តិការ ក្រុមធុរកិច្ច 1

**លោក សុថា** បទពិសោធន៍18ឆ្នាំទៅលើវិស័យធនាគារ និងមីក្រូហ្វាយនែន។ លោកបានចូលបម្រើការជាមន្ត្រីឥណទានចាប់តាំងពីឆ្នាំ2005 ហើយបានវិវត្តន៍ខ្លួនជាបន្តបន្ទាប់នៅក្នុងមុខតំណែងសំខាន់ៗជាច្រើនដូចជា ប្រធានសាខា ប្រធានតំបន់ ប្រធានប្រតិបត្តិការ និងអគ្គនាយកផ្នែកប្រតិបត្តការនៃធនាគារ អ៊ូរី (ខេមបូឌា) ម.ក។

លោកបានបញ្ចប់បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្មជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ចនៅឆ្នាំ2004 និងអនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្មជំនាញហិរញ្ញវត្ថុ និងធនាគារ ពីសកលវិទ្យាល័យបៀលប្រាយ។ លោកក៏បានចូលរួមវគ្គសិក្សាជាច្រើនដែលទាក់ទងទៅនឹងការគ្រប់គ្រង និងអភិវឌ្ឍន៍គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា និងវគ្គសិក្សាអន្តរជាតិពី Boulder Institute of Microfinance, Turin ប្រទេសអ៊ីតាលីក្នុងឆ្នាំ 2016។

## លោក ព្រាប ពិសិដ្ឋ

អគ្គនាយកប្រតិបត្តិការ ក្រុមធុរកិច្ច 2

**លោក ពិសិដ្ឋ** មានបទពិសោធន៍ច្រើនជាងមួយទសវត្សរ៍លើវិស័យអភិវឌ្ឍន៍ បម្រើអតិថិជន ការគ្រប់គ្រងកម្មវិធីឧបត្ថម្ភ ទំនាក់ទំនង សាធារណៈ និងរដ្ឋបាល ព្រមទាំង ការគ្រប់គ្រង និងភាពជា អ្នកដឹកនាំ មុនពេលដែលគាត់ចូលខ្លួនប្រលូកក្នុងវិស័យ ហិរញ្ញវត្ថុ។ អាជីពរបស់លោកមានជាមួយធនាគារ អ៊ូរី (ខេមបូឌា) ម.ក គឺចាប់ផ្តើមតាំងពីឆ្នាំ 2008។ កាលពីមុនមកលោកបានបម្រើការងារឱ្យអង្គការទស្សនៈពិភពលោកអន្តរជាតិ (កម្ពុជា) និងលេខាធិការដ្ឋានមុខងារសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា។

លោកទទួលបានសញ្ញាប័ត្រថ្នាក់អនុបណ្ឌិត គ្រប់គ្រងពាណិជ្ជកម្មពីសាកលវិទ្យាល័យ Anglia Ruskin, Global FTMS Campus នៅប្រទេស សិង្ហបុរី ។ លោកក៏មានបរិញ្ញាបត្រ ផ្នែកសេដ្ឋកិច្ច ក្នុងការគ្រប់គ្រងសហគ្រាស និងវិញ្ញាបត្ររងនៃវិជ្ជាជីវៈច្បាប់ មកពីសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅក្នុងប្រទេសកម្ពុជាផងដែរ។

## លោក លី ហ្យូ សក

អគ្គនាយកគាំទ្រប្រតិបត្តិការ

**លោក លី** បានទទួលបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច ពីមហាវិទ្យាល័យនយោបាយ និងសេដ្ឋកិច្ច (ជំនាញសេដ្ឋកិច្ច និងពាណិជ្ជកម្មអន្តរជាតិ) នៅក្នុងសាកលវិទ្យាល័យ ខ្យ៉ុងហ៊ី នៃប្រទេសកូរ៉េក្នុងឆ្នាំ 2004។

នៅក្នុងឆ្នាំ 2006, លោក លី បានចូលបម្រើការងារជាមួយធនាគារ អ៊ូរី (កូរ៉េ)។ គាត់បានបន្តអាជីពការងាររបស់គាត់មួយនេះរហូតមកដល់បច្ចុប្បន្ន ជាមួយនឹងបទពិសោធន៍ជាច្រើនតាមរយៈមុខតំណែងផ្សេងៗ។ គាត់បានចាប់ផ្តើមធ្វើការជាជំនួយការអ្នកគ្រប់គ្រង ទីផ្សារនិងលក់ សម្រាប់នាយកដ្ឋានសាជីវកម្មធនាគារ។ បន្ទាប់ពីការខិតខំប្រឹងប្រែងធ្វើការអស់រយៈពេលជាង16ឆ្នាំជាមួយធនាគារអ៊ូរី (កូរ៉េ) នាពេលបច្ចុប្បន្ននេះគាត់បានកំពុងធ្វើការជា អគ្គនាយកគាំទ្រប្រតិបត្តិការ នៅធនាគារ អ៊ូរី (ខេមបូឌា) ម.ក ចាប់តាំងពីខែសីហា 2022។

## លោក ហ៊ុន សុភ័ក្រ្ត

អគ្គនាយកឥណទាន

**លោក សុភ័ក្រ្ត** មានបទពិសោធន៍រយៈពេល 18ឆ្នាំ ក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ។ បន្ទាប់ពីទទួលបានបទពិសោធន៍4ឆ្នាំក្នុងតួនាទីជានាយករងឥណទានសាជីវកម្ម លោកបានបង្កើតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយដោយជោគជ័យក្រោមឈ្មោះថា ហ្វ្រីន សេនត្រល់ ចាប់តាំងពី ខែមេសា ឆ្នាំ2008 ដល់ ខែវិច្ឆិកា ឆ្នាំ 2010 ហើយលោកគឺជា ស្ថាបនិកនៃគ្រឹះស្ថាន ម្ល៉ិះ ហ្វាយនែន ចាប់ពីខែវិច្ឆិកា ឆ្នាំ 2010 និងបានកម្លាយខ្លួនដោយជោគជ័យជា គ្រឹះស្ថាន អ៊ូរី ហ្វាយនែន ខេមបូឌា ដែលជាផ្នែកមួយនៃធនាគារ អ៊ូរី ប្រទេសកូរ៉េ ជាគ្រឹះស្ថានហិរញ្ញវត្ថុសកល ហើយលោកមានតួនាទីជានាយកគ្រប់គ្រងទូទៅ។

ចាប់តាំងពីមានការរួមបញ្ចូលជាមួយនឹងធនាគារ អ៊ូរី ពីឆ្នាំ2014 លោក សុភ័ក្រ្ត ដើរតួនាទីយ៉ាងសំខាន់ជានាយកគ្រប់គ្រង ទូទៅ និងដឹកនាំប្រតិបត្តិការអាជីវកម្មទាំងមូលកើនឡើងជាលំដាប់ទាំងបរិមាណ និងគុណភាពនៃឥណទានដែលធ្វើឱ្យគ្រឹះស្ថាន អ៊ូ រី ហ្វាយនែន ក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុលេខ1 ចាប់តាំងពីឆ្នាំ 2018 ផ្អែកលើគុណភាពឥណទាន ទ្រព្យសកម្ម និងប្រាក់ចំណេញ។ លោកទទួលបានបរិញ្ញាបត្រផ្នែកគ្រប់គ្រង និងថ្នាក់អនុបណ្ឌិតផ្នែកហិរញ្ញវត្ថុពីសកលវិទ្យាល័យជាតិគ្រប់គ្រងនៅកម្ពុជា ព្រមទាំងបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនដែលទាក់ទងនឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ស្ថាប័នមីក្រូហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា។

## លាក វ៉ា លួង សូរិន

អគ្គនាយកព័ត៌មានវិទ្យា

**លោក សូរិន** បានចូលរួមជាមួយធនាគារ អ៊ូរី (ខេមបូឌា) ម.ក ក្នុងឆ្នាំ 2015។ លោក សូរិនជាអ្នកដឹកនាំផ្នែកយុទ្ធសាស្រ្តព័ត៌មានវិទ្យាជាមួយនឹងបទពិសោធន៍ជាង15ឆ្នាំ លើការគាំទ្រដោយជោគជ័យជាច្រើនខាងបច្ចេកវិទ្យាការអនុវត្តន៍ និងការរួមចំណែកលើកំណើនធុរកិច្ចតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឱ្យមានប្រយោជន៍ ការកាត់បន្ថយការចំណាយប្រតិបត្តិការ ការបង្កើនគុណតម្លៃនៃអាជីវកម្ម និងម្ចាស់ភាគទុនិក។ លោកមានបទពិសោធន៍ក្នុងសហគ្រាសព័ត៌មានវិទ្យានៃក្រុមហ៊ុនអភិវឌ្ឍន៍ Software Telco, ISP, Tech startup និងវិស័យធនាគារ ព្រមទាំង ក្រុមហ៊ុនពហុជាតិដែលមានវប្បធម៌ចម្រុះ។ ជំនាញគោលរបស់លោក សូរិនរួមមាន៖ ការផ្លាស់ប្តូរផ្នែកឌីជីថល ការអភិវឌ្ឍ Agile Software និងEnterprise Architecture អភិបាលកិច្ចនៃសហគ្រាសព័ត៌មានវិទ្យា ការគ្រប់គ្រងគម្រោងព័ត៌មានវិទ្យា ប្រតិបត្តិការព័ត៌មានវិទ្យា ការអភិវឌ្ឍព័ត៌មានវិទ្យា បច្ចេកវិទ្យាសន្តិសុខ ការច្នៃឡើងវិញ និងបង្កើតដំណើរការ អាជីវកម្មតាមបែបស្វ័យប្រវត្តិ និងរៀបចំផែនការ ថវិកា និងការគ្រប់គ្រងថវិកា។

**លោក សូរិន** បានចូលរួម និងទទួលបានការបណ្តុះបណ្តាលជាច្រើននៅក្នុងវគ្គបណ្តុះបណ្តាលបច្ចេកទេស និងជំនាញផ្សេងៗទាំងក្នុង និងក្រៅស្រុកដូចជាប្រព័ន្ធទូទាត់ប្រាក់ ប្រព័ន្ធគិតប្រាក់និងវាយតម្លៃការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធគ្រប់គ្រងគុណភាពស្តង់ដា ISO 9001: 2000 ផែនការនៃភាពដឹកនាំ ការគ្រប់គ្រងនិរន្តរភាពអាជីវកម្មបច្ចេកវិទ្យាសន្តិសុខនិងសេវនកម្មព័ត៌មានវិទ្យា ITIL និងការបណ្តុះបណ្តាលបច្ចេកទេស T24 ។ លោកក៏ត្រូវបានអញ្ជើញឱ្យធ្វើការបង្រៀន នៅសាកលវិទ្យាល័យមួយចំនួននៅក្នុងប្រទេសកម្ពុជា។ បន្ថែមលើ ការតែងតាំងតួនាទីជាអគ្គនាយកព័ត៌មានវិទ្យានាពេលបច្ចុប្បន្ន លោកក៏ទទួលបន្ទុកតួនាទីជាអគ្គនាយកសន្តិសុខព័ត៌មានវិទ្យា តួនាទី ជាប្រធានគណៈកម្មាធិការព័ត៌មានវិទ្យា និងគណៈកម្មាធិការយុទ្ធសាស្រ្តព័ត៌មានវិទ្យា និងជាសមាជិកគណៈកម្មាធិការប្រតិបត្តិនៅធនាគារ អ៊ូរី (ខេមបូឌា) ម.ក។

លោកបានទទួលបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្រ្តព័ត៌មានវិទ្យាពីសកលវិទ្យាល័យ KMUT ដែលនៅភាគខាងជើងនៃទីក្រុង បាងកក ក្នុងឆ្នាំ 2009។

## លោកស្រី តុប សុក្រសម្ភារ

អគ្គនាយិកាគ្រប់គ្រងហានិភ័យ

**លោកស្រី សម្ភារ** បានចូលរួមការងារជាមួយធនាគារ អ៊ូរី (ខេមបូឌា) ម.ក នៅក្នុងឆ្នាំ 2002 ក្នុងតួនាទីជានាយិកា ហិរញ្ញវត្ថុ និងកិច្ចការរដ្ឋបាល។ លោកស្រីបានទទួលតំណែង ជាអគ្គនាយិកាប្រតិបត្តិការក្នុងឆ្នាំ 2008 ក្រោយមកក៏ផ្លាស់ប្តូរ តួនាទីទៅជាអគ្គនាយិកាគ្រប់គ្រងហានិភ័យនៅក្នុងខែមេសា ឆ្នាំ2021។ មុនពេលលោកស្រីបានចូលរួមនឹងធនាគារ អ៊ូរី (ខេមបូឌា) ម.ក លោកស្រីបានបម្រើការងារជាសវនករជាន់ខ្ពស់នៅក្រុមហ៊ុន Ernst & Young និង Price Water House - Coopers ។ បច្ចុប្បន្នលោកស្រីគឺជាសមាជិក ក្រុមប្រឹក្សាភិបាលនៃសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា។

លោកស្រីមានបទពិសោធន៍ច្រើនជាង 20 ឆ្នាំលើផ្នែកហិរញ្ញវត្ថុ គណនេយ្យ ការគ្រប់គ្រង យុទ្ធសាស្រ្ត និងផែនការធុរកិច្ច សវនកម្ម រដ្ឋបាល និងប្រាស្រ័យទាក់ទង។

លោកស្រីបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រ និងថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្មពីសកលវិទ្យាល័យជាតិ គ្រប់គ្រងនៅប្រទេសកម្ពុជា។ លោកស្រីបានទទួល វិញ្ញាបនបត្រ ថ្នាក់ជំនាញបច្ចេកទេសជាន់ខ្ពស់ផ្នែកគណនេយ្យ និងរដ្ឋបាល ពីមហាវិទ្យាល័យ Noisy Le Grand នៃប្រទេសបារាំង។

## លោកស្រី ស៊ីវ ច័ន្ទរល័ក្ខ

ប្រធាននាយកដ្ឋាន ផ្នែកប្រតិបត្តិតាម

**លោកស្រី ច័ន្ទវលក្ខណ៍** មានបទពិសោធន៍ការងាររយៈពេល 8ឆ្នាំ ជានាយិកាប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម នៅក្រោមនាយកដ្ឋានប្រតិបត្តិតាម នៅធនាគារពាណិជ្ជមួយកន្លែង មុនពេលចូលធ្វើការនៅធនាគារ អ៊ូរី (ខេមបូឌា) ម.ក ដែលមានឯកទេសផ្នែក ប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការងារទាក់ទងជាមួយការអនុលោមបទប្បញ្ញត្តិ ។

ជំនាញ ឯកទេស និងវិជ្ជាជីវៈរបស់លោកស្រី មានការរីកចម្រើនយ៉ាងឆាប់រហ័សដែលទទួលបានការកោតសរសើរពីថ្នាក់ដឹកនាំកំពូលក្នុងនាមជាអ្នកជំនាញវិជ្ជាជីវៈដែលឈានមុខគេក្នុងវិស័យពាក់ព័ន្ធនឹងប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម នៅក្នុងស្ថាប័នទាំងមូល ដោយចាប់ផ្តើមពីការសាកល្បងការងារឈានទៅជាតួនាទីជាប្រធាននាយកដ្ឋាន នៅក្នុងរយៈពេលដ៏ខ្លីមួយ។

ក្រៅពីការទទួលស្គាល់ពីថ្នាក់ដឹកនាំក្រុមហ៊ុន លោកស្រីក៏ទទួលស្គាល់ថាជាអ្នកជំនាញផ្នែកប្រតិបត្តិតាម និងជាអ្នកដឹកនាំក្នុងវិស័យធនាគារពី Finletekt និងជាអ្នកជំនាញផ្នែកប្រតិបត្តិតាម ក្នុងការចែករំលែកគោលគំនិត និងបទពិសោធន៍របស់លោកស្រី ក្នុងគោលបំណងចូលរួមចំណែក នៅក្នុងរបាយការណ៍របស់ Finletekt ដើម្បីបោះពុម្ពផ្សាយ ទាក់ទងនឹងវប្បធម៌ និងការបំពេញមុខងារផ្នែកប្រតិបត្តិតាម ។

ក្នុងនាមជាអ្នកជំនាញវិជ្ជាជីវៈដែលមានទេពកោសល្យវ័យក្មេងធ្វើការពាក់ព័ន្ធនឹងប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម លោកស្រីក៏ទទួលបានវិញ្ញាបនបត្របញ្ជាក់ការសិក្សាស្តីពីការអនុលោមតាមបទប្បញ្ញត្តិ ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា ដែលបន្ថែមពីលើសញ្ញាបត្រ ស្តីពី ការអនុលោមតាម នៃការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ពី ICA (សមាគមអនុលោមភាពអន្តរជាតិ)។

## កញ្ញា ហ៊ិន សុជាតិ

ប្រធាននាយកដ្ឋាន សវនកម្មផ្ទៃក្នុង

**កញ្ញា សុជាតិ** មានបទពិសោធន៍រយៈពេល 9ឆ្នាំទាក់ទងទៅនឹងវិស័យធនាគារ និងមីក្រូហ្វាយនែន និងរយៈពេល 16ឆ្នាំក្នុងវិស័យសវនកម្ម។ មុនពេលចូលបម្រើការនៅធនាគារ អ៊ូរី (ខេមបូឌា) ម.ក កញ្ញាធ្លាប់បានបម្រើការនៅក្រុមហ៊ុន PWC Cambodia ដែលធ្លាប់ធ្វើសវនកម្មហិរញ្ញវត្ថុដល់ក្រុមហ៊ុនជាច្រើននៅក្នុង វិស័យផ្សេងៗ ដូចជាវិស័យ ធនាគារ មីក្រូហិរញ្ញវត្ថុ ទូរគមនាគមន៍ ផលិតកម្ម សណ្ឋាគារ ភោជនីយដ្ឋាន ប្រេង ឧស្ម័ន ការលក់រាយ និងការចែកចាយ។

**កញ្ញា សុជាតិ** បច្ចុប្បន្នគឺជាសមាជិកមួយរូបនៃសមាគមន៍គណនេយ្យករជំនាញ ACCA ដែលកញ្ញាបានចូលជាសមាជិកតាំងពីឆ្នាំ 2014 មកម្លេះ។

កញ្ញាបានបញ្ចប់បិរញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្មផ្នែកគណនេយ្យ និងហិរញ្ញវត្ថុពីសកលវិទ្យាល័យជាតិគ្រប់គ្រង និងបិរញ្ញាបត្រអប់រំពីវិទ្យាស្ថានភាសាបរទេស (IFL) នៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ។

# III

# សមិទ្ធផល សម្រេចបាន

ការរចនានិងបន្ថែមមុខងារថ្មីលើសេវាកម្មធនាគារចល័ត........ 34
ដៃគូអាជីវកម្មឌីជីថលថ្មី ........................................................ 36
ពាណិជ្ជករដៃគូសហការថ្មី ...................................................... 38
ការបើកដំណើរការសាខាព្រៃមៀមថ្មី ....................................... 39
ការដាក់ដំណើរការផលិតផល និងសេវាកម្មថ្មីៗ ..................... 39

## ការរចនាថ្មីនៅលើកម្មវិធីធនាគារចល័ត

- ការរចនាថ្មីទៅលើទំព័រ KHQR
- ការបន្ថែមគណនីសម្រាប់មើលនៅលើទំព័រដើម
- កែប្រែរូបតំណាងថ្មី
- ការកែប្រែទៅលើមុខងារធនាគាររហ័សទៅតាមចំណូលចិត្ត
- តារាងគណនីថ្មី
- បន្ថែមទំព័រព័ត៌មានរបស់គណនីលម្អិត
- កែសម្រួលរូបតំណាងរបស់ប្រតិបត្តិការចាស់ៗ
- បន្ថែមមុខងារជំនួយរបស់គណនី
- បន្ថែមមុខងារ ផ្ទេរប្រាក់/បង់ប្រាក់ នៅក្នុងគណនីលម្អិត
- បន្ថែមការស្វែងរកមុខងារធនាគារនានា
- ការរចនាថ្មីទាំងស្រុងទៅលើទម្រង់ប្រតិបត្តិការហិរញ្ញវត្ថុ និងទម្រង់ប្រតិបត្តិការរបស់មុខងារផ្សេងៗទៀត។

## ការកែលម្អមុខងារថ្មីលើសេវាធនាគារចល័ត

- អនុញ្ញាតឲ្យអតិថិជនបើកដំណើរការគណនីរហ័សលើសេវាធនាគារចល័ត
- អនុញ្ញាតឲ្យអតិថិជនពិនិត្យមើលគណនីសន្សំតាមផែនការផ្លឹស លើសេវាធនាគារចល័ត
- ធ្វើបច្ចុប្បន្នភាពមាតិកាតេឡេក្រាម ឈ្មោះ និងរូបតំណាងកម្មវិធីថ្មី
- កែលម្អការបំពេញ OTP ដោយដៃ
- បន្ថែមសេវាទូទាត់វិក្កយបត្រ កម្សាន្ត លើសេវាធនាគារចល័ត
- អនុញ្ញាតឲ្យអតិថិជនគណនីបឋមវ័យប្រើប្រាស់សេវាធនាគារចល័ត
- បន្ថែមមុខងារសេវាផ្ទេរប្រាក់អន្តរជាតិ
- បន្ថែមទីតាំងសាខាថ្មី និង ម៉ាស៊ីនអេធីអឹម ទៅក្នុងមុខងារស្វែងរកពួកយើង
- បន្ថែមមុខងារថ្មី ណែនាំមិត្តភក្តិ ការជជែកផ្ទាល់ និងមុខងារផ្តល់មតិយោបល់

## ដៃគូអាជីវកម្មឌីជីថលថ្មី

ដោយស្របតាមទីផ្សារប្រកួតប្រជែង ក៏ដូចជាបំពេញតម្រូវការអតិថិជនដៃគូសហការតាមរយៈឌីជីថលត្រូវបានសហការជាមួយដៃគូថ្មីដូចខាងក្រោម៖

| # | ដៃគូសហការ | អំពីសេវាកម្មជាមួយដៃគូសហការ |
|---|---|---|
| 1 | សេវាកម្សាន្ត | អតិថិជនអាចទូទាត់វិក្កយបត្រសេវាកម្សាន្តនានាភ្លាមៗតាមរយៈធនាគារចល័តរបស់ធនាគារ អ៊ូរី (ចំនួន 22 ដៃគូសហការ)។ |
| 2 | អគ្គិសនីកម្ពុជា | អតិថិជនអាចទូទាត់វិក្កយបត្ររបស់អគ្គិសនីកម្ពុជាគ្រប់បណ្តាសាខាទាំងអស់ របស់អគ្គិសនីកម្ពុជាតាមរយៈមុខងារទូទាត់វិក្កយបត្រនៅក្នុងធនាគារចល័តរបស់ធនាគារ អ៊ូរី។ |
| 3 | សេវាបង់វិក្កយបត្រឯកជន | អតិថិជនអាចទូទាត់វិក្កយបត្រទឹក, ភ្លើង, សំរាម និងវិក្កយបត្រទូទៅ របស់សេវាឯកជនបានទូទាំងប្រទេសរហូតដល់ 200 សេវាករ។ |



## ពាណិជ្ជករដៃគូសហការថ្មី

នៅឆ្នាំ 2023 យើងបានសហការជាមួយរោងកុនធំៗចំនួន 2 ក្នុងប្រទេសកម្ពុជា នឹងបានបង្ហាញខ្លួនទៅកាន់អតិថិជនជាង 2 លាននាក់ ចាប់ពីក្មេងជំទង់រហូតដល់មនុស្សពេញវ័យ ដែល Major Cineplex និង Legend Cinema ជារោងកុនពេញនិយមជាងគេក្នុងប្រទេសកម្ពុជា។

លើសពីនេះ យើងក៏បានសហការជាមួយពាណិជ្ជករដៃគូសហការជាង 30 ហាង នៅឆ្នាំ 2023 ជាប្រភេទអាជីវកម្មចំរុះមានដូចជា ភោជនីយដ្ឋាន ហាងកាហ្វេ ហាងកែសម្ផស្ស និងហាងសាឡន ឱសថស្ថាន ម៉ាត គ្លីនិកធ្មេញ និងផាប់ជាដើម។

ពាណិជ្ជករដៃគូសហការសំដៅទៅលើដៃគូអាជីវកម្មដែលសហការដោយផ្តល់អត្រាបញ្ចុះតម្លៃពិសេសដល់អតិថិជនរបស់ធនាគារ អ៊ូរី តាមរយៈការស្កេនបង់ប្រាក់តាម WOORI-KHQR នៃហាងរបស់ពួកគេ (ដែលមានសេវារហ័សនិងងាយស្រួល)។

ចំនួនពាណិជ្ជករដៃគូសហការតាមប្រភេទអាជីវកម្ម

## ការបើកដំណើរការសាខាព្រីមៀមថ្មី

គិតត្រឹមខែធ្នូ ឆ្នាំ 2023 ធនាគារ អ៊ូរី មានបណ្តាញសាខាជាច្រើនដែលរួមមានការិយាល័យប្រចាំតំបន់ចំនួន 18 និងការិយាល័យសាខាចំនួន 140 នៅទូទាំង 25 ខេត្ត/ក្រុង 206 ស្រុក 1,715 ឃុំ និង 13,361 ភូមិទូទាំងប្រទេសកម្ពុជា។ ដើម្បីបង្កើនភាពងាយស្រួល និងឆ្លើយតបទៅនឹងតម្រូវការដែលកំពុងកើនឡើងរបស់អតិថិជនរបស់យើង ធនាគារ អ៊ូរី បានពង្រីកសាខាបន្ថែមនៅឆ្នាំ 2023 ដោយបានបន្ថែមសាខាព្រីមៀមថ្មីចំនួនពីរនៅក្នុងរាជធានីភ្នំពេញ។ ចាប់ផ្តើមដំណើរការនៅដើមឆ្នាំ 2023 សាខាទាំងនេះមានទីតាំងនៅខណ្ឌដូនពេញ និងខណ្ឌសែនសុខ រាជធានីភ្នំពេញ រួមមាន សាខាខណ្ឌដូនពេញ សង្កាត់ជ័យជំនះ និងសាខា-សែនសុខ-ទឹកថ្លា។ សាខាទាំងនេះបានត្រៀមខ្លួនរួចជាស្រេចក្នុងការផ្តល់នូវភាពងាយស្រួល និងសេវាកម្មល្អឥតខ្ចោះដល់អតិថិជន ។ បំពាក់ដោយបរិក្ខារទំនើបៗ និងតុបតែងដោយការរចនាខាងក្នុងដ៏ទាក់ទាញ រួមទាំងបន្ទប់ VIP សម្រាប់ការប្រឹក្សាឯកជន សាខាទាំងនេះត្រូវបានរចនាឡើងដើម្បីផ្តល់នូវបរិយាកាសស្វាគមន៍ និងផាសុកភាពសម្រាប់អតិថិជន។ ជាមួយនឹងការគាំទ្រឥតឈប់ឈរ និងតម្រូវការដែលកំពុងកើនឡើងពីអតិថិជនរបស់យើង ធនាគារ អ៊ូរី នៅតែប្តេជ្ញាពង្រីកប្រតិបត្តិការរបស់ខ្លួននៅទូទាំងប្រទេសកម្ពុជា ទាំងក្នុងរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ដើម្បីបម្រើឱ្យកាន់តែប្រសើរឡើង។

## ការដាក់ដំណើរការផលិតផល និងសេវាកម្មថ្មីៗ

### ផលិតផលគណនីសន្សំ

**គណនីរហ័ស** គឺជាផលិតផលបញ្ញើសន្សំមួយប្រភេទ ដែលត្រូវបានបង្កើតឡើងដើម្បីគាំទ្រប្រតិបត្តិការអាជីវកម្ម ដែលអនុញ្ញាតឱ្យអតិថិជនបើកគណនីថ្មីតាមរយៈធនាគារចល័ត។ គណនីរហ័ស បានផ្តល់នូវភាពងាយស្រួល ក្នុងការទាក់ទាញអតិថិជនថ្មីឱ្យប្រើប្រាស់សេវាកម្មរបស់ ធនាគារ អ៊ូរី ។

**គណនីបឋមវ័យ** គឺជាគណនីបញ្ញើសន្សំមួយប្រភេទដែលត្រូវបានបង្កើតឡើងសម្រាប់ក្មេងដែលមានអាយុចាប់ពី 10 ដល់ 17ឆ្នាំ អាចបើកគណនីជាមួយធនាគារ អ៊ូរី និងអនុញ្ញាតឱ្យធ្វើប្រតិបត្តិការហិរញ្ញវត្ថុមួយចំនួនតាមរយៈសេវាធនាគារចល័តរបស់ធនាគារ អ៊ូរី ដែលរាល់ការធ្វើប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់ស្ថិតនៅក្រោមការគ្រប់គ្រងពីសំណាក់ឪពុកម្តាយ ឬអាណាព្យាបាលរបស់ពួកគេ។

### ផលិតផលឥណទាន

កម្ចីសម្រាប់និយោជិតធ្វើការក្រៅប្រទេស គឺជាទម្រង់នៃកម្ចីមានកាលកំណត់ដែលមិនមានទ្រព្យធានា ដែលផ្តល់ជូនសម្រាប់គ្រប់និយោជិត/ពលករខ្មែរទាំងអស់ដែលទទួលបានការងារពេញសិទ្ធិនៅឯក្រៅប្រទេស សម្រាប់ជាមធ្យោបាយដល់ពួកគេក្នុងដំណើរការនៃការបំពេញបែបបទការងារ។

# IV

# ចំណុចសំខាន់ៗ អំពីអាជីវកម្ម


ទិន្នន័យហិរញ្ញវត្ថុសំខាន់ៗ ..... 42

របាយការណ៍អភិវឌ្ឍន៍ធនធានមនុស្ស..... 46

សក្ខីកម្មរបស់បុគ្គលិក ..... 47

ព័ត៌មានសំខាន់ៗ ..... 50

អំពីភាពជោគជ័យរបស់អតិថិជន..... 56

អំពីផលិតផល និងសេវាកម្ម..... 58

របាយការណ៍ស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម ..... 78

បណ្តាញសាខា និងតំបន់ប្រតិបត្តិការ..... 80

# ទិន្នន័យ ហិរញ្ញវត្ថុសំខាន់ៗ

## ទិន្នន័យសំខាន់ៗ

| បរិយាយ | ឆ្នាំ 2023 | ឆ្នាំ 2022 |
|---|---|---|
| ចំនួនអតិថិជនប្រាក់កម្ចីសកម្ម | **176,130** | 196,821 |
| % អតិថិជនប្រាក់កម្ចីជាស្ត្រី | **69%** | 71% |
| % អតិថិជនប្រាក់កម្ចីតាមជនបទ | **72%** | 72% |
| % អតិថិជនប្រាក់កម្ចីផ្នែកកសិកម្ម | **31.49%** | 33.40% |
| ចំនួនតំបន់ប្រតិបត្តិការ | **18** | 18 |
| ចំនួនស្រុកប្រតិបត្តិការ | **206** | 204 |
| ចំនួនបុគ្គលិកសរុប | **4,259** | 4,205 |
| **ផលប័ត្រឥណទាន** | **$1,216,174,546** | **$1,183,324,067** |
| ផលប័ត្រឥណទាន ជាមធ្យមសម្រាប់អ្នកខ្ចីម្នាក់ | **$6,905** | $6,012 |
| ផលប័ត្រឥណទាន ជាមធ្យមសម្រាប់មន្ត្រីឥណទានម្នាក់ | **$587,240** | $583,491 |
| ផលប័ត្រឥណទាន មានហានិភ័យ > 30 ថ្ងៃ | **4.27%** | 1.35% |
| ប្រាក់បញ្ញើរបស់អតិថិជន | **$444,831,158** | $353,464,472 |
| ចំនួនអ្នកដាក់ប្រាក់បញ្ញើ | **454,098** | 416,491 |
| **ទ្រព្យសកម្មសរុប** | **$1,461,968,327** | **$1,441,347,853** |
| **មូលនិធិម្ចាស់ហ៊ុនសរុប** | **$338,367,781** | **$322,495,295** |
| ប្រាក់ចំណេញធៀបដើមទុន | **4.80%** | 15.43% |
| ប្រាក់ចំណេញធៀបទ្រព្យសកម្ម | **1.09%** | 3.56% |

## វិធីសាស្ត្រប្រាក់កម្ចី

តាមចំនួនអតិថិជន




## វិធីសាស្ត្រប្រាក់កម្ចី

តាមទំហំផលប័ត្រឥណទាន




## និន្នាការកំណើន

ខែធ្នូ ឆ្នាំ 2023

**$1,216.17**
ផលប័ត្រឥណទាន
(គិតជាលានដុល្លារអាមេរិក)

**176,130**
ចំនួនអតិថិជនកម្ចី

**454,098**
ចំនួនអតិថិជនបញ្ញើសន្សំ

**$444.83**
សមតុល្យប្រាក់បញ្ញើ-សន្សំ
(គិតជាលានដុល្លារអាមេរិក)

**$1,461.97**
សរុបទ្រព្យសកម្ម
(គិតជាលានដុល្លារអាមេរិក)

ពីខែធ្នូឆ្នាំ 2020 ដល់ខែធ្នូឆ្នាំ 2023 (គិតជាលានដុល្លារអាមេរិក)









# របាយការណ៍បង់ពន្ធ

នៅក្នុងនាមជាធនាគារពាណិជ្ជដែលមានតម្លាភាពមួយយើងខ្ញុំសូមធ្វើការផ្សព្វផ្សាយជូនលោកអ្នកនូវរបាយការណ៍ពន្ធដែលបានបង់ដូចមានបង្ហាញជូននៅតារាងខាងក្រោម៖

| គិតជាដុល្លារអាមេរិក | 2020 | 2021 | 2022 | 2023 |
|---|---|---|---|---|
| ពន្ធលើប្រាក់ចំណូល | 6,876,812 | 11,756,722 | 11,800,719 | 2,751,389 |
| ប្រាក់រំដោះពន្ធលើប្រាក់ចំណូល | 843,090 | 1,252,193 | 1,708,308 | 1,766,710 |
| ពន្ធកាត់ទុក | 1,811,051 | 1,912,554 | 4,930,403 | 9,549,664 |
| ពន្ធលើប្រាក់បៀវត្ស | 1,029,252 | 1,324,151 | 1,639,996 | 1,419,224 |
| ពន្ធតែមសារពើពន្ធលើផ្ទាំងផ្សាយពាណិជ្ជកម្ម | 69,185 | 115,098 | 211,688 | 327,743 |
| អាករលើតម្លៃបន្ថែម | 17,767 | 0 | 5,222 | 190,194 |
| ពន្ធប៉ាតង់ | 18,500 | 18,500 | 18,500 | 18,500 |
| ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ | 2,301 | 3,593 | 3,388 | 3,186 |
| សរុប | **10,667,958** | **16,382,810** | **20,318,224** | **16,026,611** |
| សរុបបង្គរទុក* | **41,524,177** | **57,906,987** | **78,225,211** | **94,251,822** |

* សរុប និងសរុបបង្គរទុក គិតចាប់តាំងពីឆ្នាំ 2003។

# របាយការណ៍ **អភិវឌ្ឍន៍ធនធានមនុស្ស**

នៅឆ្នាំ 2023 ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានវិនិយោគប្រមាណ **US$350,062** ដុល្លារអាមេរិក ទោះបីជាមានការធ្លាក់ចុះនៃសេដ្ឋកិច្ច ពិភពលោកក៏ដោយក្នុងគោលបំណងកសាងសមត្ថភាពបុគ្គលិកតាមរយៈកម្មវិធីបណ្តុះបណ្តាល និងគំនិតផ្តួចផ្តើមផ្សេងៗ។ ការបណ្តុះបណ្តាលនេះដើម្បីបង្កើនចំណេះដឹង នឹងជំនាញរបស់និយោជិតរបស់ខ្លួនឱ្យក្លាយជាបុគ្គលិកអាជីពរបស់ធនាគារពាណិជ្ជ។

នៅឆ្នាំនោះដែរ ធនាគារ អ៊ូរី បានផ្តល់វគ្គបណ្តុះបណ្តាលចំនួន **1,273** (ក្នុងនោះ 66% តាមរយៈថ្នាក់រៀន 22% តាមរយៈថ្នាក់រៀននិម្មិត និង 12% តាមរយៈថ្នាក់រៀនអនឡាញ) ជូនដល់បុគ្គលិករបស់ខ្លួន។ ក្នុងចំណោមវគ្គសិក្សាទាំងអស់ មាន **1,216** គឺជាការបណ្តុះបណ្តាលរៀបចំខាងក្នុងស្ថាប័នរួមបញ្ចូលទាំង 47វគ្គ សម្រាប់បុគ្គលិកថ្មីៗ និង 57វគ្គ ជាការបណ្តុះបណ្តាលផ្តល់ជូនដោយស្ថាប័នខាងក្រៅជូនដល់បុគ្គលិករបស់យើងដោយមានបុគ្គលិកចូលរួមសរុប ចំនួន **125,776** នាក់។

បន្ថែមពីលើកម្មវិធីបណ្តុះបណ្តាលផ្សេងៗរបស់យើង ធនាគារ អ៊ូរី ក៏បានបង្កើត និងអនុវត្តនូវកម្មវិធីបណ្តុះបណ្តាលធំៗសំខាន់ៗមួយចំនួន ដូចជា កម្មវិធីពន្លកថ្មី កម្មវិធីការណែនាំបុគ្គលិកថ្មី កម្មវិធីប្រកួតប្រជែងចំណេះដឹង និងកម្មវិធីប្រលងសមត្ថភាពជាដើម ដោយមានបុគ្គលិកចូលរួមសរុបចំនួន **1,252**នាក់ ក្នុងគោលបំណងចូលរួម និងពង្រឹងការសិក្សារៀនសូត្រដល់បុគ្គលិកដែលមិនមានបទពិសោធន៍ និងក្រុមបុគ្គលិកផ្នែកលក់ជាដើម។

ការផ្តោតសំខាន់សម្រាប់ឆ្នាំ 2024 គឺការពង្រឹងបន្ថែមលើសេវាកម្មអតិថិជន និងជំនាញផ្នែកលក់តាមរយៈកម្មវិធីបណ្តុះបណ្តាលសំខាន់ៗដើម្បីបង្កើនចំណេះដឹងនៃក្រុមបុគ្គលិកផ្នែកលក់ក៏ដូចជាថ្នាក់ដឹកនាំរបស់ធនាគារផងដែរ ដែលជាកត្តាជម្រុញឱ្យបង្កើនផលិតភាពការងាររបស់ពួកគាត់ផងដែរ។ នេះរួមបញ្ចូលទាំងគុណភាពនៃការបណ្តុះបណ្តាលបុគ្គលិកថ្មី ការកែលម្អ នឹងពង្រឹងលើសេវាកម្មអតិថិជន និងជំនាញផ្នែកលក់ និងជំនាញបង្វឹកសម្រាប់អ្នកដឹកនាំរបស់យើងផងដែរ។ ការប្តេជ្ញាចិត្តរបស់យើង គឺរក្សាការរៀនសូត្រ និងការអភិវឌ្ឍន៍សមត្ថភាពបុគ្គលិកជាអាទិភាពដើម្បីធ្វើឱ្យធនាគារ អ៊ូរី ក្លាយជាធនាគារដែលផ្តល់សេវាកម្មលឿនបំផុតងាយស្រួល និងប្រកបដោយភាពច្នៃប្រឌិតបំផុតនៅក្នុងប្រទេសកម្ពុជា។

| ទិន្នន័យ វគ្គបណ្តុះបណ្តាល | 2023 | 2022 | 2021 |
|---|---|---|---|
| ចំនួនបុគ្គលិក | 4,259 | 4,205 | 3,783 |
| ចំនួនវគ្គបណ្តុះបណ្តាល | 1,273 | 1,107 | 616 |
| ចំនួនអ្នកចូលរួម | 125,776 | 130,469 | 80,857 |
| ចំនួនទឹកប្រាក់សរុប | $350,062 | $472,187 | $301,596 |
| ចំណាយមធ្យមសម្រាប់អ្នកចូលរួមម្នាក់ | $3 | $4 | $4 |
| ចំណាយមធ្យមសម្រាប់បុគ្គលិកម្នាក់ | $82 | $112 | $80 |

**ទិន្នន័យវគ្គបណ្តុះបណ្តាល ឆ្នាំ2021 ដល់ 2023**




## ការចែករំលែកបទពិសោធន៍ពីបុគ្គលិក

> ស្ត្រីគ្រប់រូប មានចរិតលក្ខណៈស្វាហាប់ក្លាហានឈានទៅមុខដោយមិនភ័យខ្លាចពីឧបសគ្គ។ សូមក្លាយខ្លួនឯង ទៅជាស្ត្រីដែលពោរពេញទៅដោយទេពកោសល្យ សមត្ថភាពច្នៃប្រឌិត ចំណេះដឹង ទូលំទូលាយឱ្យដូចជារចនានុក្រមមានជីវិត។

**សូ ដាលីន**
អ្នកគ្រប់គ្រងទូទៅ ប្រធាននាយកដ្ឋានគោលនយោបាយប្រាក់កម្ចី

អស់រយៈពេលជាងមួយទស្សវត្សរ៍ មកហើយ ដែលខ្ញុំបានក្លាយជាផ្នែកមួយនៃក្រុមដ៏មាន សក្តានុពលនៅ ធនាគារ អ៊ូរី តាំងពីឆ្នាំ 2011 ដែលបានចាប់ផ្តើមទៅជាដំណើរគួរឱ្យកត់សម្គាល់នៃការវិវឌ្ឍន៍នៃអាជីពការងារ ការអភិវឌ្ឍន៍ខ្លួន និងការបំពេញបន្ថែមយ៉ាងជ្រាលជ្រៅសម្រាប់ខ្លួនខ្ញុំផ្ទាល់។

**វឌ្ឍនភាពនៃអាជីព៖** តាំងតែពីការចាប់ផ្តើមដំបូងរបស់ខ្ញុំក្នុងនាមជាបុគ្គលិកថ្នាក់ដំបូង រហូតដល់តួនាទីបច្ចុប្បន្នរបស់ខ្ញុំជាអ្នកគ្រប់គ្រងទូទៅ និងប្រធាននាយកដ្ឋានគោលនយោបាយប្រាក់កម្ចី ធនាគារ អ៊ូរី គឺជាកត្តាជំរុញដល់វឌ្ឍនភាពនៃអាជីពរបស់ខ្ញុំ។ ការប្តេជ្ញាចិត្តឥតងាករេរបស់អង្គភាពក្នុងការបណ្តុះទេពកោសល្យ និងជំរុញវប្បធម៌នៃការរៀនសូត្រជាបន្តបន្ទាប់ បានផ្តល់ឱកាសឱ្យខ្ញុំអាចឡើងទៅកាន់មុខតំណែងប្រាំមួយផ្សេងគ្នា។

**ភាពជាអ្នកដឹកនាំ និងការបណ្តុះបណ្តាល៖** រៀងរាល់ជំហាននីមួយៗ ខ្ញុំត្រូវបានដឹកនាំដោយអ្នកដឹកនាំដែលមានទេពកោសល្យពីអ្នកដឹកនាំល្អៗទាំងជនជាតិខ្មែរ និងកូរ៉េ ដែលការបង្ហាត់បង្រៀន និងការណែនាំរបស់ពួកគាត់បានដើរតួយ៉ាងសំខាន់ក្នុងការលើកកម្ពស់ជំនាញរបស់ខ្ញុំ និងពង្រីកការយល់ដឹងរបស់ខ្ញុំ។

**សមិទ្ធិផលសម្រេចបានសំខាន់ៗ៖** ពេលវេលាដ៏សារៈសំខាន់បំផុតមួយនៅក្នុងអាជីពការងាររបស់ខ្ញុំនៅ ធនាគារ អ៊ូរី គឺបានឃើញការបំប្លែងស្ថាប័នរបស់យើងទៅជាធនាគារពាណិជ្ជ។ នេះគឺជាភាពជោគជ័យជាសមូហភាព ដែលជាសក្ខីភាពមួយចំពោះការលះបង់ និងចក្ខុវិស័យរបស់យើងទាំងអស់គ្នា។ សមិទ្ធិផលដែលគួរឱ្យស្ញប់ស្ញែងមួយនេះ មិនត្រឹមតែជាសញ្ញាដ៏សំខាន់ប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការប្តេជ្ញាចិត្តជាថ្មី ដើម្បីក្លាយជាធនាគារដែលជាជម្រើសល្អបំផុតសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប។

**បរិយាកាសកន្លែងធ្វើការ៖** ធនាគារ អ៊ូរី មិនគ្រាន់តែជាកន្លែងធ្វើការប៉ុណ្ណោះទេ វាគឺជាផ្ទះទីពីររបស់ខ្ញុំ ជាទីជម្រកដ៏សែនកក់ក្តៅ ដែលខ្ញុំអាចពង្រឹងចំណេះដឹង និងជំនាញរបស់ខ្ញុំក្នុងកិច្ចការ និងទំនួលខុសត្រូវផ្សេងៗគ្នា។ បរិយាកាសការងារដែលពោរពេញទៅដោយការគាំទ្រ សហការគ្នា គួបផ្សំនឹងឱកាសរីកចម្រើនជាច្រើននៅក្នុងស្ថាប័ន បានជំរុញទឹកចិត្តរបស់ខ្ញុំ ដើម្បីអភិវឌ្ឍន៍ខ្លួនកាន់តែពូកែ និងទទួលបានភាពជោគជ័យដូចថ្ងៃនេះ។

**ការរួមចំណែកដល់សហគមន៍៖** លើសពីការរីកចម្រើនផ្ទាល់ខ្លួន ការក្លាយជាផ្នែកមួយនៃធនាគារ អ៊ូរី មានន័យថាជាការចូលរួមជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងភាពរុងរឿងនៅក្នុងប្រទេសកម្ពុជា។ ក្នុងនាមជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារឈានមុខគេនៅប្រទេសកូរ៉េ ការរួមចំណែករបស់យើងចំពោះសេដ្ឋកិច្ចក្នុងស្រុកតាមរយៈផលិតផល និងសេវាកម្មហិរញ្ញវត្ថុប្រកបដោយភាច្នៃប្រឌិត គឺជាមោទនភាពដ៏ធំធេងរបស់បុគ្គលិកគ្រប់ៗរូប។

អនុសាសន៍ និងសេចក្តីបញ្ចប់៖ ការរួមដំណើររបស់ខ្ញុំជាមួយ ធនាគារ អ៊ូរី គឺលើសពីការរំពឹងទុក។ សម្រាប់អ្នកដែលកំពុងពិចារណាលើអាជីពក្នុងវិស័យធនាគារ មិនថានិស្សិតបញ្ចប់ការសិក្សាថ្មីៗ ឬអ្នកជំនាញដែលមានបទពិសោធន៍នោះទេ ខ្ញុំសូមណែនាំក្នុងការចាប់យកឱកាសដ៏ល្អដើម្បីចូលរួមជាមួយធនាគារ អ៊ូរី។ នៅទីនេះ វាមិនមែនគ្រាន់តែជាការបំពេញការងារនោះទេ តែគឺជាមាគ៌ាក្នុងការអភិវឌ្ឍអនាគតផ្ទាល់ខ្លួន និងវិជ្ជាជីវៈ ដែលការរួមចំណែករបស់អ្នក ទទួលបាននូវការផ្តល់តម្លៃ ហើយ សមត្ថភាពរបស់អ្នកនឹងរីកចម្រើនរួមគ្នាជាមួយធនាគារ អ៊ូរី ។

”

**ការចាប់យកឱកាស ការរីកចម្រើន និងដំណើរជីវិតការងាររបស់ខ្ញុំនៅធនាគារ អ៊ូរី**

”

**គង់ ចន្ថា**

នាយក (ប្រធាននាយកដ្ឋានយុទ្ធសាស្រ្ត និងផែនការ)

ខ្ញុំបាទឈ្មោះ គង់ ចន្ថា ហើយខ្ញុំមានកិត្តិយសក្នុងការចែករំលែកបទពិសោធន៍ និងបង្ហាញអំពីពេលវេលារបស់ខ្ញុំនៅធនាគារ អ៊ូរី។ ចាប់តាំងពីខែកញ្ញា ឆ្នាំ2008 មក ខ្ញុំបានបម្រើការងារ និងជាផ្នែកមួយនៃគ្រួសារធនាគារ អ៊ូរី ដោយបានចាប់ផ្តើមការងារពោរពេញទៅដោយការរីកចម្រើន ការរៀនសូត្រ និងមិត្តភាព។

**តួនាទីដំបូង និងវឌ្ឍនភាពអាជីពការងារ៖** ខ្ញុំបានចាប់ផ្តើមជាប្រធានរដ្ឋបាល ខ្ញុំបានចំណាយរយៈពេលប្រាំឆ្នាំចំពោះតួនាទីនេះ មុនពេលផ្លាស់ប្តូរទៅកាន់លេខាធិការដ្ឋានក្រុមហ៊ុន ច្បាប់ និងប្រតិបត្តិតាម។ ថ្ងៃនេះ ខ្ញុំមានមោទនភាពក្នុងការដឹកនាំនាយកដ្ឋានយុទ្ធសាស្រ្ត និងផែនការ ដែលជាសក្ខីកម្មអំពីឱកាសសម្រាប់ការរីកចម្រើននៅក្នុងធនាគារ អ៊ូរី ។

**ការរកឃើញនូវផ្ទះទីពីរ៖** នៅពេលខ្ញុំត្រឡប់មកពីក្រៅប្រទេសវិញ ធនាគារ អ៊ូរី បានស្វាគមន៍ខ្ញុំយ៉ាងកក់ក្តៅ ដោយមិនត្រឹមតែផ្តល់ឱកាសការងារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់នូវបរិយាកាសមួយ ដែលពោរពេញទៅដោយការជ្រោមជ្រែង ធ្វើឱ្យខ្ញុំមានអារម្មណ៍ថាដូចជាផ្ទះទីពីររបស់ខ្ញុំ។ នៅទីនេះ ខ្ញុំអាចបណ្តុះជំនាញរបស់ខ្ញុំ ពង្រីកចំណេះដឹង និងបង្កើតទំនាក់ទំនងជីវិតជាមួយមិត្តរួមការងារ។

**ចំណុចសំខាន់ៗដែលគួរឱ្យចងចាំ៖** ខណៈពេលដែលមានអនុស្សាវរីយ៍ដ៏គួរឱ្យចងចាំជាច្រើននៅ ធនាគារ អ៊ូរី គ្មានអ្វីអាចចងចាំជាង ការសប្បាយចិត្តពេលសម្រេចបាននូវកិច្ចការតាមពេលកំណត់នោះទេ។ ពេល សម្រេចសមិទ្ធផលបានទាំងនេះ បញ្ជាក់នូវការប្តេជ្ញាចិត្តរបស់ខ្ញុំចំពោះការងារ និងជម្រុញទៅរកភាពជោគជ័យ។

**វប្បធម៌នៃការងារជាក្រុម៖** ធនាគារ អ៊ូរី តែងតែមានវប្បធម៌នៃការសហការ និងការឯកភាពគ្នាក្នុងចំណោមសមាជិកបុគ្គលិក។ ទីនេះពិតជាពិសេសជាងកន្លែងធ្វើការផ្សេងទៀតដែលខ្ញុំធ្លាប់ធ្វើ នៅទីនេះយើងពិតជាជ្រោមជ្រែង និងលើកកម្ពស់គ្នាទៅវិញទៅមក បង្កើតអារម្មណ៍នៃមិត្តភាពដែលជំរុញភាពជោគជ័យរួមរបស់យើង។

**មោទនភាពលើប្រវត្តិ និងបណ្តាញ៖** ក្នុងនាមជាផ្នែកមួយនៃធនាគារ អ៊ូរី ខ្ញុំមានមោទនភាពយ៉ាងខ្លាំងចំពោះប្រវត្តិដ៏យូរអង្វែង និងបណ្តាញអន្តរជាតិដ៏ទូលំទូលាយរបស់យើង ដែលមានរយៈពេលជាងមួយសតវត្សនៅក្នុងវិស័យធនាគារ។ ការផ្សារភ្ជាប់ជាមួយនឹងស្ថាប័នដ៏ល្បីឈ្មោះបែបនេះ បង្កើតឱ្យមានមោទនភាព និងគោលដៅនៅក្នុងការងាររបស់ខ្ញុំ។

**ការរៀនសូត្រ និងការរីកចម្រើនជាបន្តបន្ទាប់៖** បរិយាកាសការងារដែលរួសរាយរាក់ទាក់ និងគាំទ្រនៅធនាគារ អ៊ូរី ជំរុញឱ្យមានការរៀនសូត្រជាបន្តបន្ទាប់ និងការរីកចម្រើនផ្ទាល់ខ្លួន។ ជាមួយនឹងស្តង់ដារខ្ពស់នៃការងារ និងនីតិវិធីនៅនឹងកន្លែង ខ្ញុំមានការជំរុញចិត្តជានិច្ចឱ្យធ្វើលើសពីដែនកំណត់របស់ខ្ញុំ និងខិតខំឆ្ពោះទៅភាពល្អឥតខ្ចោះ។

**ការអភិវឌ្ឍន៍អាជីព និងការទទួលស្គាល់៖** ដំណើរជីវិតរបស់ខ្ញុំនៅធនាគារ អ៊ូរី ត្រូវបានសម្គាល់ដោយការរីកចម្រើនក្នុងអាជីពបន្តបន្ទាប់ និងការទទួលស្គាល់ចំពោះការរួមចំណែករបស់ខ្ញុំ។ ពីអ្នកដឹកនាំក្រុមរហូតដល់មុខតំណែងជាអ្នកដឹកនាំជាន់ខ្ពស់ ការតម្លើងឋានៈនីមួយៗគឺជាសក្ខីភាពបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ស្ថាប័ន លើការទទួលស្គាល់ទេពកោសល្យ និងផ្តល់រង្វាន់ដល់ការខិតខំប្រឹងប្រែងរបស់បុគ្គលិក។

**អនុសាសន៍សម្រាប់អ្នកដែលនឹងក្លាយជានិយោជិត៖** ចំពោះអ្នកទាំងអស់គ្នាដែលពិចារណាលើអាជីព ខ្ញុំសូមណែនាំក្នុងការចាប់យកឱកាសដើម្បីចូលរួមជាមួយគ្រួសារធនាគារ អ៊ូរី។ នៅទីនេះ មិនត្រឹមតែជាការងារប៉ុណ្ណោះទេ ប៉ុន្តែជាសហគមន៍ដែលការរីកចម្រើន និងភាពជោគជ័យរបស់អ្នកត្រូវបានជ្រោមជ្រែងគ្រប់ជំហាន។ ចូលរួមជាមួយខ្ញុំនៅ ធនាគារ អ៊ូរី យើងនឹងរីកចម្រើន និងជោគជ័យជាមួយគ្នា!

”

**ដោយឆ្លងកាត់ពេលវេលាជាង 16 ឆ្នាំរបស់ខ្ញុំនៅធនាគារ អ៊ូរី ខ្ញុំបានធ្វើឱ្យមានតុល្យភាពរវាងការងារ និងជីវិតផ្ទាល់ខ្លួន ដែលជាសក្ខីភាពបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ធនាគារចំពោះសុខុមាលភាពបុគ្គលិក**

”

**លី សុភា**

នាយកគ្រប់គ្រងតំបន់ ប្រចាំខេត្តបាត់ដំបង

**ពីមន្រ្តីឥណទានទៅជាអ្នកគ្រប់គ្រងប្រចាំតំបន់៖** ក្នុងរយៈពេលជាង 17 ឆ្នាំ នៃការធ្វើការរបស់ខ្ញុំនៅធនាគារ អ៊ូរី ដោយចាប់ផ្តើមជាមន្រ្តីឥណទានក្នុងឆ្នាំ 2006។ ខ្ញុំបានទទួលការរីកចម្រើនប្រកបដោយវិជ្ជាជីវៈ ដោយបានផ្លាស់ប្តូរពីតួនាទីតូចៗទៅកាន់តំណែងជាអ្នកគ្រប់គ្រង។ ថ្ងៃនេះ ក្នុងនាមជាអ្នកគ្រប់គ្រងប្រចាំតំបន់ ខ្ញុំរីករាយណាស់ក្នុងការចែករំលែកបទពិសោធន៍ និងលះបង់នៅទីនេះ។

**ការសិក្សា និងការរីកចម្រើន៖** ការចូលរួមជាមួយធនាគារ អ៊ូរី គឺជាការសម្រេចចិត្តដ៏សំខាន់មួយ ជាពិសេសបន្ទាប់ពីការដឹកនាំរបស់ខ្ញុំនៅវីសិន ហ្វាន់ ។ នៅទីនេះ ខ្ញុំបានបម្រើការងារនៅក្នុងមុខងារផ្សេងៗដូចជា អ្នកគ្រប់គ្រងឥណទាន អ្នកគ្រប់គ្រងគុណភាពឥណទាន អ្នកគ្រប់គ្រងរដ្ឋបាល និងការគ្រប់គ្រងហានិភ័យ។ ធនាគារ អ៊ូរី បានផ្តល់បរិយាកាសដ៏សម្បូរបែបជាមួយនឹងគំរូល្អៗ និងការអនុវត្តក្នុងការគ្រប់គ្រង ដោយបណ្តុះជំនាញរបស់ខ្ញុំជាបន្តបន្ទាប់។

**ការងារជាក្រុម និងការលះបង់៖** ទោះបីជាមានបញ្ហាប្រឈមដូចជាការទាមទារធ្វើការនៅចុងសប្តាហ៍ និងវេនយប់ខ្លះក៏ដោយ វាពិតជាផ្តល់រង្វាន់យ៉ាងច្រើន ពីការសហការគ្នាជាមួយក្រុមការងាររបស់ខ្ញុំ។ យើងធានាឱ្យមានការផ្លាស់ប្តូរប្រកបដោយភាពរលូន និងបានសម្រេចព្រឹត្តិការណ៍ដ៏ធំ ដែលជាសក្ខីភាពមួយចំពោះកិច្ចខិតខំប្រឹងប្រែងរួមរបស់យើង និងភាពជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាព។

**សាលា និងគ្រួសារទីពីរ ៖** ធនាគារ អ៊ូរី មិនត្រឹមតែជាកន្លែងធ្វើការប៉ុណ្ណោះទេ ប៉ុន្តែជាសាលា និងគ្រួសារទីពីរ ដែលបង្កើតនូវជំនាញក្នុងអាជីពការងាររបស់ខ្ញុំ និងការជម្រុញលើកទឹកចិត្ត។ ការងារប្រចាំថ្ងៃ បង្ហាញពីឱកាសមួយសម្រាប់ការពង្រឹងជំនាញ និងការរីកចម្រើនផ្ទាល់ខ្លួន ដោយសារប្រព័ន្ធនៃការគ្រប់គ្រងដែលគាំទ្រដោយធនាគារ អ៊ូរី។

**មោទនភាពក្នុងស្ថាប័ន៖** ខ្ញុំមានមោទនភាពយ៉ាងខ្លាំងក្នុងការក្លាយជាផ្នែកមួយរបស់ធនាគារ អ៊ូរី ដែលជាធនាគារលំដាប់ពិភពលោកដែលមានអាយុកាលជាង 120 ឆ្នាំ និងមានវត្តមាននៅក្នុង 24 ប្រទេសជុំវិញពិភពលោក។ ការរួមបញ្ចូលគ្នានៃធនាគារលំដាប់ពិភពលោក និងធនាគារក្នុងស្រុកធ្វើឱ្យធនាគារ អ៊ូរី បានក្លាយជាធនាគារពណិជ្ជឈានមុខគេមួយនៅក្នុងវិស័យធនាគារ។

**តុល្យភាពជីវិត និងការងារ៖** ដោយឆ្លងកាត់ពេលវេលាជាង 16 ឆ្នាំរបស់ខ្ញុំនៅធនាគារ អ៊ូរី ខ្ញុំបានធ្វើឱ្យមានតុល្យភាពរវាងការងារ និងជីវិតផ្ទាល់ខ្លួន ដែលជាសក្ខីភាពបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ធនាគារចំពោះសុខុមាលភាពបុគ្គលិក។ ការសម្រេចបាននូវសមិទ្ធផលសំខាន់ៗ ខណៈពេលដែលរក្សាលំនឹងនេះគឺពិតជារង្វាន់ដ៏ធំធេង សម្រាប់ខ្ញុំ។

**ផ្តោតលើការអភិវឌ្ឍន៍សមត្ថភាព៖** វិធីសាស្រ្តប្រកបដោយភាពច្នៃប្រឌិតរបស់ ធនាគារ អ៊ូរី ចំពោះការអភិវឌ្ឍន៍បុគ្គលិកគឺគួរឱ្យកោតសរសើរ ដោយមានការសង្កត់ធ្ងន់យ៉ាងខ្លាំងលើការកសាងសមត្ថភាពតាមរយៈការបណ្តុះបណ្តាល និងផែនការសិក្សាដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ។ ការប្តេជ្ជាចិត្តនេះឆ្លុះបញ្ចាំងពីជំនឿដែលថាដំណើររបស់និយោជិតម្នាក់ៗគឺដូចគ្នាទៅនឹងសៀវភៅពិសេសមួយ ដែលពោរពេញទៅដោយឱកាសសម្រាប់ការលូតលាស់ និងការពង្រឹងសមត្ថភាព។

# ព័ត៌មានសំខាន់ៗ

## ធនាគារ អ៊ូរី ផ្តល់អាហារូបករណ៍ចំនួន 100កន្លែងក្នុងមួយឆ្នាំដល់និស្សិតនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

ភ្នំពេញ ថ្ងៃទី10 ខែមករា ឆ្នាំ2023 ធនាគារ អ៊ូរី បានចុះអនុស្សរណៈយោគយល់គ្នា ជាមួយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីផ្តល់អាហារូបករណ៍ចំនួន 100 ដែលមានតម្លៃស្មើ $50,000 ក្នុងមួយឆ្នាំដល់និស្សិតថ្នាក់បរិញ្ញាបត្រលើមុខវិជ្ជាឯកទេសសំខាន់ៗចំនួនប្រាំមួយ។ អនុស្សរណៈយោគយល់គ្នា គឺជាការចាប់ផ្តើមនៃកិច្ចសហប្រតិបត្តិការរយៈពេលវែងរវាងធនាគារ អ៊ូរី និង សាកលវិទ្យាល័យភូមិន្ទភ្នំពេញសម្រាប់ការរីកចម្រើនប្រកបដោយចីរភាពរបស់កម្ពុជា។

## ធនាគារ អ៊ូរី បានចូលរួមការងារសង្គមជាមួយ ទីភ្នាក់ងារ កិច្ចសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) នៅខេត្តព្រៃវែង

ថ្ងៃទី19 ខែឧសភា ឆ្នាំ2023 ធនាគារ អ៊ូរី បានចូលរួមជាមួយភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) អង្គការ និងស្ថាប័នក្រុមហ៊ុនកូរ៉េមួយចំនួន ក្នុងការចូលរួមចំណែកក្នុងកិច្ចការសង្គមនៅអនុវិទ្យាល័យ តាកៅ ខេត្តព្រៃវែង ក្រោមប្រធានបទ ពិធីបរិច្ចាកសង្គម "សុខសប្បាយ" "Soksabay" Social Activity Donation Ceremony ។ កម្មវិធីនេះរួមមានសកម្មភាពចម្រុះៗដូចជា ការអប់រំចំណេះដឹងហិរញ្ញវត្ថុ ការអប់រំទាក់ទងទៅនឹងសុខភាព អនាម័យ និងមានការចែកជូននូវសម្ភារសិក្សា កង់ និងមួកសុវត្ថិភាពដល់សិស្សានុសិស្សផងដែរ។ ក្រៅពីនេះ មានការដាក់ស្តង់បើកគណនីជូនប្រជាពលរដ្ឋ ព្រមទាំងមានការចែកជូនកាដូអនុស្សាវរីយ៍ផងដែរ។

## ធនាគារ អ៊ូរី ឧបត្ថម្ភអគារមណ្ឌលសុខភាពថ្មីមួយខ្នងដល់រដ្ឋបាលខេត្តកំពង់ធំ

កំពង់ធំ ថ្ងៃទី 12 ខែមិថុនា ឆ្នាំ 2023 **ធនាគារ អ៊ូរី បានប្រគល់អគារឧបត្ថម្ភថ្មីនៃមណ្ឌលសុខភាព** (តាំងក្រសាំង) ស្រុកសន្ទុក ខេត្តកំពង់ធំ ក្រោមអធិបតីភាព ឯកឧត្តម ជា ចាន់តូ និងលោក Seok Mo Yoon តំណាងពីធនាគារ អ៊ូរី កូរ៉េ ។ អគារដែលទើបសាងសង់ថ្មីនេះ គាំទ្រដោយធនាគារ អ៊ូរី (ខេមបូឌា) ម.ក។ មណ្ឌលសុខភាពនេះជាសញ្ញាបង្ហាញនៃក្តីសង្ឃឹមសម្រាប់សហគមន៍ ដែលនឹងផ្តល់សេវាថែទាំសុខភាពឱ្យបានប្រសើរឡើងសម្រាប់ប្រជាពលរដ្ឋនៅស្រុកសន្ទុក និងតំបន់ដែលនៅក្បែរនោះ។

## ធនាគារ អ៊ូរី ឧបត្ថម្ភលើគម្រោងបង្កើនសមត្ថភាព ឌីជីថលក្នុងវិស័យអប់រំ គាំទ្រដោយក្រសួងអប់រំ យុវជន និងកីឡា

ភ្នំពេញ ថ្ងៃទី 27 ខែ កក្កដា ឆ្នាំ 2023៖ ធនាគារ អ៊ូរី បានចុះហត្ថលេខាលើ អនុស្សរណៈយោគយល់គ្នា ជាមួយអង្គការឆាលហ្វាន់ ខេមបូឌា ដើម្បីផ្តល់មូលនិធិសប្បុរសធម៌តាមរយៈអង្គការ ឆាលហ្វាន់ កូរ៉េ ដើម្បីគាំទ្រដល់គម្រោងនៃ "ការកែលម្អសមត្ថភាពឌីជីថលក្នុងវិស័យអប់រំ" របស់អង្គការ ឆាលហ្វាន់ ខេមបូឌា។ គម្រោងនេះចាប់ពីខែកក្កដា ឆ្នាំ 2023 ក្នុងគោលបំណងលើកកម្ពស់ការអប់រំឌីជីថល និងការបំពាក់បរិក្ខារកុំព្យូទ័រ (បន្ទប់កុំព្យូទ័រ និងបណ្ណាល័យ) នៅក្នុងសាលាចំនួន 21 ដែលបានជ្រើសរើសចាប់ពីបឋមសិក្សាដល់មធ្យមសិក្សាទុតិយភូមិរាជធានីភ្នំពេញ ខេត្តកណ្តាល និងកំពង់ធំ។ គំនិតផ្តួចផ្តើមនេះនឹងជួយដល់កុមារជាង 24,000 នាក់ក្នុងការរៀនមូលដ្ឋានគ្រឹះនៃជំនាញកុំព្យូទ័ររួមទាំងចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងសុវត្ថិភាពអនឡាញ ដែលនឹងអនុញ្ញាតឱ្យពួកគេពង្រីកចំណេះដឹង និងជំនាញរបស់ពួកគេបន្ថែមទៀតនិងចំណេះដឹងដើម្បីក្លាយខ្លួនជាធនធានសំខាន់សម្រាប់ពិភពលោកនាពេលអនាគត។

## ធនាគារ អ៊ូរី គាំទ្រសហគមន៍សប្បុរស តាមរយៈគណនីសន្សំ សប្បុរស

ធនាគារ អ៊ូរី បានបង្ហាញពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការធ្វើសប្បុរសធម៌តាមរយៈការបរិច្ចាគយ៉ាងសំខាន់ដល់ដៃគូសប្បុរសធម៌ផ្សេងៗ តាមរយៈកម្មវិធី របស់គណនីសប្បុរស។ ធនាគារបានចូលរួមចំណែកសរុបជាង **50,000 USD** (ចំនួនបង្គរសម្រាប់ឆ្នាំ 2022 និង 2023) ដល់អង្គការសប្បុរសមួយចំនួនដូចជា មូលនិធិគន្ធបុប្ផាកម្ពុជា មន្ទីរពេទ្យកុមារអង្គរ មូលនិធិព្រះធម៌ មូលនិធិកុមារកម្ពុជា និង សាលាដុនបូស្កូ។ ការផ្តល់ដ៏សប្បុរសនេះមិនត្រឹមតែឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់របស់ធនាគារក្នុងការគាំទ្រសហគមន៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបញ្ជាក់ពីតួនាទីរបស់ធនាគារ ក្នុងនាមជាសាជីវកម្មដែលមានការទទួលខុសត្រូវសង្គមផងដែរ។ តាមរយៈការបរិច្ចាគធនធានទៅកាន់អង្គការដែលផ្តោតលើការថែទាំសុខភាព ការអប់រំ និងសុខុមាលភាពសង្គម ធនាគារ អ៊ូរី បន្តផ្តល់នូវអត្ថប្រយោជន៍ដ៏មានអត្ថន័យដល់ជីវិតរបស់បុគ្គល និងប្រជាជនកម្ពុជា។

## ធនាគារ អ៊ូរី សហការជាមួយក្រុមហ៊ុន វើរីវើដស៍ ដើម្បីជំរុញ ESG សម្រាប់ប្រទេសកម្ពុជា!

ភ្នំពេញ ថ្ងៃទី27 ខែកុម្ភៈ ឆ្នាំ2023 ធនាគារ អ៊ូរី និង ក្រុមហ៊ុន VERYWORDS បានចុះអនុស្សរណៈនៃការយោគយល់គ្នាដើម្បីលើកកម្ពស់ ការប្រើប្រាស់យានយន្តអគ្គិសនីនៅកម្ពុជា តាមរយៈការដំឡើងស្ថានីយ៍សាកថ្មនៅសាខារបស់ ធនាគារ អ៊ូរី។ កិច្ចសហការនេះមានគោលបំណងសម្រួលដំណើរការសាកថ្មសម្រាប់រថយន្តអគ្គីសនីរបស់ ក្រុមហ៊ុន VERYWORDS រួមចំណែកដល់ប្រព័ន្ធដឹកជញ្ជូនកាន់តែស្អាត និងប្រកបដោយចីរភាព។ អនុស្សរណៈ រវាងក្រុមហ៊ុនទាំងពីរបានគូសបញ្ជាក់ពីបេសកកម្មក្នុងការបង្កើតប្រព័ន្ធអេកូឡូស៊ីសម្រាប់រថយន្តអគ្គិសនីនៅកម្ពុជា ក៏ដូចជាគាំទ្រដល់បរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) សម្រាប់កម្ពុជា។

## ធនាគារ អ៊ូរី បានដាក់ឱ្យដំណើរការជាផ្លូវការនូវប័ណ្ណឥណពន្ធ វីសាទៅកាន់ទីផ្សារ

ធនាគារ អ៊ូរី បានប្រារព្ធ ព្រឹត្តិការណ៍ដ៏សំខាន់មួយនៅថ្ងៃទី 28 ខែសីហា ឆ្នាំ 2023 ដោយបានដាក់សម្ពោធប័ណ្ណឥណពន្ធវីសារបស់ខ្លួននៅការិយាល័យកណ្តាលរបស់ ធនាគារ អ៊ូរី។ ពិធីសម្ពោធនេះត្រូវបានប្រព្រឹត្តិទៅក្រោមអធិបតីភាព លោក គីម ហុងជូ អគ្គនាយកប្រតិបត្តិនៃ ធនាគារ អ៊ូរី និងលោកស្រី Ivana Tranchini នាយកប្រចាំប្រទេសនៃ VISA។ ពិធីសម្ពោធនេះបានដាក់ដំណើរការនូវប័ណ្ណវីសា អ៊ូរី បីប្រភេទ គឺ Visa Classic, Visa Platinum និង Visa Gold ។ ព្រឹត្តិការណ៍ នេះបានគូសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ ធនាគារ អ៊ូរី ចំពោះការច្នៃប្រឌិត និងការដោះស្រាយតម្រូវការដែលកើនឡើងរបស់អតិថិជនរបស់ខ្លួន។ ជាផែនការទៅថ្ងៃអនាគត ធនាគារ អ៊ូរី និងមានគម្រោងក្នុងការដាក់ដំណើរការ ប័ណ្ណវីសាឥណទាន និង ប័ណ្ណវីសានិម្មិត្ត និងការប្តេជ្ញាចិត្តរបស់ធនាគារក្នុងការផ្តល់នូវដំណោះស្រាយហិរញ្ញវត្ថុដែលសមស្របតាមរបៀបរស់នៅដែលទាន់សម័យ និងតម្រូវការទីផ្សារ។

## ធនាគារ អ៊ូរី បានប្រារព្ធពិធីបិទវគ្គកម្មវិធី ពន្លកថ្មី ជំនាន់ទី 2 ដោយជោគជ័យ!

ធនាគារ អ៊ូរី បានបញ្ចប់កម្មវិធី បណ្តុះបណ្តាលពន្លកថ្មី ជំនាន់ទី២ Talent Incubation Program Generation II ជាមួយនឹងពិធីបិទកម្មវិធីដែលធ្វើឡើងនៅថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2023។ កម្មវិធីប្រព្រឹត្តិទៅក្រោមអធិបតីភាពលោក គីម ហុងជូ អគ្គនាយកប្រតិបត្តិ និងគណៈគ្រប់គ្រងជាន់ខ្ពស់នៃ ធនាគារ អ៊ូរី ដើម្បី អបអរសាទរដល់ពន្លកថ្មីចំនួន 45 នាក់ ដែលបានបញ្ចប់កម្មវិធីបណ្តុះបណ្តាលរយៈពេល 3 ខែយ៉ាងម៉ត់ចត់។ កម្មវិធី បណ្តុះបណ្តាលពន្លកថ្មី របស់ធនាគារ អ៊ូរី ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ 2022 ក្នុងគោលបំណងផ្តល់អាទិភាព ដល់និស្សិតដែលកំពុងសិក្សា និងទើបបញ្ចប់ការសិក្សាថ្មីៗ ជាមួយនឹងជំនាញ និងចំណេះដឹងចាំបាច់សម្រាប់អាជីពបំពេញការងារក្នុងវិស័យធនាគារ។ តាមរយៈការបញ្ចូលគ្នានៃការតម្រង់ទិសបុគ្គលិកថ្មី និងវគ្គសិក្សាជាក់លាក់របស់នាយកដ្ឋាន អ្នកចូលរួមត្រូវបានបណ្តុះបណ្តាល និងណែនាំយ៉ាងខ្ជាប់ខ្ជួន ដើម្បីក្លាយជាអ្នកដឹកនាំនាពេលអនាគត នៅក្នុងធនាគារ។

# អំពីភាពជោគជ័យ **របស់អតិថិជន**

”

**នៅមុនពេលទទួលបានកម្ចីពីធនាគារ អ៊ូរី អាជីវកម្មរបស់ខ្ញុំមានចំណូលនិងដើមទុនមានកម្រិត ប៉ុន្តែឥឡូវនេះ អាជីវកម្មខ្ញុំមិនត្រឹមតែអាចបន្តរស់រាននោះទេ ប៉ុន្តែអាចរីកចម្រើនជាងមុនទៀតផង**

”

## អ្នកស្រី ឌី អ៊ី

ម្ចាស់ហាងបង្អែម និងលក់គ្រឿងទេស ក្រុងតាខ្មៅ ខេត្តកណ្ដាល

នាងខ្ញុំឈ្មោះ ឌី អ៊ី មានអាយុ 38ឆ្នាំ ជាម្ដាយមានកូនតូចពីរនាក់ និងជាម្ចាស់ហាងបង្អែមខ្មែរ និងហាងលក់គ្រឿងទេសមួយកន្លែងនៅក្រុងតាខ្មៅ ខេត្តកណ្ដាល។ ធនាគារ អ៊ូរី គឺបានជួយគាំទ្រក្នុងដំណើរខ្សែជីវិតខ្ញុំរហូតមក។ ប្រាក់កម្ចីពីធនាគារ អ៊ូរី បានផ្ដល់ការគាំទ្រផ្នែកហិរញ្ញវត្ថុចាំបាច់នៅដំណាក់កាលផ្សេងៗគ្នាដំណាលគ្នានឹងកំណើនអាជីវកម្មរបស់ខ្ញុំ។ ប្រាក់កម្ចីដំបូងចំនួន $24,000 បានជួយខ្ញុំសាងសង់ផ្ទះរបស់ខ្ញុំ បន្ទាប់មកប្រាក់កម្ចីចំនួន $35,000 ដើម្បីពង្រីកហាងលក់គ្រឿងទេសរបស់ខ្ញុំ និងចុងក្រោយចំនួន $65,000 ដើម្បីបន្ថែមដើមទុន និងប្រែក្លាយហាងលក់គ្រឿងទេសទៅជាហាងបោះដុំ និងលក់រាយ។ នៅមុនពេលទទួលបានកម្ចីពីធនាគារ អ៊ូរី អាជីវកម្មរបស់ខ្ញុំមានចំណូល និងដើមទុនមានកម្រិត ប៉ុន្តែឥឡូវនេះ អាជីវកម្មខ្ញុំមិនត្រឹមតែអាចបន្តរស់រាននោះទេ ប៉ុន្តែអាចរីកចម្រើនជាងមុនទៀតផង។

ធនាគារ អ៊ូរី បានដើរតួយ៉ាងសំខាន់ក្នុងភាពជោគជ័យនៃអាជីវកម្មរបស់ខ្ញុំ។ តាមរយៈការផ្ដល់ប្រាក់កម្ចី បានអនុញ្ញាតឱ្យខ្ញុំបំពេញតម្រូវការរបស់អតិថិជន និងពង្រីកប្រតិបត្តិការរបស់ខ្ញុំកាន់តែធំឡើង។ ខ្ញុំពេញចិត្តចំពោះសេវាកម្មដ៏រហ័ស និងងាយស្រួលរបស់ពួកគេ ដែលធ្វើឱ្យដំណើរការខ្ចីប្រាក់មិនមានការស្មុគស្មាញ។ ជាមួយនឹងការគាំទ្ររបស់ធនាគារ អ៊ូរី អាជីវកម្មរបស់ខ្ញុំបានរីកចម្រើនយ៉ាងខ្លាំង។ ថ្ងៃនេះខ្ញុំមានមោទនភាពដែលខ្ញុំអាចមានលទ្ធភាពទិញរថយន្តសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនដើម្បីសម្រួលដល់ការរស់នៅកាន់តែប្រសើរ។

ប្រសិនបើអ្នកកំពុងស្វែងរកធនាគារដែលអាចទុកចិត្តបានជាមួយនឹងសេវាកម្មកម្ចីដ៏ល្អ សូមកុំរំលងធនាគារ អ៊ូរី ។ ការផ្ដល់សេវាកម្មប្រកបដោយវិជ្ជាជីវៈ និងការយកចិត្តទុកដាក់ និងការបំពេញចិត្តរបស់អតិថិជនគឺគួរឱ្យកោតសរសើរ។ ខ្ញុំក៏បានណែនាំពួកគេដល់មិត្តភ័ក្តិ និងក្រុមគ្រួសាររួចហើយ ហើយខ្ញុំលើកទឹកចិត្តអ្នកផ្សេងទៀតឱ្យស្វែងរកការទទួលសេវាពីធនាគារ អ៊ូរី ផងដែរ។

សូមអរគុណ ធនាគារ អ៊ូរី ដែលជឿជាក់ និងគាំទ្រលើអាជីវកម្មខ្នាតតូចដូចខ្ញុំ និងផ្ដល់ការគាំទ្រចាំបាច់សម្រាប់ការរីកចម្រើន និងជោគជ័យ។ ជំនួយរបស់អ្នកបានធ្វើឱ្យមានភាពខុសប្លែកគ្នាយ៉ាងខ្លាំងនៅក្នុងជីវិត និងអាជីវកម្មរបស់ខ្ញុំ ។

”

**ជាមួយនឹងប្រាក់កម្ចីដែលយើងទទួលបាន យើងអាចបញ្ចូលដើមទុនដែលត្រូវការច្រើនទៅក្នុងប្រតិបត្តិការរបស់យើង**

”

## លោក អន សារ៉ាត់

ម្ចាស់ឱសថស្ថានមួយកន្លែងនៅខេត្តមណ្ឌលគីរី

ខ្ញុំឈ្មោះ អន សារ៉ាត់ អាយុ42ឆ្នាំ ជាមួយភរិយារបស់ខ្ញុំឈ្មោះ ឈិត ចាន់ណេ អាយុ 35ឆ្នាំ យើងជាម្ចាស់ឱសថស្ថាន និងគ្លីនិកតូចមួយ ដើម្បីផ្ដល់សេវាកម្មដល់សហគមន៍នៅភូមិពូឡោះ ឃុំដាក់ដាំ ស្រុកអូរាំង ខេត្តមណ្ឌលគិរី ។ មុនពេលយើងទទួលបានជំនួយហិរញ្ញវត្ថុពី ធនាគារ អ៊ូរី អាជីវកម្មរបស់យើងបានប្រឈមមុខនឹងបញ្ហាជាច្រើន ការផ្គត់ផ្គង់ថ្នាំសង្កូវ និងឧបករណ៍ព្យាបាលមិនគ្រប់គ្រាន់ ដែលធ្វើឱ្យយើងមិនអាចបំពេញតម្រូវការថែទាំសុខភាពរបស់អតិថិជនបានពេញលេញ។

សូមអរគុណចំពោះការគាំទ្រពី ធនាគារ អ៊ូរី ដែលបានធ្វើឱ្យអាជីវកម្មរបស់យើងមានការផ្លាស់ប្ដូរគួរឱ្យកត់សម្គាល់។ ជាមួយនឹងប្រាក់កម្ចីដែលយើងទទួលបាន យើងអាចបញ្ចូលដើមទុនដែលត្រូវការច្រើនទៅក្នុងប្រតិបត្តិការរបស់យើង។ យើងបានបន្ថែមថ្នាំសង្កូវ និងឧបករណ៍ព្យាបាលកាន់តែសម្បូរបែប ដោយធានាថាយើងអាចផ្ដល់សេវាថែទាំសុខភាពកាន់តែទូលំទូលាយដល់សហគមន៍។ ជាងនេះទៅទៀត ប្រាក់កម្ចីមួយផ្នែកត្រូវបានប្រើប្រាស់ដើម្បីទិញរថយន្តភីកអាប់ ក្នុងការសម្រួលដល់ការដឹកជញ្ជូនថ្នាំ និងការផ្គត់ផ្គង់ និងបង្កើនប្រសិទ្ធភាពនៃអាជីវកម្ម។

ការជ្រើសរើសធនាគារ អ៊ូរី គឺជាការសម្រេចចិត្តដ៏ត្រឹមត្រូវលើការផ្ដល់ដំណោះស្រាយហិរញ្ញវត្ថុលឿន និងរហ័ស។ ចាប់ពីពេលដែលយើងបានដាក់ពាក្យស្នើសុំរបស់យើងដំណើរការគឺរហ័ស និងងាយស្រួល។ បុគ្គលិករបស់ធនាគារមានជំនាញខាងជំនាញ និងរួសរាយរាក់ទាក់ និងឱ្យតម្លៃអតិថិជនយ៉ាងខ្លាំង។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះធនាគារ អ៊ូរី សម្រាប់ការគាំទ្រ និងការសម្របសម្រួលអាជីវកម្មខ្នាតតូចដូចពួកយើងឱ្យរីកចម្រើន។ ជាមួយដំណើរឆ្ពោះទៅរកសហគ្រិនភាពរបស់យើង ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមការងារទាំងអស់នៅ ធនាគារ អ៊ូរី និងសូមជូនពរឱ្យពួកគេបន្តជោគជ័យជាបន្តទៀត ។

ផលិតផល
ហិរញ្ញវត្ថុ
និងសេវាកម្ម
សេវា
ប្រាក់សន្សំ
សេវា
ឥណទាន
សេវា
ផ្ទេរប្រាក់
ផលិតផលហិរញ្ញប្បទាន
ពាណិជ្ជកម្មអន្តរជាតិ
សេវាធនាគារ
ឌីជីថល
ATM
សេវាអេធីអឹម
និងប័ណ្ណឥណពន្ធ
សេវាធនាគារ
ផ្សេងៗទៀត

# សេវាប្រាក់សន្សំ

## គណនីសង្ឃឹម

គណនីសង្ឃឹម គឺជាប្រភេទគណនីសន្សំស្មគ្រ័ចិត្ត ដែលបង្កើតសម្រាប់ សហគ្រិន បុគ្គលិកក្រុមហ៊ុន ស្ត្រីមេផ្ទះ ដែលមានបំណងដាក់ប្រាក់សន្សំ របស់ពួកគេ ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយ ដែលគួរឱ្យជឿទុកចិត្ត និងមានសុវត្ថិភាពខ្ពស់។

| | |
|---|---|
| រូបិយប័ណ្ណ | រៀល, ដុល្លារ និងថៃបាត |
| សមតុល្យគណនីអប្បបរមា | 20,000 រៀល |
| | 5 ដុល្លារ |
| | 200 បាត |
| រយៈពេល | មិនកំណត់ |

## គណនីសន្សំថ្លឹស

គណនីសន្សំផ្លឹស គឺជាប្រភេទផលិតផលគណនីសន្សំថ្មីមួយទៀត របស់ធនាគារ អ៊ូរី ដែលត្រូវបានបង្កើតឡើង ដើម្បីផ្តល់ជូនអតិថិជន នូវភាពបត់បែនក្នុងការដកប្រាក់ និងដាក់ប្រាក់ ទៅតាមលំហូរ សាច់ប្រាក់យ៉ាងទាក់ទាញ ទៅតាមទំហំទឹកប្រាក់របស់អតិថិជនផងដែរ។

| | |
|---|---|
| រូបិយប័ណ្ណ | រៀល, ដុល្លារ និងថៃបាត |
| សមតុល្យគណនីអប្បបរមា | 400,000 រៀល |
| | 100 ដុល្លារ |
| | 4,000 បាត |
| រយៈពេល | មិនកំណត់ |

## គណនីរហ័ស

គណនីរហ័ស គឺជាផលិតផលបញ្ញើសន្សំមួយប្រភេទ ដែលត្រូវបានបង្កើតឡើងដើម្បីគាំទ្រប្រតិបត្តិការអាជីវកម្ម ដែលអនុញ្ញាតឱ្យអតិថិជនបើកគណនីថ្មីតាមរយៈធនាគារចល័ត (WOORI BANK Mobile)។ គណនីរហ័ស បានផ្តល់នូវភាពងាយស្រួល ក្នុងការទាក់ទាញអតិថិជនថ្មីឱ្យប្រើប្រាស់សេវាកម្មរបស់ ធនាគារ អ៊ូរី ។

| | |
|---|---|
| រូបិយប័ណ្ណ | រៀល, ដុល្លារ |
| សមតុល្យគណនីអប្បបរមា | 0 រៀល |
| | 0 ដុល្លារ |
| រយៈពេល | មិនកំណត់ |

## គណនីបឋមវ័យ

គណនីបឋមវ័យ គឺជាគណនីបញ្ញើសន្សំមួយប្រភេទដែលត្រូវបានបង្កើតឡើងសម្រាប់ក្មេងដែលមានអាយុចាប់ពី 10 ដល់ 17ឆ្នាំ អាចបើកគណនីជាមួយធនាគារ អ៊ូរី និងអនុញ្ញាតឱ្យធ្វើប្រតិបត្តិការហិរញ្ញវត្ថុមួយចំនួនតាមរយៈសេវាធនាគារចល័តរបស់ធនាគារ អ៊ូរី ដែលរាល់ការធ្វើប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់ស្ថិតនៅក្រោមការគ្រប់គ្រងពីសំណាក់ឪពុកម្តាយ ឬអាណាព្យាបាលរបស់ពួកគេ។

| | |
|---|---|
| រូបិយប័ណ្ណ | រៀល, ដុល្លារ |
| សមតុល្យគណនីអប្បបរមា | 0 រៀល |
| | 0 ដុល្លារ |
| រយៈពេល | រហូតដល់កុមារមានអាយុ 18ឆ្នាំ |



## គណនីកូនល្អ

គណនីកូនល្អ គឺជាប្រភេទគណនីសន្សំមានកាលកំណត់ថ្មីមួយទៀត ដែលបង្កើតឡើង ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ឪពុកម្តាយ ឬសាច់ញាតិ ដែលមានបំណងសន្សំប្រាក់សម្រាប់កូនៗរបស់ពួកគេ ដែលមាន អាយុក្រោម 18ឆ្នាំ។

| | |
|---|---|
| រូបិយប័ណ្ណ | រៀល, ដុល្លារ |
| សមតុល្យគណនីអប្បបរមា | 20,000 រៀល |
| | 5 ដុល្លារ |
| រយៈពេល | រហូតដល់កុមារមានអាយុ 18ឆ្នាំ |

## គណនីចម្រើនទ្រព្យ

គណនីចម្រើនទ្រព្យ គឺជាប្រភេទគណនីសន្សំ ដែលទទួលបានអត្រាការប្រាក់ ខ្ពស់ និងមានលក្ខណៈជាកិច្ចសន្យាដែលតម្រូវឱ្យរក្សាទុកនូវសមតុល្យ គណនី ក្នុងរយៈពេលកំណត់ជាក់លាក់មួយរហូតដល់កាលបរិច្ឆេទកំណត់។

| | |
|---|---|
| រូបិយប័ណ្ណ | រៀល, ដុល្លារ និងថៃបាត |
| ការដាក់ប្រាក់តម្កល់ដំបូង | 100,000 រៀល |
| | 25 ដុល្លារ |
| | 1,000 បាត |
| រយៈពេល | 1- 36 ខែ |

## គណនីសប្បុរស

គណនីសប្បុរស គឺជាប្រភេទគណនីមានកាលកំណត់មួយទៀត ដែលមានរួមបញ្ចូលកម្មវិធីសប្បុរសធម៌ ឬកម្មវិធីជួយសង្គម។ តាមរយៈផលិតផលថ្មីនេះ អតិថិជនអាចជ្រើសរើសអង្គការសប្បុរសធម៌ដែលខ្លួនពេញចិត្តដើម្បីបរិច្ចាគ។ នៅថ្ងៃកាលបរិច្ឆេទកំណត់ អតិថិជននឹងទទួលបានការប្រាក់គោល ហើយចំនួនទឹកប្រាក់ដែលត្រូវបរិច្ចាគនឹងត្រូវបានកាត់ចេញពីការប្រាក់ដែលទទួលបាន រួចផ្ទេរទៅគណនីរបស់អង្គការសប្បុរសធម៌ដែលបានជ្រើសរើសដោយបង្ហាញឈ្មោះរបស់អតិថិជន។

| | |
|---|---|
| រូបិយប័ណ្ណ | រៀល, ដុល្លារ |
| ការដាក់ប្រាក់តម្កល់ដំបូង | 100,000 រៀល |
| | 25 ដុល្លារ |
| រយៈពេល | 3 ទៅ 12 ខែ |

## គណនីសន្សំតាមផែនការ

គណនីសន្សំតាមផែនការ គឺជាប្រភេទផលិតផលដាក់ប្រាក់បញ្ញើប្រចាំខែ ដែលតម្រូវឱ្យមានការដាក់ប្រាក់ចូលក្នុងគណនីនូវចំនួនស្មើៗគ្នាជារៀងរាល់ខែ។ គណនីនេះត្រូវបានបង្កើតឡើងសម្រាប់អតិថិជនដែលមានចំណូលទៀងទាត់ និងមានបំណងជ្រើសរើសវិធីសាស្ត្រសន្សំបង្គរសម្រាប់ការវិនិយោគ ឬតម្រូវការអនាគតដូចជា វិនិយោគក្នុងអាជីវកម្ម ទិញសម្ភារ ឬ ផែនការចូលនិវត្តន៍ ជាដើម។

| | |
|---|---|
| រូបិយប័ណ្ណ | រៀល, ដុល្លារ |
| ការដាក់ប្រាក់តម្កល់ដំបូង | 40,000 រៀល |
| | 10 ដុល្លារ |
| រយៈពេល | 3 ទៅ 36 ខែ |

## គណនីសន្សំតាមផែនការ ផ្លឹស

គណនីសន្សំតាមផែនការ ផ្លឹស គឺជាប្រភេទផលិតផលដាក់ប្រាក់ បញ្ញើប្រចាំខែថ្មីមួយទៀត ដែលមានភាពបត់បែនលើការដាក់ប្រាក់។ មានន័យថាអតិថិជនអាចដាក់ប្រាក់បន្ថែមលើចំនួនទឹកប្រាក់ដែល បានកំណត់នៅក្នុងតារាង កាលវិភាគដាក់ប្រាក់សន្សំក្នុងអំឡុង ពេលកិច្ចសន្យា។

| | |
|---|---|
| រូបិយប័ណ្ណ | រៀល, ដុល្លារ |
| ការដាក់ប្រាក់តម្កល់ដំបូង | 20,000 រៀល |
| | 5 ដុល្លារ |
| រយៈពេល | 3 ទៅ 36 ខែ |












# សេវាឥណទាន

## ឥណទានអាជីវកម្ម

ឥណទានអាជីវកម្ម គឺជាឥណទានដែលត្រូវបានប្រើប្រាស់សម្រាប់ជាទុនបង្វិល ដើមទុនវិនិយោគសម្រាប់អាជីវកម្ម ការទិញទ្រព្យអាជីវកម្ម ការជួញដូរអាជីវកម្ម រួមបញ្ចូលទាំង ការជួញដូរផ្នែកកសិកម្ម និងប្រើប្រាស់ផងដែរសម្រាប់សកម្មភាពរកប្រាក់ចំណូលដែលទទួលផលចំណូលជាប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ជារៀងរាល់2សប្តាហ៍ ឬ ប្រចាំខែ។

| | |
|---|---|
| រូបិយប័ណ្ណ | រៀល, ដុល្លារ និងថៃបាត |
| ទំហំឥណទាន | ចាប់ពី 400,000 ដល់ 400,000,000 រៀល |
| | ចាប់ពី 100 ដល់ 100,000 ដុល្លារ |
| | ចាប់ពី 4,000 ដល់ 400,000 បាត |
| រយៈពេលកម្ចី | 03 - 84 ខែ |

## ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន

ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន គឺជាឥណទានដែលត្រូវបានប្រើប្រាស់សម្រាប់ទិញសម្ភារប្រើប្រាស់ផ្ទាល់ខ្លួន ឬទ្រព្យសម្បត្តិគ្រួសារ ក៏ដូចជាផ្តល់ហិរញ្ញប្បទានសម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ ក្នុងគោលបំណងធ្វើឱ្យជីវភាពរស់នៅជាមូលដ្ឋានមានភាពល្អប្រសើរ។

| | |
|---|---|
| រូបិយប័ណ្ណ | រៀល, ដុល្លារ និងថៃបាត |
| ទំហំឥណទាន | ចាប់ពី 400,000 ដល់ 200,000,000 រៀល |
| | ចាប់ពី 100 ដល់ 50,000 ដុល្លារ |
| | ចាប់ពី 4,000 ដល់ 400,000 បាត |
| រយៈពេលកម្ចី | 03 – 72 ខែ |

## ឥណទានកសិកម្ម

ឥណទានកសិកម្ម គឺជាឥណទានដែលត្រូវបានប្រើប្រាស់សម្រាប់ការចំណាយលើវត្ថុធាតុដើម ទ្រព្យសកម្មនៃអាជីវកម្មកសិកម្ម ឬសកម្មភាពរកប្រាក់ចំណូលទាំងឡាយដែលទទួលផលចំណូលតាមរដូវកាល ដូចជា ការដាំដំណាំ ការចិញ្ចឹមសត្វ។ល។

| | |
|---|---|
| រូបិយប័ណ្ណ | រៀល ដុល្លារ និងថៃបាត |
| ទំហំឥណទាន | ចាប់ពី 400,000 ដល់ 200,000,000 រៀល |
| | ចាប់ពី 100 ដល់ 50,000 ដុល្លារ |
| | ចាប់ពី 4,000 ដល់ 400,000 បាត |
| រយៈពេលកម្ចី | 03 - 72 ខែ |

## ឥណទានការសិក្សា

ឥណទានការសិក្សា គឺជាប្រភេទឥណទានផលិតផលសង្គម ដែលត្រូវបានប្រើប្រាស់សម្រាប់ជាជំនួយផ្នែកហិរញ្ញវត្ថុដល់បុគ្គលឬឪពុកម្ដាយ/អាណាព្យាបាល ដែលមានបំណងចង់ឱ្យកូនបានរៀនសូត្រនូវកម្មវិធីសិក្សាអប់រំចំណេះដឹងទូទៅ (ចាប់ពីថ្នាក់ទី1 ដល់ថ្នាក់ទី12) ឬ សម្រាប់បន្តការអប់រំជាន់ខ្ពស់ ឬ សិក្សាជំនាញវិជ្ជាជីវៈសម្រាប់ប្រកបរបរចិញ្ចឹមជីវិត។

| រូបិយប័ណ្ណ | រៀល, ដុល្លារ និងថៃបាត |
|---|---|
| ទំហំឥណទាន | ចាប់ពី 400,000 ដល់ 20,000,000 រៀល |
| | ចាប់ពី 100 ដល់ 5,000 ដុល្លារ |
| | ចាប់ពី 4,000 ដល់ 200,000 បាត |
| រយៈពេលកម្ចី | កម្រិតសិក្សាអប់រំចំណេះដឹងទូទៅ ៖ 03 - 12 ខែ |
| | កម្រិតបរិញ្ញាបត្ររង ៖ 03 - 48 ខែ |
| | កម្រិតបរិញ្ញាបត្រ ៖ 03 - 84 ខែ |
| | កម្រិតអនុបណ្ឌិត ៖ 03 - 48 ខែ |
| | វគ្គបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ ៖ 03 - 24 ខែ |

## ឥណទានគ្រាអាសន្ន

ឥណទានគ្រាអាសន្ន ជាប្រភេទឥណទានផលិតផលសង្គម ដែលត្រូវបានប្រើប្រាស់ដើម្បីធានាបាននូវការឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការហិរញ្ញវត្ថុរបស់អតិថិជន នៅក្នុងពេលមានហេតុការណ៍បន្ទាន់ និង/ឬព្រឹត្តិការណ៍ដែលមិនអាចគិតទុកជាមុន ទាំងគ្រោះធម្មជាតិ ឬ គ្រោះថ្នាក់ផ្ទាល់ខ្លួន។

| រូបិយប័ណ្ណ | រៀល, ដុល្លារ និងថៃបាត |
|---|---|
| ទំហំឥណទាន | ចាប់ពី 400,000 ដល់ 4,000,000 រៀល |
| | ចាប់ពី 100 ដល់ 1,000 ដុល្លារ |
| | ចាប់ពី 4,000 ដល់ 40,000 បាត |
| រយៈពេលកម្ចី | 03 - 24 ខែ |

## ឥណទានកូនកាត់ពិសេស

ឥណទានកូនកាត់ពិសេស គឺសំដៅទៅលើឥណទានដែលមានរបៀបបង់សងពិសេស ដែល50% នៃកម្ចីសរុប អាចរក្សាទុកបង់សងនៅចុងវគ្គ និង50%ទៀត ត្រូវបង់សងរំលស់ប្រាក់ដើមប្រចាំខែ។

| រូបិយប័ណ្ណ | រៀល ដុល្លារ និងថៃបាត |
|---|---|
| ទំហំឥណទាន | ចាប់ពី 400,000 ដល់ 400,000,000 រៀល |
| | ចាប់ពី 100 ដល់ 100,000 ដុល្លារ |
| | ចាប់ពី 4,000 ដល់ 400,000 បាត |
| រយៈពេលកម្ចី | 03 - 60 ខែ |

## ឥណទានសហគ្រាសខ្នាតតូច និងមធ្យម

ឥណទានសហគ្រាសខ្នាតតូច និងមធ្យម ត្រូវបានទទួលស្គាល់ថាជាឥណទានសម្រាប់សហគ្រាសធុនតូច និងមធ្យម ដែលត្រូវការហិរញ្ញវត្ថុដើម្បីទ្រទ្រង់ដល់ការចំណាយទូទាត់រយៈពេលខ្លី ឬដើមទុនទ្រទ្រង់ប្រតិបត្តិការអាជីវកម្ម និងការវិនិយោគ។

| រូបិយប័ណ្ណ | រៀល និងដុល្លារ |
|---|---|
| ទំហំឥណទាន | ធំជាង 100,000 ដល់ 5,000,000 ដុល្លារ ឬ ធំជាង 400,000,000 ដល់ 20,000,000,000 រៀល |
| រយៈពេលកម្ចី | 03 - 120 ខែ |
| អត្រាការប្រាក់ប្រចាំឆ្នាំ | អត្រាការប្រាក់ប្រកួតប្រជែង |
| របៀបបង់សង | ជម្រើសនៃការបង់សងបត់បែន |
| ទ្រព្យធានាដែលអាចទទួលយកបាន | • គ្រប់ប្រភេទអចលនវត្ថុទាំងអស់ដែលមានទីតាំងគ្រប់កន្លែងក្នុងរាជធានីភ្នំពេញ និងគ្រប់បណ្ដាខេត្ត/ក្រុង<br>• គណនីមានកាលកំណត់របស់ធនាគារអ៊ូរី<br>• ការធានាដោយភាគីទី3<br>• ប័ណ្ណធានាពីធនាគារ |

## ឥណទានសាជីវកម្ម

ឥណទានសាជីវកម្ម គឺជាឥណទានដែលផ្ដល់ឱ្យនីតិបុគ្គល/ក្រុមហ៊ុន/សហគ្រាសខ្នាតធំ ដែលត្រូវការហិរញ្ញវត្ថុដើម្បីទ្រទ្រង់ដល់ការចំណាយទូទាត់រយៈពេលខ្លី ឬដើមទុនទ្រទ្រង់ប្រតិបត្តិការអាជីវកម្ម និងការវិនិយោគ។

| រូបិយប័ណ្ណ | រៀល និងដុល្លារ |
|---|---|
| ទំហំឥណទាន | ធំជាង 100,000 ដល់ 5,000,000 ដុល្លារ ឬ ធំជាង 400,000,000 ដល់ 20,000,000,000 រៀល |
| រយៈពេល | 03 - 120 ខែ |
| អត្រាការប្រាក់ប្រចាំឆ្នាំ | អត្រាការប្រាក់ប្រកួតប្រជែង |
| របៀបបង់សង | ជម្រើសនៃការបង់សងបត់បែន |
| ទ្រព្យធានាដែលអាចទទួលយកបាន | • គ្រប់ប្រភេទអចលនវត្ថុទាំងអស់ដែលមានទីតាំងគ្រប់កន្លែងក្នុងរាជធានីភ្នំពេញ និងគ្រប់បណ្ដាខេត្ត/ក្រុង។<br>• គណនីមានកាលកំណត់របស់ធនាគារអ៊ូរី។<br>• ការធានាដោយភាគីទី3។<br>• ប័ណ្ណធានាពីធនាគារ។ |

## កម្ចីសម្រាប់និយោជិតធ្វើការក្រៅប្រទេស

កម្ចីសម្រាប់និយោជិតធ្វើការក្រៅប្រទេស គឺជាទម្រង់នៃកម្ចីមានកាលកំណត់ដែលមិនមានទ្រព្យធានា ដែលផ្ដល់ជូនសម្រាប់គ្រប់និយោជិត/ពលករខ្មែរទាំងអស់ដែលទទួលបានការងារពេញលេញនៅឯក្រៅប្រទេស។

| រូបិយប័ណ្ណ | រៀល និងដុល្លារ |
|---|---|
| ទំហំឥណទាន | ចាប់ពី 400,000 ដល់ 8,000,000 រៀល |
| | ចាប់ពី 100 ដល់ 2,000 ដុល្លារ |
| រយៈពេលកម្ចី | 03 - 36 ខែ |
| ទ្រព្យធានា | មិនតម្រូវឱ្យដាក់ទ្រព្យធានា |

## ឥណទានគេហដ្ឋាន

ឥណទានគេហដ្ឋាន គឺជាប្រភេទឥណទានដែលត្រូវបានប្រើប្រាស់សម្រាប់ទិញ/សាងសង់ផ្ទះថ្មី ឬ កែលម្អផ្ទះដែលមានស្រាប់ ឬ ពង្រីក និងជួសជុលផ្ទះដែលមានស្រាប់។ ឥណទាននេះ ក៏អាចប្រើប្រាស់សម្រាប់ការទិញដីដើម្បីសាងសង់ផ្ទះផងដែរ។

| រូបិយប័ណ្ណ | រៀល, ដុល្លារ និងថៃបាត |
|---|---|
| ទំហំឥណទាន | ចាប់ពី 400,000 ដល់ 400,000,000 រៀល |
| | ចាប់ពី 100 ដល់ 100,000 ដុល្លារ |
| | ចាប់ពី 4,000 ដល់ 400,000 បាត |
| រយៈពេលកម្ចី | 03 – 120 ខែ |

# សេវាផ្ទេរប្រាក់

## សេវាផ្ទេរប្រាក់អន្តរធនាគារ

សេវាផ្ទេរប្រាក់អន្តរធនាគារ (FAST) គឺជាប្រភេទសេវាផ្ទេរប្រាក់ដែលធ្វើប្រតិបត្តិការរវាងស្ថាប័នហិរញ្ញវត្ថុ (ធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ) ដើម្បីផ្តល់សេវា ដែលមានភាពងាយស្រួល និងទាន់ពេលវេលាដល់អតិថិជន ជាមួយនឹងគោលបំណងនៃការផ្ញើប្រាក់ទៅកាន់គណនីអ្នកទទួល។

| ចំនួនទឹកប្រាក់ផ្ទេរ (ជាប្រាក់រៀល) | តម្លៃសេវា (ជាប្រាក់រៀល) |
|---|---|
| ≤ 4 លាន | 4,000 |
| > 4 លាន ដល់ 20 លាន | 8,000 |
| > 20 លាន ដល់ 40 លាន | 12,000 |

## ការផ្ទេរប្រាក់ឆ្លងសាខា

សេវាផ្ទេរប្រាក់ឆ្លងសាខា គឺជាប្រភេទសេវាផ្ទេរប្រាក់ដែលអតិថិជនអាចប្រើដើម្បីផ្ទេរប្រាក់ពីសាខាមួយ ទៅសាខាមួយទៀតរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ។ អតិថិជនអាចធ្វើការផ្ទេរ ឬទទួលប្រាក់នៅសាខាតែមួយ ឬសាខាផ្សេងទៅតាមការស្នើសុំរបស់អតិថិជន។

| ប្រភេទប្រតិបត្តិការ | សាច់ប្រាក់ទៅសាច់ប្រាក់ ឬ ពីគណនីទៅសាច់ប្រាក់ | | | សាច់ប្រាក់ទៅគណនី ឬ ពីគណនីទៅគណនី | | |
|---|---|---|---|---|---|---|
| រូបិយប័ណ្ណ | រៀល | ដុល្លារ | ថៃបាត | រៀល | ដុល្លារ | ថៃបាត |
| អត្រាកម្រៃសេវា | 0.10% | 0.10% | 0.10% | 0.08% | 0.08% | 0.08% |
| កម្រៃសេវាអប្បបរមា | 4,000 | 1 | 40 | 3,000 | 1 | 40 |

## ការផ្ទេរប្រាក់អន្តរជាតិ

### សេវាផ្ទេរប្រាក់ពីក្រៅប្រទេស

ការទទួលប្រាក់ដែលផ្ទេរចូលមកក្នុងប្រទេសតាមរយៈធនាគារ អ៊ូរី (ខេមបូឌា) ម.ក មានភាពឆាប់រហ័ស សុវត្ថិភាព និងមានភាពងាយស្រួល។ អតិថិជនដែលមានគណនីសន្សំជាមួយ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក អាចទទួលបានទឹកប្រាក់ដែលផ្ទេរចូលមកក្នុងប្រទេស ជាមួយនឹងភាពងាយស្រួលបន្ថែមទៀតដែលអាចឆែកទឹកប្រាក់ដែលផ្ទេរចូល និងសមតុល្យទឹកប្រាក់ក្នុងគណនី តាមរយៈកម្មវិធីធនាគារចល័តក្នុងទូរស័ព្ទដៃ ដែលផ្តល់ជូនដោយមិនគិតថ្លៃ ។ ពិសេសជាងនេះទៀត អតិថិជននិងទទួលបានកម្រៃសេវាផ្ទេរប្រាក់ចូលមកក្នុងប្រទេសទាបជាងគេ។



| ប្រភេទព័ត៌មាន | ព័ត៌មានដែលត្រូវបំពេញ |
|---|---|
| រូបិយប័ណ្ណ | ដុល្លារអាមេរិក និងថៃបាត |
| អ្នកទទួល | តាមរយៈគណនីទទួលទៅ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក |
| ព័ត៌មានរបស់អ្នកទទួល | ឈ្មោះអ្នកទទួល, លេខគណនីអ្នកទទួល, អាសយដ្ឋានអ្នកទទួល, ឈ្មោះធនាគារអ្នកទទួល, អាសយដ្ឋានធនាគារអ្នកទទួល, និងSWIFT កូដនៃធនាគារ អ៊ូរី (ខេមបូឌា) ម.ក (KVBKKHPP) |

| កម្រៃសេវាផ្ទេរប្រាក់ចូល | |
|---|---|
| គ្រប់ទំហំទឹកប្រាក់នៃប្រតិបត្តិការ | 0.07% នៃចំនួនទឹកប្រាក់ដែលទទួល ឬ អប្បបរមា 10ដុល្លារ |

### សេវាផ្ទេរប្រាក់ទៅក្រៅប្រទេស

ជាមួយវិសាលភាពនៃបណ្តាញធនាគារដ៏ធំធេងនៅជុំវិញពិភពលោករបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក អតិថិជនអាចផ្ទេរប្រាក់ទៅប្រទេសជាច្រើននៅលើពិភពលោកតាមរយៈប្រព័ន្ធ SWIFT ដែលជាប្រព័ន្ធសុវត្ថិភាពមួយដែលធនាគារលំដាប់ថ្នាក់ពិភពលោកបានប្រើប្រាស់ក្នុងការផ្ទេរប្រាក់ជាលក្ខណៈអន្តរជាតិ។ អតិថិជនអាចផ្ញើប្រាក់អោយក្រុមគ្រួសារ ទូទាត់ថ្លៃទំនិញ និងគោលបំណងផ្សេងទៀតនៅគ្រប់ 140សាខារបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក។

| លក្ខណៈពិសេស | |
|---|---|
| **រូបិយប័ណ្ណ** | ដុល្លារអាមេរិក ថៃបាត កូរ៉េន អឺរ៉ូ ដុល្លារអូស្ត្រាលី ដុល្លារសាំងហ្គាពួរ ម៉ាឡេស៊ីរីងហ្គិត យ៉ុនចិន យ៉េនជប៉ុន |
| **អ្នកផ្ទេរ** | អនុវត្តចំពោះអតិថិជនដែលមានគណនីជាមួយធនាគារ អ៊ូរី (ខេមបូឌា) ម.ក តែប៉ុណ្ណោះ |
| **ព័ត៌មានរបស់អ្នកទទួល** | អ្នកទទួលផល, លេខគណនីអ្នកទទួលផល, អាសយដ្ឋានអ្នកទទួលផល, ឈ្មោះធនាគារអ្នកទទួលផល, អាសយដ្ឋានធនាគារអ្នកទទួលផល, និង SWIFT កូដនៃធនាគារទទួលផល |

| សេវាផ្ទេរប្រាក់ចេញ | | | |
|---|---|---|---|
| **ចំនួនទឹកប្រាក់ (ដុល្លារ)** | **Telex** | **Commission Fee** | **OUR (FULLPAYFEE)** |
| **តិចជាង $1,000** | $10 | $5 | $20 |
| **ចាប់ពី $1,000 ដល់ក្រោម $10,000** | $10 | $10 | $20 |
| **ចាប់ពី $10,000** | $10 | 0.13% នៃចំនួនទឹកប្រាក់សរុប(ទាបបំផុត$10) | $20 |

# ផលិតផលហិរញ្ញប្បទានពាណិជ្ជកម្មអន្តរជាតិ

**ធនាគារ អ៊ូរី (ខេមបូឌា) ម.ក** បានផ្តល់ជូនលោកអ្នកនូវសេវាកម្ម លិខិតឥណទាន, សេវាប្រមូលឯកសារ, លិខិតធានា, STANDBY LETTER OF CREDIT ក៏ដូចជា ADVISING, NEGOTIATION ព្រមទាំងសេវាកម្មពាណិជ្ជកម្មអន្តរជាតិជាច្រើនទៀត។

**លិខិតឥណទាន** គឺជាប្រភេទផលិតផលមួយដែល ធនាគាររបស់អ្នកទិញទំនិញ (អ្នកនាំចូល) ទទួលខុសត្រូវលើការទូទាត់សងទៅកាន់អ្នកលក់ជំនួសមុខឱ្យអ្នកទិញទំនិញ ក្នុងករណីដែលប្រត្តិបត្តិការណ៍គោរពតាមគ្រប់លលក្ខខណ្ឌនៃលិខិតឥណទាន។ផលិតផលប្រភេទនេះគឺជាប្រភេទដែលមានសុវត្ថិភាពខ្ពស់បំផុតក្នុងការទូទាត់និងពេញនិយមក្នុងការប្រើប្រាស់ជាងគេក្នុងវិស័យហិរញ្ញប្បទានពាណិជ្ជកម្មអន្តរជាតិ។

**សេវាប្រមូលឯកសារ** គឺជាការទទួលខុសត្រូវមិនអាចកែប្រែបានរបស់ធនាគារ ចេញផ្សាយ (ហៅថាអ្នកធានា) លើការទូទាត់សងទៅកាន់អ្នកទទួលផលពីលិខិតធានា (ហៅថាអ្នកទទួលផល)ក្នុងករណីដែលអ្នកស្នើសុំមិនអាចបំពេញគ្រប់កាតព្វកិច្ចឬក៏បំពេញបានត្រឹមតែផ្នែកខ្លះៗ។

**លិខិតធានា** គឺជាវិធីសាស្រ្តមួយរបស់ហិរញ្ញវត្ថុពាណិជ្ជកម្ម នៅពេលដែលធនាគារអ្នកនាំចេញផ្ញើ នូវឯកសារពាក់ព័ន្ធទៅកាន់ធនាគាររបស់អ្នកនាំចូល ហើយធ្វើការប្រមូលការទូទាត់ពីការដឹកទំនិញនោះ។អ្នកទិញទំនិញអាចមានសិទ្ធិទទួលបានទំនិញក្នុងករណីដែលពួកគាត់បានទូទាត់ទំនិញរួច ឬក៏ឯកសារដែលពាក់ព័ន្ធត្រូវបានព្រមព្រៀងថាទូទាត់នៅក្នុងកាលបរិច្ឆេទណាមួយជាក់លាក់ ឬក៏លក្ខខណ្ឌណាមួយ។

# សេវាធនាគារ ឌីជីថល

សេវាធនាគារចល័ត គឺជាការផ្តល់ជូននូវសេវាធនាគារ ឬសេវាហិរញ្ញវត្ថុមួយ ជាមួយនឹងជំនួយទូរគមនាគមន៍ចល័ត ដែលអនុញ្ញាតអោយអតិថិជនធ្វើប្រតិបត្តិការធនាគារដោយខ្លួនឯងតាមរយៈឧបករណ៍ចល័តរបស់អតិថិជន។

## ការរចនាថ្មីនៃសេវាធនាគារចល័ត

ដើម្បីជួយជ្រោមជ្រែងទៅលើទីផ្សារប្រកួតប្រជែងនៃសេវាកម្មធនាគារចល័ត និងភាពងាយស្រួលទៅតាមតម្រូវការអតិថិជន សេវាកម្មធនាគារចល័តរបស់ពួកយើងតែងតែពង្រឹងបន្ថែមឥតឈប់ឈរ ក្នុងនោះរួមមាន៖

| # | មុខងារ | សេចក្តីរៀបរាប់លម្អិត |
|---|---|---|
| 1 | ទំព័រដើម | ឥលូវនេះ អ្នកប្រើប្រាស់អាចមើលគណនីសន្សំជាច្រើននៅលើទំព័រដើម ហើយថែមទាំងអាចកែប្រែមុខងារធនាគាររហ័សដែលអ្នកប្រើប្រាស់ចង់បាន |
| 2 | តារាងគណនី | អនុញ្ញាតឱ្យអ្នកប្រើប្រាស់ត្រួតពិនិត្យទៅលើចំនួនទឹកប្រាក់សរុប និងព័ត៌មានលម្អិតរបស់គណនីទាំងអស់យ៉ាងងាយស្រួល |
| 3 | KHQR | ការរចនាថ្មីរបស់ KHQR សមស្របតាមបទពិសោធន៍របស់អ្នកប្រើប្រាស់ |
| 4 | ទម្រង់ប្រតិបត្តិការហិរញ្ញវត្ថុ | ការរចនាថ្មីទៅលើទម្រង់ប្រតិបត្តិការទាំងអស់ដើម្បីងាយស្រួល និងបង្ហាញទិន្នន័យជាក់លាក់នៅពេលដែលប្រតិបត្តិការទទួលបានជោគជ័យ |
| 5 | ឧបករណ៍គណនា | ងាយស្រួលបំផុតដើម្បីមើលការគណនាទៅលើអត្រាប្តូរប្រាក់ ការទូទាត់កម្ចី ការដាក់ប្រាក់បញ្ញើមានកាលកំណត់ |
| 6 | ស្វែងរកពួកយើង និងប្រវត្តិរូប | រូបរាងថ្មីរបស់មុខងារ"ស្វែងរកពួកយើង" និងអនុញ្ញាតឱ្យអ្នកប្រើប្រាស់ត្រួតពិនិត្យមើលព័ត៌មានផ្ទាល់ខ្លួនបានក្នុងប្រវត្តិរូប |

## ការបន្ថែមមុខងារថ្មីនៃសេវាធនាគារចល័ត

ដោយស្របតាមទីផ្សារប្រកួតប្រជែង ក៏ដូចជាបំពេញតម្រូវការអតិថិជន សេវាកម្មធនាគារចល័តត្រូវបានអភិវឌ្ឍន៍ឥតឈប់ឈរ។ មុខងារទាំងនោះមានដូចជា៖

| # | មុខងារ | សេចក្តីរៀបរាប់លម្អិត |
|---|---|---|
| 1 | បើកគណនីរហ័ស តាមរយៈកម្មវិធីធនាគារចល័ត | ឥលូវនេះ អតិថិជនថ្មីទាំងអស់ អាចចុះឈ្មោះប្រើប្រាស់សេវាធនាគារចល័តបាន ដោយគ្រាន់តែធ្វើការទាញយកកម្មវិធីធនាគារចល័ត ហើយចាប់ផ្តើមធ្វើការបើកគណនីរហ័សបានដោយខ្លួនឯងគ្រប់ពេលវេលាគ្រប់ទីកន្លែងដោយមិនតម្រូវឱ្យអតិថិជនអញ្ជើញមកកាន់សាខាណាមួយរបស់ធនាគា អ៊ូរី ឡើយ។ |
| 2 | ពិនិត្យមើលគណនីសន្សំតាមផែនការផ្ញើស លើសេវាធនាគារចល័ត | អនុញ្ញាតឱ្យអតិថិជនពិនិត្យមើលព័ត៌មានលម្អិតនៃគណនីសន្សំតាមផែនការផ្ញើស នៅលើសេវាធនាគារចល័ត |
| 3 | បច្ចុប្បន្នភាពមាតិកាតេឡេក្រាម ឈ្មោះ និងរូបតំណាងកម្មវិធីថ្មី | យើងបានធ្វើបច្ចុប្បន្នភាពមាតិកាតេឡេក្រាមសម្រាប់ប្រតិបត្តិការទទួលបានប្រាក់ពីការទូទាត់វិក្កយបត្រតាមរយៈការស្កេនQR។<br>ក្រៅពីការធ្វើបច្ចុប្បន្នភាពមាតិកាតេឡេក្រាម ពួកយើងក៏បានធ្វើការផ្លាស់ប្តូរឈ្មោះ និងរូបតំណាងកម្មវិធីធនាគារចល័តថ្មីផងដែរ។ |
| 4 | កែលម្អការបំពេញ OTP ដោយដៃ | ដើម្បីភាពងាយស្រួល ការពារការក្លែងបន្លំ ក៏ដូចជាបន្ថែមសុវត្ថិភាពមួយកម្រិតទៀតនោះ ពួកយើងបានធ្វើការកែលម្អការបំពេញOTPដោយដៃទៅជាការបំពេញOTPដោយស្វ័យប្រវត្តិចំពោះប្រភេទទូរស័ព្ទដែលដំណើរការដោយប្រព័ន្ធ Android និង ណែនាំឱ្យចុចOTP នៅលើក្តារចុចចំពោះប្រភេទទូរស័ព្ទដែលដំណើរការដោយប្រព័ន្ធ iOS |
| 5 | បន្ថែមសេវាទូទាត់វិក្កយបត្រកម្សាន្តលើសេវាធនាគារចល័ត | បន្ថែមសេវាទូទាត់វិក្កយបត្រកម្សាន្តថ្មីនៅលើសេវាធនាគារចល័ត |
| 6 | បើកដំណើរការគណនីបឋមវ័យ តាមរយៈកម្មវិធីធនាគារចល័ត | អនុញ្ញាតឱ្យអតិថិជនដែលជាកុមារអាយុចន្លោះពី10 ទៅ17ឆ្នាំ ទទួលបានបទពិសោធន៍ក្នុងការប្រើប្រាស់សេវាធនាគារក្រោមការគ្រប់គ្រងរបស់ឪពុកម្តាយឬ អាណាព្យាបាលរបស់ពួកគេ ដោយគ្រាន់តែចាប់ផ្តើមជំហានងាយៗក្នុងការបើកដំណើរការគណនីបឋមវ័យរបស់គេតាមរយៈកម្មវិធីធនាគារចល័ត |
| 7 | បន្ថែមមុខងារសេវាផ្ទេរប្រាក់អន្តរជាតិ | បន្ថែមមុខងារសេវាផ្ទេរប្រាក់អន្តរជាតិថ្មីលើសេវាធនាគារចល័តដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ទទួលបានបទពិសោធន៍ថ្មីនៃការផ្ទេរប្រាក់ដែលមានភាពរហ័ស ងាយស្រួល ហើយអាចផ្ទេរប្រាក់ទៅប្រទេសជាច្រើននៅលើពិភពលោក ជាមួយកម្រៃសេវាសមរម្យ និងមានសុវត្ថិភាពខ្ពស់ |
| 8 | បន្ថែមទីតាំងសាខា និង ម៉ាស៊ីន ATMថ្មីក្នុងមុខងារស្វែងរកពួកយើង | យើងបានធ្វើការកែប្រែ រចនាបទ និងបទពិសោធន៍ថ្មីតាមរយៈការធ្វើបច្ចុប្បន្នភាពក៏ដូចជាបន្ថែមនូវទីតាំងសាខា និងម៉ាស៊ីនATM ថ្មី ទៅក្នុងមុខងារស្វែងរកពួកយើងដែលពិតជាផ្តល់ភាពងាយស្រួលជូនអតិថិជនក្នុងការស្វែងរកយើង |
| 9 | បន្ថែមមុខងារថ្មីណែនាំមិត្តភក្តិ ការជជែកផ្ទាល់ និងមុខងារផ្តល់មតិយោបល់ | ឥលូវនេះ អ្នកប្រើប្រាស់សេវាធនាគារចល័តអាចធ្វើការណែនាំមិត្តភក្តិ និងក្រុមគ្រួសារដើម្បីចុះឈ្មោះប្រើប្រាស់សេវាធនាគារចល័តរបស់ធនាគារ អ៊ូរី បានតាមរយៈមុខងារណែនាំមិត្តភក្តិ។ ម្យ៉ាងវិញទៀតនាពេលបច្ចុប្បន្ននេះ អ្នកប្រើប្រាស់ទាំងអស់ក៏ធ្វើការអាចជជែកដោយផ្ទាល់ទៅកាន់ផ្នែកសេវាបម្រើអតិថិជន ហើយអាចធ្វើការសាកសួរ ឬ បញ្ចេញមតិយោបល់មកកាន់ពួកយើងបាន តាមរយៈមុខងារថ្មីដែលមានឈ្មោះថា ការជជែកផ្ទាល់ និងផ្តល់មតិយោបល់ |

## សេវាទូទាត់បាគង

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក គឺជាសមាជិកក្នុងប្រព័ន្ធបាគង ហើយបច្ចុប្បន្ននេះ ធនាគារ អ៊ូរី បានបញ្ចូលកម្មវិធីបាគងចូលទៅក្នុង WOORI BANK Mobile ដែលអតិថិជនអាចប្រើប្រាស់ គណនីបាគង នៅលើ WOORI BANK Mobile ដោយភាពងាយស្រួល។

### អត្ថប្រយោជន៍នៃការប្រើប្រាស់បាគងនៅលើ WOORI BANK Mobile

- ការចុះឈ្មោះគណនីបាគងតាមរយៈ WOORI BANK Mobile
- ផ្ទេរ និងទទួលប្រាក់ភ្លាមៗប្រកបដោយសុវត្ថិភាពពីគណនីសន្សំធនាគារ អ៊ូរី ទៅកាន់គណនីរបស់សមាជិកនៃប្រព័ន្ធបាគងដោយឥតគិតថ្លៃសេវាលើ WOORI BANK Mobile
- ការដាក់ប្រាក់ចូលគណនីធនាគាររបស់សមាជិកបាគង
- ការទូទាត់តាមរយៈ QR
- បង្កើត QR កូដថ្មី ក្នុងករណីបាត់លេខកូដសម្ងាត់
- ការចូលដំណើរការប្រើគណនីបាគងចាស់ឡើងវិញ
- ពិនិត្យសមតុល្យគណនី និងប្រវត្តិប្រតិបត្តិការបាគង
- ពិនិត្យព័ត៌មានគណនីបាគងរបស់អ្នក

### ការប្រើប្រាស់សេវាកម្ម ៖

**តាមរយៈ WOORI BANK Mobile**

- ធ្វើប្រតិបត្តិការហិរញ្ញវត្ថុ៖ ផ្ញើ ទទួល ការដាក់ប្រាក់ ទូទាត់តាមរយៈ QR
- ប្រតិបត្តិការផ្ទេរប្រាក់ពីគណនីសន្សំធនាគារ អ៊ូរី ទៅកាន់គណនីចរន្ត ឬ គណនីសន្សំរបស់សមាជិកនៃប្រព័ន្ធបាគង
- ប្រតិបត្តិការផ្ទេរប្រាក់ ពីគណនីសន្សំធនាគារ អ៊ូរី ទៅកាន់គណនីបាគង
- ការចុះឈ្មោះគណនីបាគង
- ការស្តារចូលប្រើគណនីបាគងឡើងវិញ
- ការសង្គ្រោះគណនីបាគង ឬ QR
- ការបង្កើតកូដ QR ថ្មី
- ពិនិត្យមើលសមតុល្យគណនី និងប្រវត្តិប្រតិបត្តិការបាគង
- ពិនិត្យមើលព័ត៌មានគណនីបាគង

**តាមរយៈបញ្ជររបស់ធនាគារ អ៊ូរី**

- ប្រតិបត្តិការដាក់សាច់ប្រាក់
- ប្រតិបត្តិការដកសាច់ប្រាក់
- ប្រតិបត្តិការផ្ទេរ ពីគណនីសន្សំធនាគារ អ៊ូរី ទៅកាន់គណនីបាគង
- ប្រតិបត្តិការផ្ទេរប្រាក់ ពីគណនីសន្សំធនាគារ អ៊ូរី ទៅកាន់គណនីចរន្ត ឬគណនីសន្សំ របស់សមាជិកនៃប្រព័ន្ធបាគង

## សេវាផ្ទេរមូលនិធិភ្លាមៗ

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានក្លាយជាសមាជិកនៃសេវាផ្ទេរមូលនិធិភ្លាមៗ (RFT)។ អតិថិជនរបស់ ធនាគារ អ៊ូរី ទាំងអស់អាចរីករាយប្រើប្រាស់ជាមួយសេវាកម្មផ្ទេរប្រាក់បន្ថែមថ្មីមួយទៀតប្រកបដោយភាពងាយស្រួល និងមានសុវត្ថិភាព។

**អត្ថប្រយោជន៍ដែលទទួលបាន៖**

- អតិថិជនអាចផ្ទេរប្រាក់ទៅធនាគារផ្សេងៗ (ដែលជាសមាជិករបស់ RFT) ភ្លាមៗ
- អតិថិជនអាចផ្ទេរប្រាក់បានគ្រប់ពេលវេលា និងគ្រប់ទីកន្លែងដោយប្រើប្រាស់ WOORI BANK Mobile
- វាមានភាពរហ័ស សុវត្ថិភាព និងងាយស្រួលសម្រាប់អតិថិជនក្នុងការផ្ទេរប្រាក់ឆ្លងធនាគារ។

**ការប្រើប្រាស់សេវាកម្ម៖**

**តាមរយៈ WOORI BANK Mobile**

- ផ្ទេរប្រាក់តាមគណនី
- ផ្ទេរប្រាក់តាមលេខទូរស័ព្ទ

**តាមរយៈបញ្ជររបស់ ធនាគារ អ៊ូរី**

- ផ្ទេរប្រាក់តាមគណនី
- ការលុបចោលការផ្ទេរប្រាក់តាមគណនី
- ផ្ទេរប្រាក់តាមលេខទូរស័ព្ទ
- ការលុបចោលផ្ទេរប្រាក់តាមលេខទូរស័ព្ទ
- ការទូទាត់សម្រាប់ប្រតិបត្តិការផ្ទេរប្រាក់ពីគណនីទៅលេខទូរស័ព្ទ
- ការសាកសួរអំពីការផ្ទេរប្រាក់

## សេវាកម្ម KHQR

KHQR ត្រូវបានបង្កើតឡើងសម្រាប់ការទូទាត់នៅកម្ពុជា និងការទូទាត់ឆ្លងប្រទេសក្នុងតំបន់អាស៊ាន។ វាទាមទារតែ QR តែមួយប៉ុណ្ណោះសម្រាប់ការទទួលការទូទាត់ពីកម្មវិធីទូរស័ព្ទនានា រួមទាំងកម្មវិធី Bakong App ដែលធ្វើឱ្យការទូទាត់ QR កាន់សាមញ្ញសម្រាប់ទាំងអតិថិជន និងអាជីវករក្នុងប្រទេសកម្ពុជាដោយប្រើបណ្ដាញទូទាត់បាគង។

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានដាក់ដំណើរការសេវាកម្ម KHQR ជាផ្លូវការនៅថ្ងៃទី07 ខែកុម្ភៈ ឆ្នាំ 2022។ អតិថិជនរបស់ធនាគារ អ៊ូរី អាចស្កេន KHQR ដើម្បីផ្ទេរប្រាក់ និងទូទាត់ដោយប្រើកម្មវិធី WOORI BANK Mobile កាន់តែមានសុវត្ថិភាពខ្ពស់ និងងាយស្រួល។ លើសពីនេះទៀត ពាណិជ្ជករ KHQR របស់ធនាគារ អ៊ូរី អាចទទួលយកការទូទាត់បានទូទៅពី Bakong App និងកម្មវិធីទូរស័ព្ទចល័តធនាគារផ្សេងទៀតដែលគាំទ្រសេវាស្កេន KHQR។

## អត្ថប្រយោជន៍របស់ KHQR

**សម្រាប់អតិថិជន៖**

- មិនមានការភាន់ច្រលំជាមួយកូដ QR ច្រើនទៀតទេនៅពេលធ្វើការទូទាត់ដោយគ្រាន់តែរកមើលស្លាកKHQR ។
- ការប្រើប្រាស់កម្មវិធីដែលអ្នកចូលចិត្តរួមទាំងកម្មវិធី Bakong ដើម្បីទូទាត់គ្រប់ទីកន្លែងដែលមានស្លាក KHQR ។

**សម្រាប់ពាណិជ្ជករ៖**

- ងាយស្រួលដាក់តាំងលើបញ្ជរ ដោយគ្រាន់តែត្រូវបង្ហាញជើងទម្រ KHQR តែមួយដើម្បីទទួលយកការទូទាត់ពីគ្រប់ធនាគារដែលជាសមាជិកបាគង។
- ដំណោះស្រាយនៃការទូទាត់យ៉ាងសាមញ្ញ រហ័ស និងសុវត្ថិភាព។



## ប្រភេទប្រតិបត្តិការ KHQR

**សម្រាប់អតិថិជន៖**

| ប្រភេទប្រតិបត្តិការ | ការពិពណ៌នា |
| --- | --- |
| **ស្កេនសម្រាប់ការទូទាត់ទៅឱ្យពាណិជ្ជករ KHQR** | អតិថិជនរបស់ WOORI BANK Mobile អាចស្កេន និងទូទាត់ប្រាក់ជាមួយពាណិជ្ជករ KHQR ទាំង ពាណិជ្ជកររបស់ធនាគារ អ៊ូរី និងពាណិជ្ជករសមាជិកKHQR ផ្សេងទៀត។ |
| **ស្កេនសម្រាប់ការផ្ទេរប្រាក់ទៅឱ្យគណនីរបស់សមាជិក KHQR ឬ គណនីរបស់ធនាគារ អ៊ូរី** | អតិថិជនរបស់ WOORI BANK Mobile អាចស្កេន និងផ្ទេរប្រាក់គណនីរបស់សមាជិក KHQR ឬ គណនីរបស់ធនាគារ អ៊ូរី ។<br>**សម្គាល់៖** ប្រតិបត្តិការនេះគឺជោគជ័យ លុះត្រាតែធនាគារសមាជិក KHQR ប្រើប្រាស់សេវានេះ។ |
| **ទទួលការផ្ទេរប្រាក់ពីធនាគារសមាជិក KHQR ឬកម្មវិធីបាគង** | អតិថិជនរបស់របស់ធនាគារ អ៊ូរី អាចទទួលការផ្ទេរប្រាក់ពីធនាគារសមាជិក KHQR ឬកម្មវិធីបាគង ដោយគ្រាន់តែបង្ហាញ QR កូដពីកម្មវិធីទូរស័ព្ទ WOORI BANK Mobile។<br>**សម្គាល់៖** ប្រតិបត្តិការនេះគឺជោគជ័យ លុះត្រាតែធនាគារសមាជិក KHQR ប្រើប្រាស់សេវានេះ។ |
| **ស្កេនសម្រាប់ការផ្ទេរប្រាក់ទៅឱ្យគណនីបាគង** | អតិថិជនរបស់ WOORI BANK Mobile អាចស្កេន និងផ្ទេរប្រាក់គណនីបាគង។ |

**សម្រាប់ពាណិជ្ជករ៖**

| ប្រភេទប្រតិបត្តិការ | ការពិពណ៌នា |
| --- | --- |
| **ទទួលយកការទូទាត់តាមរយៈ Bakong** | ពាណិជ្ជកររបស់ធនាគារ អ៊ូរី អាចទទួលយកការទូទាត់ពី WOORI BANK Mobile, កម្មវិធីទូរស័ព្ទបាគង និងកម្មវិធីទូរស័ព្ទរបស់ធនាគារផ្សេងទៀតដែលជាសមាជិកបាគង។ |

# សេវាអេធីអឹម និងប័ណ្ណឥណពន្ធ

សេវាអេធីអឹម និងប័ណ្ណឥណពន្ធ បានត្រៀមខ្លួនរួចជាស្រេចដើម្បីបម្រើអតិថិជនជាមួយនឹងភាពងាយស្រួល ភាពបត់បែន និងសុវត្ថិភាពនៅទូទាំងតំបន់ក្នុងប្រទេសកម្ពុជា។ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ក៏បានភ្ជាប់ប្រព័ន្ធអេធីអឹម របស់ខ្លួនដោយជោគជ័យទៅនឹងប្រព័ន្ធ Cambodian Shared Switch (CSS) និងប្រព័ន្ធរបស់ប័ណ្ណវីសា ដែលត្រូវបានរៀបចំ និងគាំទ្រដោយធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុនវីសា ។ សេវាកម្មអេធីអឹម និងប័ណ្ណឥណពន្ធ បានផ្តល់នូវភាពបត់បែន និងភាពងាយស្រួល សម្រាប់អតិថិជនដើម្បីធ្វើប្រតិបត្តិការលើម៉ាស៊ីនអេធីអឹមរបស់ ធនាគារ អ៊ូរី ឬ សេវាកម្ម អេធីអឹម និងម៉ាស៊ីនឆូតកាត (POS) របស់ធនាគារដែលជាសមាជិករបស់ប្រពន្ធ័ Cambodian Shared Switch តាមតម្រូវការដោយមិនគិតពីពេលវេលា និងទីកន្លែង។ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ត្រៀមខ្លួនជាស្រេចដើម្បីគាំទ្រជាមួយនឹងមុខងារផ្សេងៗរួមទាំងប្រតិបត្តិការហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុនៅលើម៉ាស៊ីនអេធីអឹម និងម៉ាស៊ីនឆូតកាត (POS) ដូចខាងក្រោម។ ក្នុងឆ្នាំ 2023 ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានដាក់បន្ថែមម៉ាស៊ីនអេធីអឹមថ្មីចំនួន 98 ម៉ាស៊ីន ដែលធ្វើអោយចំនួនសរុបរហូតដល់ជាង 100 ម៉ាស៊ីននៅទូទាំងប្រទេសកម្ពុជា។

### សេវាកម្មម៉ាស៊ីន អេធីអឹម របស់ធនាគារ អ៊ូរី ឬ ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ Cambodian Shared Switch (CSS) ៖

| # | ប្រភេទប្រតិបត្តិការ | ការពិពណ៌នា |
|---|---|---|
| 1 | ការដកប្រាក់ | អតិថិជនអាចធ្វើប្រតិបត្តិការដកសាច់ប្រាក់តាមរយៈម៉ាស៊ីនអេធីអឹម របស់ធនាគារ អ៊ូរី ឬ ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ CSS |
| 2 | ការពិនិត្យសមតុល្យ | អតិថិជនអាចធ្វើប្រតិបត្តិការពិនិត្យសមតុល្យតាមរយៈម៉ាស៊ីនអេធីអឹម របស់ធនាគារ អ៊ូរី ឬ ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ CSS |
| 3 | របាយការណ៍សង្ខេប | អតិថិជនអាចធ្វើប្រតិបត្តិការពិនិត្យរបាយការណ៍សង្ខេប តាមរយៈម៉ាស៊ីន អេធីអឹម របស់ធនាគារ អ៊ូរី ឬ ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ CSS |
| 4 | ការប្តូរលេខសម្ងាត់ | អតិថិជនអាចធ្វើប្រតិបត្តិការប្តូរលេខសម្ងាត់របស់ប័ណ្ណ តាមរយៈម៉ាស៊ីន អេធីអឹម របស់ធនាគារ អ៊ូរី ឬ ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ CSS |
| 5 | ការផ្ទេរប្រាក់ក្នុងធនាគារតែមួយ | ការធ្វើប្រតិបត្តិការនេះ គឺអនុញ្ញាតសម្រាប់តែអតិថិជនរបស់ ធនាគារ អ៊ូរី តែប៉ុណ្ណោះ |
| 6 | ការផ្ទេរប្រាក់អន្តរធនាគារ | អតិថិជនអាចធ្វើប្រតិបត្តិការផ្ទេរប្រាក់អន្តរធនាគារតាមរយៈម៉ាស៊ីនអេធីអឹម របស់ធនាគារ អ៊ូរី ឬ ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ CSS |

### តាមរយៈសេវាកម្មរបស់ម៉ាស៊ីន POS ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ Cambodian Shared Switch(CSS)៖

| # | ប្រភេទប្រតិបត្តិការ | ការពិពណ៌នា |
|---|---|---|
| 1 | ការដកប្រាក់ | អតិថិជនរបស់ ធនាគារ អ៊ូរី អាចធ្វើប្រតិបត្តិការដកសាច់ប្រាក់ តាមរយៈម៉ាស៊ីន ឆូតកាត (POS) របស់ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ CSS |
| 2 | ការពិនិត្យសមតុល្យ | អតិថិជនរបស់ ធនាគារ អ៊ូរី អាចធ្វើប្រតិបត្តិការពិនិត្យសមតុល្យ តាមរយៈម៉ាស៊ីនឆូតកាត (POS) របស់ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ CSS |
| 3 | ការទូទាត់ | អតិថិជនរបស់ ធនាគារ អ៊ូរី អាចធ្វើប្រតិបត្តិការទូទាត់ការទិញទំនិញ តាមរយៈម៉ាស៊ីនឆូតកាត (POS) របស់ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ CSS |



## ប័ណ្ណវីសា

ក្នុងខែសីហា ឆ្នាំ2023 ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានដាក់ដំណើរការជាផ្លូវការប្រភេទប័ណ្ណអន្តរជាតិ ប័ណ្ណឥណពន្ធវីសា ទៅកាន់ទីផ្សារប្រទេសកម្ពុជា និងបន្ទាប់មកប័ណ្ណឥណទានវីសាក្នុងខែធ្នូ ឆ្នាំ2023 ដែលរួមមានប័ណ្ណឥណពន្ធវីសាក្លាស៊ីក ប័ណ្ណឥណពន្ធវីសាហ្គោល ប័ណ្ណឥណពន្ធវីសាផ្លាធីនីម ប័ណ្ណឥណទានវីសាក្លាស៊ីក ប័ណ្ណឥណទានវីសាហ្គោល និងប័ណ្ណឥណទានវីសាផ្លាធីនីម។ ប័ណ្ណវីសារបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ត្រូវបានបង្កើតឡើងដើម្បីតម្រូវជូនគ្រប់ប្រភេទអតិថិជន ទាំងអតិថិជនរូបវន្តបុគ្គល និងអតិថិជនស្ថាប័ន។

**ប័ណ្ណវីសាអ៊ូរី ទទួលយកបទពិសោធន៍ជុំវិញពិភពលោកជាមួយយើង!**

## សេវាទូទាត់វិក្កយបត្រ

ការទូទាត់វិក្កយបត្រ គឺជាមធ្យោបាយមួយដែលផ្តល់ជូនអតិថិជនដើម្បីធ្វើការទូទាត់របស់ពួកគេតាមអ៊ីនធឺណិតតាមរយៈធនាគារចល័ត ( WOORI BANK Mobile)។ អតិថិជនមានការបង់ប្រាក់ផ្សេងៗគ្នា ដូចជាការទូទាត់ការប្រើប្រាស់ ការកម្សាន្តជាដើម។

# សេវា ធនាគារផ្សេងៗ

## សេវាបើកប្រាក់បៀវត្សរ៍

សេវាបើកប្រាក់បៀវត្សរ៍ ត្រូវបានរៀបចំឡើងដើម្បីបំពេញតាមតម្រូវការរបស់អតិថិជនដែលជានិយោជក តាមរយៈប្រព័ន្ធគ្រប់គ្រងច្បាស់លាស់ និងមានភាពងាយស្រួលក្នុងការទូទាត់ដូចជា (ប្រាក់បៀវត្សរ៍ ប្រាក់លើកទឹកចិត្ត និងប្រាក់រង្វាន់ផ្សេងៗ) ដល់បុគ្គលិករបស់ពួកគេ។ សេវានេះនឹងត្រូវបានអនុវត្តដោយយោងតាមសំណើរបញ្ជាលើសេវាបើកប្រាក់បៀវត្សរ៍ ដែលត្រូវបាន ផ្តល់ដោយនិយោជក។ សេវានេះ នឹងអនុញ្ញាតឱ្យនិយោជកអាចធ្វើការទូទាត់ប្រាក់បៀវត្សរ៍ឱ្យបុគ្គលិករបស់ពួកគេ ដោយការផ្ទេរប្រាក់ចេញពីគណនីទូទាត់របស់ខ្លួនទៅកាន់គណនីបុគ្គលិកតាមរយៈ ធនាគារ អ៊ូរី ប្រកបដោយភាពងាយស្រួលរហ័ស និងសុវត្ថិភាព។ សេវា នេះក៏នឹងផ្តល់នូវឱកាស និងអត្ថប្រយោជន៍ជាច្រើនផ្សេងទៀតដល់បុគ្គលិករបស់ពួកគេ តាមរយៈការប្រើប្រាស់ផលិតផល និងសេវា ផ្សេងទៀតរបស់ ធនាគារ អ៊ូរី ដូចជាទទួលបានត្រាការប្រាក់ខ្ពស់ពីប្រាក់សន្សំ ទទួលបានសេវាអេធីអឹម សេវាធនាគារចល័តជាដើម។

| | |
|---|---|
| **រូបិយប័ណ្ណ** | រៀល, ដុល្លារ និងថៃបាត |
| **កម្រៃសេវា** | 1,000 រៀល |
| | 0.25 ដុល្លារ |
| | 7.5 បាត |
| **សម្គាល់** | និយោជិត និងនិយោជកត្រូវមានគណនីសន្សំជាមួយធនាគារ អ៊ូរី |

## សេវា ថេប ប៉ែងឃីង

សេវា ថេប ប៉ែងឃីង ត្រូវបានបង្កើតឡើងជាមធ្យោបាយមួយផ្សេងទៀតសម្រាប់ការបើកគណនី ដើម្បីផ្តល់សេវាបម្រើអតិថិជនកាន់តែប្រសើរ និងដើម្បីកាត់បន្ថយពេលវេលា និងការចំណាយសម្រាប់ការបើកគណនី។ ដំណើរការនេះអនុញ្ញាតឱ្យបុគ្គលិកទទួលបន្ទុករបស់ធនាគារ អ៊ូរី ធ្វើការចុះទៅបើកគណនីដល់ទីតាំងជូនអតិថិជន។

## សេវាកម្មបំពេញតុល្យភាពគណនីរបស់ភ្នាក់ងារ

សេវាកម្មបំពេញសមតុល្យគណនីរបស់ភ្នាក់ងារ គឺជាសេវាមួយរបស់ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ដែលបង្កើតឡើងដើម្បីជួយសម្រួលដល់ភ្នាក់ងារដែលជាដៃគូររបស់ ធនាគារ អ៊ូរី ដើម្បីចាត់ចែង គណនីWallet របស់ពួកគេ។ សេវាកម្មនេះអនុញ្ញាតឱ្យភ្នាក់ងារធ្វើប្រតិបត្តិការដាក់ប្រាក់ចូល និងដកប្រាក់ចេញពីគណនីWallet តាមរយៈបញ្ជររបស់ ធនាគារ អ៊ូរី ឬមធ្យោបាយផ្សេងទៀតរបស់ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក។

| | |
|---|---|
| **រូបិយប័ណ្ណ** | រៀល និងដុល្លារ |
| **វិសាលភាពនៃសេវាកម្ម** | **ការដាក់ប្រាក់ចូល**<br>• ដាក់សាច់ប្រាក់ចូលគណនី Wallet របស់ភ្នាក់ងារ<br>• ផ្ទេរប្រាក់ពីគណនីសង្ស៊ឹម ទៅគណនីWallet របស់ភ្នាក់ងារ |
| | **ការដកប្រាក់ចេញ**<br>• ដកសាច់ប្រាក់ចេញពីគណនី Wallet របស់ភ្នាក់ងារ |
| **ដៃគូបច្ចុប្បន្ន** | • ភ្នាក់ងាររីង<br>• ភ្នាក់ងារ លី ហួរ វេរលុយ |

# របាយការណ៍
# ស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម

| | 2023 | 2022 | 2021 | 2020 |
|---|---|---|---|---|
| **សូចនាករលើការអនុវត្តផ្នែកបរិស្ថាន** | | | | |
| **សម្ភារ** | | | | |
| ក្រដាស ប្រើគិតជាគីឡូក្រាម /FTE (1) | 34.38 | 22.09 | 10.74 | 18.83 |
| ទម្រង់ប្រាក់កម្ចី ប្រើគិតជាគីឡូក្រាម /FTE | 14.79 | 5.77 | 3.18 | 5.10 |
| ក្រដាសប្រើប្រាស់ក្នុងការិយាល័យ ប្រើគិតជាគីឡូក្រាម /FTE | 19.59 | 16.32 | 7.56 | 13.73 |
| **សំណល់** | | | | |
| សំណល់ក្រដាស គិតជាគីឡូក្រាម /FTE | 1.00 | 1.08 | 1.13 | 2.10 |
| ក្រដាសជូតមាត់ ប្រើគិតជាគីឡូក្រាម | 2,791.38 | 2,784.36 | 2,767.95 | 2,973.78 |
| ក្រដាសជូតដៃ ប្រើគិតជាគីឡូក្រាម | 462.55 | 284.95 | 329.79 | 1,162.64 |
| ក្រដាសបង្គន់ ប្រើគិតជាគីឡូក្រាម | 847.45 | 806.41 | 830.88 | 846.94 |
| **ថាមពល** | | | | |
| ចរន្តអគ្គិសនី ប្រើគិតជាគីឡូវ៉ាត់ម៉ោង/FTE | 456.85 | 417.24 | 428.14 | 549.59 |
| ប្រេងសាំង ប្រើគិតជាលីត្រ /FTE | 239.07 | 307.73 | 244.47 | 264.92 |
| ប្រេងសាំងសម្រាប់ទោចក្រយានយន្ត ប្រើគិតជាលីត្រ | 969,379.20 | 1,093,318.46 | 844,931.15 | 627,846.08 |
| ប្រេងសាំងសម្រាប់រថយន្ត ប្រើគិតជាលីត្រ | 6,971.54 | 7,733.09 | 4,863.87 | 1,063.74 |
| ប្រេងម៉ាស៊ូត ប្រើគិតជាលីត្រ /FTE | 16.41 | 18.29 | 15.12 | 25.21 |
| ប្រេងម៉ាស៊ូតសម្រាប់ម៉ាស៊ីនភ្លើង ប្រើគិតជាលីត្រ | 4,786.48 | 4,706.32 | 2,717.90 | 6,185.40 |
| ប្រេងម៉ាស៊ូតសម្រាប់រថយន្ត ប្រើគិតជាលីត្រ | 62,237.43 | 60,740.45 | 49,855.94 | 53,656.07 |
| ប្រេងម៉ាស៊ីន ប្រើគិតជាលីត្រ /FTE | N/A | | N/A | N/A |

| | 2023 | 2022 | 2021 | 2020 |
|---|---|---|---|---|
| **ការបញ្ចេញចោលនូវឧស្ម័នកាបូនិក (សមមូល គិតជាពាន់គីឡូក្រាម)(2)** | | | | |
| ចរន្តអគ្គិសនី | 1,026.18 | 821.09 | 818.51 | 717.60 |
| ប្រេងសាំង | 2,343.24 | 2,642.52 | 2039.51 | 1,509.41 |
| ប្រេងម៉ាស៊ូត | 184.32 | 179.98 | 144.58 | 164.56 |
| **ទឹក** | | | | |
| ទឹក ប្រើគិតជាម៉ែត្រគូប /FTE | 4.93 | 5.56 | 6.02 | 10.43 |
| ទឹក ប្រើគិតជាម៉ែត្រគូប | 17,327.62 | 17,090.04 | 20,580.32 | 24,294.76 |
| ទឹកបរិសុទ្ធ ប្រើគិតជាម៉ែត្រគូប | 2,799.82 | 2,799.65 | 339.20 | 465.81 |
| **ការធ្វើដំណើរ** | | | | |
| ដោយរថយន្ត គិតជាគីឡូម៉ែត្រ /FTE | 179.76 | 136.58 | 160.68 | 235.27 |
| ដោយទោចក្រយានយន្ត គិតជាគីឡូម៉ែត្រ /FTE | 9,689.15 | 12,230.49 | 9,764.89 | 10,579.71 |

## សូចនាករលើការអនុវត្តផ្នែកបរិស្ថាន

| | 2023 | 2022 | 2021 | 2020 |
|---|---|---|---|---|
| ការបម្រើការងារ | | | | |
| ចំនួនបុគ្គលិក | 4,259 | 4,205 | 3,780 | 2,984 |
| ស្រី | 1,091 | 1,058 | 2,908 | 632 |
| ប្រុស | 3,168 | 3,147 | 872 | 2,352 |
| ចំនួនបុគ្គលិក (FTE) | 4,084 | 3,578 | 3,476 | 2,374 |

*((1) FTE (Full Time Equivalent): ចំនួនមធ្យមនៃកម្មករនិយោជិត បម្រើការពេញម៉ោងក្នុងមួយឆ្នាំ។*

*(2) សមមូលឧស្ម័នកាបូនិកត្រូវបានគណនាយោងតាមគោលការណ៍របស់ Greenhouse Gas Protocol។*

# បណ្តាញសាខា
# និងតំបន់ប្រតិបត្តិការ

# តំបន់ប្រតិបត្តិការ

រាជធានី/ខេត្ត **25**

បណ្តាញសាខា **140**

ការិយាល័យប្រចាំតំបន់ **18**

គិតត្រឹមខែ ធ្នូ ឆ្នាំ2023



ខណ្ឌច្បារអំពៅ
ខណ្ឌដង្កោ
ខណ្ឌមានជ័យ
ខណ្ឌសែនសុខ
ខណ្ឌទួលគោក
ខណ្ឌដូនពេញ
ខណ្ឌ 7មករា
ខណ្ឌពោធិ៍សែនជ័យ
ខណ្ឌជ្រោយចង្វារ
ខណ្ឌព្រែកព្នៅ
ខណ្ឌឫស្សីកែវ
ខណ្ឌចំការមន

# V

# របាយការណ៍ហិរញ្ញវត្ថុ


របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ........................................ 84

របាយការណ៍ចំណេញ ឬ ខាត និងលទ្ធផលលម្អិតផ្សេងៗ .... 85

របាយការណ៍បម្រែបម្រួលមូលធន ........................................ 86

របាយការណ៍លំហូរសាច់ប្រាក់ ........................................ 87

របាយការណ៍របស់សវនករឯករាជ្យ ........................................ 88

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ........................................ 91

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | |
| សាច់ប្រាក់ក្នុងដៃ | 15,349,892 | 62,704,309 | 12,238,185 | 50,384,608 |
| ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា | 132,416,366 | 540,920,855 | 99,548,079 | 409,839,441 |
| ប្រាក់បញ្ញើនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា | 82,887,381 | 338,594,951 | 131,434,362 | 541,115,268 |
| ឥណទាន និងបុរេប្រទាន ផ្តល់ដល់អតិថិជន | 1,180,853,134 | 4,823,785,052 | 1,161,229,951 | 4,780,783,708 |
| មូលបត្រវិនិយោគ | 15,353 | 62,717 | 15,353 | 63,208 |
| ទ្រព្យ និងបរិក្ខារ | 16,259,358 | 66,419,477 | 9,654,433 | 39,747,301 |
| ទ្រព្យសកម្មអរូបី | 8,735,170 | 35,683,169 | 5,764,271 | 23,731,504 |
| សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | 15,622,452 | 63,817,716 | 12,774,005 | 52,590,579 |
| ពន្ធពន្យារជាទ្រព្យសកម្ម សុទ្ធ | 4,185,694 | 17,098,560 | 4,089,306 | 16,835,673 |
| ទ្រព្យសកម្មផ្សេងៗ | 5,643,527 | 23,053,810 | 4,599,908 | 18,937,821 |
| **ទ្រព្យសកម្មសរុប** | 1,461,968,327 | 5,972,140,616 | 1,441,347,853 | 5,934,029,111 |
| **បំណុល និងមូលធនរបស់ភាគទុនិក** | | | | |
| **បំណុល** | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុនានា | 444,831,158 | 1,817,135,280 | 353,464,472 | 1,455,213,231 |
| បំណុលពន្ធលើប្រាក់ចំណេញ | 2,694,139 | 11,005,558 | 11,614,705 | 47,817,740 |
| ប្រាក់កម្ចី | 110,621,173 | 451,887,492 | 128,431,315 | 528,751,724 |
| គណនីត្រូវទូទាត់ឱ្យសម្ព័ន្ធញាតិ | 543,005,844 | 2,218,178,873 | 606,374,329 | 2,496,443,112 |
| បំណុលភតិសន្យា | 15,278,899 | 62,414,302 | 12,652,171 | 52,088,988 |
| បំណុលផ្សេងៗ | 7,169,333 | 29,286,726 | 6,315,566 | 26,001,186 |
| **បំណុលសរុប** | 1,123,600,546 | 4,589,908,231 | 1,118,852,558 | 4,606,315,981 |
| **មូលធនរបស់ភាគទុនិក** | | | | |
| ដើមទុន | 175,895,100 | 703,580,400 | 175,895,100 | 703,580,400 |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | 3,239,827 | 13,338,368 |
| ប្រាក់ចំណេញរក្សាទុក | 156,516,181 | 638,270,535 | 137,403,868 | 559,696,250 |
| ទុនបម្រុងរួមបញ្ចូលគ្នា | 5,956,500 | 24,284,651 | 5,956,500 | 24,284,651 |
| ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | - | 16,096,799 | - | 26,813,461 |
| **មូលធនរបស់ភាគទុនិកសរុប** | 338,367,781 | 1,382,232,385 | 322,495,295 | 1,327,713,130 |
| **បំណុល និងមូលធនរបស់ភាគទុនិកសរុប** | 1,461,968,327 | 5,972,140,616 | 1,441,347,853 | 5,934,029,111 |



# របាយការណ៍ចំណេញ ឬ ខាត និងលទ្ធផលលម្អិតផ្សេងៗ

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលការប្រាក់ | 179,685,683 | 738,508,157 | 169,853,347 | 694,190,629 |
| ចំណាយការប្រាក់ | (81,189,150) | (333,687,407) | (48,808,733) | (199,481,292) |
| **ចំណូលការប្រាក់សុទ្ធ** | 98,496,533 | 404,820,750 | 121,044,614 | 494,709,337 |
| កម្រៃ និងចំណូលជើងសា | 617,332 | 2,537,235 | 330,876 | 1,352,290 |
| កម្រៃ និងចំណាយជើងសា | (1,673,690) | (6,878,866) | (1,659,572) | (6,782,671) |
| **កម្រៃ និងចំណាយជើងសាសុទ្ធ** | (1,056,358) | (4,341,631) | (1,328,696) | (5,430,381) |
| ខាតលើឱនភាពនៃតម្លៃលើឧបករណ៍ហិរញ្ញវត្ថុ | (27,332,262) | (112,335,597) | (16,180,923) | (66,131,432) |
| ចំណូលផ្សេងៗសុទ្ធ | 7,618,028 | 31,310,095 | 7,822,939 | 31,972,352 |
| ចំណាយបុគ្គលិក | (35,337,309) | (145,236,340) | (33,586,591) | (137,268,397) |
| រំលស់ | (7,471,355) | (30,707,269) | (5,402,032) | (22,078,105) |
| ចំណាយប្រតិបត្តិការផ្សេងៗ | (14,858,564) | (61,068,698) | (14,190,400) | (57,996,166) |
| **ប្រាក់ចំណេញមុនដកពន្ធ** | 20,058,713 | 82,441,310 | 58,178,911 | 237,777,208 |
| ចំណាយពន្ធលើប្រាក់ចំណេញ | (4,186,227) | (17,205,393) | (12,449,544) | (50,881,286) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | 15,872,486 | 65,235,917 | 45,729,367 | 186,895,922 |
| **លទ្ធផលលម្អិតផ្សេងៗ** ធាតុដែលមិនត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញក្នុងរបាយការណ៍ចំណេញ ឬខាត | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (10,716,662) | - | 13,272,817 |
| **លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | 15,872,486 | 54,519,255 | 45,729,367 | 200,168,739 |

# របាយការណ៍បម្រែបម្រួលមូលធន

| | ដើមទុន | ទុនបម្រុងបទប្បញ្ញត្តិ | ចំណេញរក្សាទុក | ទុនបម្រុងបញ្ចូលគ្នា | លម្អៀងពីការប្តូររូបិយប័ណ្ណ | មូលធនសរុប |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ថ្ងៃទី1 ខែមករា ឆ្នាំ2023 (ការរាយការណ៍ឡើងវិញ) | 175,895,100 | 3,239,827 | 137,403,868 | 5,956,500 | 26,813,461 | 322,495,295 |
| **ប្រតិបត្តិការទទួលស្គាល់ដោយផ្ទាល់ទៅក្នុងមូលធន** | | | | | | |
| ផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងតាមបទប្បញ្ញត្តិ (កំណត់សម្គាល់ 21) | - | (3,239,827) | 3,239,827 | - | - | - |
| **លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | 15,872,486 | - | - | 15,872,486 |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | (10,716,662) | - |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | **175,895,100** | **-** | **156,516,181** | **5,956,500** | **16,096,799** | **338,367,781** |
| ថ្ងៃទី1 ខែមករា ឆ្នាំ2022 (ការរាយការណ៍ឡើងវិញ) | 175,895,100 | 4,534,996 | 90,379,332 | 5,956,500 | 13,540,644 | 276,765,928 |
| **ប្រតិបត្តិការទទួលស្គាល់ដោយផ្ទាល់ទៅក្នុងមូលធន** | | | | | | |
| ផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងតាមបទប្បញ្ញត្តិ (កំណត់សម្គាល់ 21) | - | **(1,295,169)** | **1,295,169** | - | - | - |
| **លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ (ការរាយការណ៍ឡើងវិញ) | - | - | 45,729,367 | - | - | 45,729,367 |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | 13,272,817 | - |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 (ការរាយការណ៍ឡើងវិញ) | **175,895,100** | **3,239,827** | **137,403,868** | **5,956,500** | **26,813,461** | **322,495,295** |



# របាយការណ៍លំហូរសាច់ប្រាក់

| | សម្រាប់ការិយបរិច្ឆេទបានបញ្ចប់ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | | សម្រាប់ការិយបរិច្ឆេទបានបញ្ចប់ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| ប្រាក់ចំណេញមុនដកពន្ធ | **20,058,713** | **82,441,310** | 58,178,911 | 237,777,208 |
| *និយ័តភាពលើ៖* | | | | |
| ខាតលើឱនភាពនៃតម្លៃលើឧបករណ៍ហិរញ្ញវត្ថុ | **27,332,262** | **112,335,597** | 16,180,923 | 66,131,432 |
| ចំណាយការប្រាក់ | **81,189,150** | **333,687,407** | 48,808,733 | 199,481,292 |
| រំលស់ | **7,471,355** | **30,707,269** | 5,402,032 | 22,078,105 |
| ប្រាក់ខាតលើការលក់ទ្រព្យ និងបរិក្ខារ | **52** | **214** | 6,442 | 26,328 |
| ការលុបចោលទ្រព្យអរូបី | **-** | **-** | 443,359 | 1,812,008 |
| ចំណូលការប្រាក់ | **(179,685,683)** | **(738,508,157)** | (169,853,347) | (694,190,629) |
| ប្រាក់ខាតពីអត្រាប្តូររូបិយប័ណ្ណដែលមិនទាន់ទទួលស្គាល់ | **(50,564)** | **(207,818)** | (92,710) | (378,906) |
| | **(43,684,715)** | **(179,544,178)** | (40,925,657) | (167,263,162) |
| *បម្រែបម្រួលនៃ៖* | | | | |
| សមតុល្យនៅ | | | | |
| ធនាគារជាតិនៃកម្ពុជា | **(16,932,205)** | **(69,591,363)** | (16,977,969) | (69,388,959) |
| ឥណទានផ្តល់ដល់អតិថិជន | **(44,496,076)** | **(182,878,872)** | (255,490,580) | (1,044,190,000) |
| ទ្រព្យសកម្មផ្សេងៗ | **(142,131)** | **(584,158)** | (1,177,803) | (4,813,681) |
| ប្រាក់បញ្ញើរបស់អតិថិជន | **88,840,799** | **365,135,684** | 131,403,976 | 537,048,050 |
| បំណុលផ្សេងៗ | **853,767** | **3,508,982** | (3,288,485) | (13,440,038) |
| *សាច់ប្រាក់ប្រើប្រាស់ក្នុងប្រតិបត្តិការ* | **(15,560,561)** | **(63,953,905)** | (186,456,518) | (762,047,790) |
| ការប្រាក់បានទទួល | **176,851,116** | **726,858,087** | 165,787,523 | 677,573,607 |
| ការប្រាក់បានបង់ | **(82,278,561)** | **(338,164,886)** | (41,272,934) | (168,682,481) |
| ពន្ធលើប្រាក់ចំណេញបានបង់ | **(13,203,181)** | **(54,265,074)** | (13,175,186) | (53,846,985) |
| **សាច់ប្រាក់សុទ្ធទទួលបានពី/(ប្រើប្រាស់ក្នុង) សកម្មភាពប្រតិបត្តិការ** | **65,808,813** | **270,474,222** | (75,117,115) | (307,003,649) |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| សាច់ប្រាក់ទទួលបានពីការលក់ទ្រព្យ និងបរិក្ខារ | **185** | **760** | 398,174 | 1,627,337 |
| ការទិញទ្រព្យសកម្មអរូបី | **(3,986,259)** | **(16,383,524)** | (3,141,560) | (12,839,556) |
| ការទិញទ្រព្យ និងបរិក្ខារ | **(9,981,560)** | **(41,024,212)** | (6,085,493) | (24,871,410) |
| ប្រាក់បញ្ញើនៅធនាគារនានា | **44,105,973** | **181,275,549** | (10,273,360) | (41,987,222) |
| **សាច់ប្រាក់សុទ្ធទទួលបានពី/(ប្រើប្រាស់ក្នុង) សកម្មភាពវិនិយោគ** | **30,138,339** | **123,868,573** | (19,102,239) | (78,070,851) |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | **76,552,632** | **314,631,318** | 104,930,775 | 428,852,077 |
| ការទូទាត់ប្រាក់កម្ចី | **(95,471,236)** | **(392,386,780)** | (76,525,410) | (312,759,351) |
| សាច់ប្រាក់ទទួលបានពីគណនីទូទាត់ឱ្យសម្ព័ន្ធញាតិ | **339,000,000** | **1,393,290,000** | 252,500,000 | 1,031,967,500 |
| ការទូទាត់លើគណនីទូទាត់ឱ្យសម្ព័ន្ធញាតិ | **(398,500,000)** | **(1,637,835,000)** | (185,631,239) | (758,674,874) |
| ការទូទាត់បំណុលភតិសន្យា | **(3,301,316)** | **(13,568,409)** | (2,550,506) | (10,423,918) |
| **សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/ទទួលបានពី សកម្មភាពហិរញ្ញប្បទាន** | **(81,719,920)** | **(335,868,871)** | 92,723,620 | 378,961,434 |
| **ការកើនឡើង/(ថយចុះ)សុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | **14,227,232** | **58,473,924** | (1,495,734) | (6,113,066) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមការិយបរិច្ឆេទ** | **44,403,335** | **182,808,531** | 45,899,069 | 186,992,808 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | **-** | **(1,776,589)** | - | 1,928,789 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងការិយបរិច្ឆេទ** | **58,630,567** | **239,505,866** | 44,403,335 | 182,808,531 |

# របាយការណ៍ របស់សវនករឯករាជ្យ

**ក្រុមហ៊ុន ខេភីអឹមជី ខេមបូឌា**
អគារ ជីអាយអេ, ផ្លូវសុភមង្គល, ភូមិ 14, សង្កាត់ទន្លេបាសាក, ខណ្ឌចំការមន, រាជធានីភ្នំពេញ, ប្រទេសកម្ពុជា

**ទូរស័ព្ទលេខ** +855 (17) 666 537 / (81) 533 999
kpmg.com.kh

ជូនចំពោះភាគទុនិកនៃ
**ធនាគារ អ៊ូរី (ខេមបូឌា) ម.ក**

## មតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក (ហៅកាត់ថា "ធនាគារ") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ ដែលរួមមានគោលនយោបាយគណនេយ្យសារវន្ត ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗ ដូចបានបង្ហាញនៅទំព័រទី11 ដល់ទី145 (ហៅកាត់ថា "របាយការណ៍ហិរញ្ញវត្ថុ")។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ បានបង្ហាញនូវភាពត្រឹមត្រូវលើរាល់ទិដ្ឋភាពជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក")។

## មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាមស្តង់ដាទាំងនោះ ត្រូវបានពណ៌នាបន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពី ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំ មានភាពឯករាជ្យពីធនាគារ ដោយស្របទៅតាមលក្ខខណ្ឌតម្រូវនៃក្រមសីលធម៌វិជ្ជាជីវៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវក្រមសីលធម៌វិជ្ជាជីវៈផ្សេងៗទៀតស្របតាមលក្ខខណ្ឌតម្រូវទាំងនេះ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបាន មានលក្ខណៈគ្រប់គ្រាន់ និងសមស្រប សម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

## ការទាញចំណាប់អារម្មណ៍ - ព័ត៌មានប្រៀបធៀប

យើងខ្ញុំ សូមធ្វើការទាញចំណាប់អារម្មណ៍ទៅកំណត់សម្គាល់ 33 នៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបញ្ជាក់ថាព័ត៌មានប្រៀបធៀបដែលបានបង្ហាញសម្រាប់ការិយបរិច្ឆេទ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 និងថ្ងៃទី1 ខែមករា ឆ្នាំ2022 និងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ត្រូវបានធ្វើការរាយការណ៍ឡើងវិញ។ មតិរបស់យើងខ្ញុំ មិនត្រូវបានកែប្រែចំពោះបញ្ហានេះឡើយ។

## បញ្ហាផ្សេងៗទាក់ទិននឹងព័ត៌មានប្រៀបធៀប

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារនាការិយបរិច្ឆេទ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 និងថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ (ដោយផ្តើមចេញពីរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី1 ខែមករា ឆ្នាំ2022 ត្រូវបានលើកឡើងមកវិញ) លើកលែងតែនិយ័តកម្មដែលបានបង្ហាញនៅកំណត់សម្គាល់ 33 នៃរបាយការណ៍ហិរញ្ញវត្ថុនេះ ដែលត្រូវបានធ្វើសវនកម្មដោយ សវនករដទៃ បានបង្ហាញមតិសវនកម្មមិនមានបញ្ហាលើ របាយការណ៍ហិរញ្ញវត្ថុទាំងនេះនៅថ្ងៃទី27 ខែមីនា ឆ្នាំ2023។

ជាផ្នែកមួយនៃការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 យើងខ្ញុំបានធ្វើសវនកម្មលើនិយ័តកម្មដែលបានបង្ហាញនៅកំណត់សម្គាល់ 33 ដែលត្រូវបានយកមកអនុវត្តដើម្បីរាយការណ៍ឡើងវិញនូវព័ត៌មានប្រៀបធៀបនៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី1 ខែមករា ឆ្នាំ2022។ យើងខ្ញុំមិនបានចូលរួមធ្វើសវនកម្ម ត្រួតពិនិត្យ ឬអនុវត្តនីតិវិធីណាមួយចំពោះរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ឬថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 (មិនបានបង្ហាញនៅទីនេះ) ឬរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនៅថ្ងៃទី1 ខែមករា ឆ្នាំ2022 នោះឡើយ ក្រៅពីនិយ័តកម្មដូចដែលបានបង្ហាញនៅកំណត់សម្គាល់ 33 សម្រាប់របាយការណ៍ហិរញ្ញវត្ថុ។ ហេតុដូចនេះហើយ យើងខ្ញុំមិនបញ្ចេញសេចក្តីសន្និដ្ឋាន ឬទម្រង់នៃការអះអាងណាមួយ លើរបាយការណ៍ហិរញ្ញវត្ថុទាំងមូលនោះឡើយ។ ទន្ទឹមនឹងនេះ មតិរបស់យើងខ្ញុំ ទៅលើនិយ័តកម្មដូចដែលបានបង្ហាញនៅក្នុងកំណត់សម្គាល់ 33 គឺមានលក្ខណៈសមស្រប និងអនុវត្តបានត្រឹមត្រូវ។

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗដែលទទួលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ សវនកម្មនេះ រួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលដែលបានបង្ហាញនៅទំព័រទី1 ដល់ទី6 និងរបាយការណ៍ប្រចាំឆ្នាំ ដែលរំពឹងថានឹងទទួលបានបន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករនេះ។ មតិសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុមិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗនេះឡើយ ហើយយើងខ្ញុំក៏មិនធ្វើការផ្តល់នូវអំណះអំណាង ណាមួយទៅលើព័ត៌មានផ្សេងៗនេះទេ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ដែលអាចរកបានខាងលើ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានអសង្គតិភាពជាសារវន្តជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬក៏ព័ត៌មានផ្សេងៗនេះបង្ហាញនូវកំហុសឆ្គងជាសារវន្តដែរ ឬទេ។

ប្រសិនបើផ្អែកទៅលើការអានព័ត៌មានផ្សេងៗ ដែលយើងខ្ញុំបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មអាចឱ្យយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

## ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ហើយទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឱ្យជៀសផុតពីការបង្ហាញខុស ជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធ នូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការធនាគារ ឬគ្មានជម្រើសសមរម្យដទៃទៀត ក្រៅពីធ្វើបែបនេះ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុ របស់ធនាគារ។

## ការទទួលខុសត្រូវរបស់សវនករ ចំពោះការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំ គឺទទួលបាននូវអំណះអំណាងសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករ ដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងមួយដែលមានកម្រិតខ្ពស់ ប៉ុន្តែវាមិនអាចធានាថា គ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការបង្ហាញខុស អាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាមានលក្ខណៈសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងដោយឡែក ឬក៏រួមបញ្ចូលគ្នា អាចត្រូវបានរំពឹងទុកយ៉ាងសមហេតុផលថា នឹងជះឥទ្ធិពលដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយម ក្នុងអំឡុងពេលធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការតាក់តែង និងអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យ ទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យនៃការរកមិនឃើញនូវការបង្ហាញខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាង ការបង្ហាញខុសដែលបណ្តាលមកពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំអាចទាក់ទិននឹង ការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីនៃប្រព័ន្ធ ត្រួតពិនិត្យផ្ទៃក្នុង។
- ធ្វើការស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីតាក់តែងនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារឡើយ។
- ធ្វើការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យដែលធនាគារបានអនុវត្ត និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធនានា ដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។
- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើភាពមិនប្រាកដប្រជាជាសារវន្តបានកើតមានឡើង ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចបង្កឱ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ធនាគារ ដើម្បីបន្តនិរន្តរភាពអាជីវកម្មដែរ ឬទេ។ ប្រសិនបើយើងខ្ញុំ ធ្វើការសន្និដ្ឋានថា មានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវទាញចំណាប់អារម្មណ៍នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌ នាពេលអនាគតអាចធ្វើឱ្យធនាគារបញ្ឈប់និរន្តរភាពនៃ អាជីវកម្ម។
- ធ្វើការវាយតម្លៃលើការបង្ហាញទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដោយរួមបញ្ចូលទាំងការ លាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធ ក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

យើងខ្ញុំ ផ្តល់ព័ត៌មាន ក្នុងចំណោមបញ្ហាផ្សេងៗ ជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ចស្តីពីវិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្ត ដោយរួមបញ្ចូលទាំងចំណុចខ្វះខាតជា សារវន្ត ក្នុងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា**

ហ្គេក ឆាន

*Partner*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី26 ខែមីនា ឆ្នាំ2024

# របាយការណ៍ **របស់ក្រុមប្រឹក្សាភិបាល**

ក្រុមប្រឹក្សាភិបាល (“អភិបាល”) មានសេចក្តីសោមនស្សរីករាយ សូមធ្វើការបង្ហាញជូននូវរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក (ហៅកាត់ថា “ធនាគារ”) ដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023។

## សកម្មភាពចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ធនាគារ គឺការផ្តល់សេវាកម្ម និងផលិតផលហិរញ្ញវត្ថុដូចជាប្រាក់បញ្ញើ ឥណទាន រួមទាំងសេវាផ្ទេរប្រាក់ក្នុងស្រុក និងក្រៅប្រទេស សេវាធនាគារចល័ត សេវាទូទាត់សាច់ប្រាក់ សេវាកម្មម៉ាស៊ីនដកប្រាក់និងដាក់ប្រាក់ដោយស្វ័យប្រវត្តិ លិខិតធានារបស់ធនាគារ និងសេវាកម្មធនាគារផ្សេងៗទៀត ដែលផ្តល់សេវាជូនប្រជាជនកម្ពុជា តាមរយៈការិយាល័យកណ្តាល និងសាខារបស់ខ្លួននៅក្នុងរាជធានីភ្នំពេញ និងសាខានៅតាមបណ្តាខេត្តផ្សេងៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ពុំមានការផ្លាស់ប្តូរជាសារវន្ត លើសកម្មភាពចម្បងរបស់ធនាគារ នៅក្នុងអំឡុងការិយបរិច្ឆេទធ្វើរបាយការណ៍ហិរញ្ញវត្ថុនេះទេ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 មានដូចខាងក្រោម៖

| | សម្រាប់ការិយបរិច្ឆេទបានបញ្ចប់ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | | សម្រាប់ការិយបរិច្ឆេទបានបញ្ចប់ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់ចំណេញមុនដកពន្ធ | 20,058,713 | 82,441,310 | 58,178,911 | 237,777,208 |
| ចំណាយពន្ធលើប្រាក់ចំណេញ | (4,186,227) | (17,205,393) | (12,449,544) | (50,881,286) |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | 15,872,486 | 65,235,917 | 45,729,367 | 186,895,922 |

## ភាគលាភ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានការប្រកាស ឬបែងចែកភាគលាភណាមួយឡើយ ហើយក្រុមប្រឹក្សាភិបាលក៏ពុំមាន អនុសាសន៍ឱ្យមានការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 នេះដែរ (ឆ្នាំ2022៖ ពុំមាន)។

## ដើមទុន

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ដើមទុនរបស់ធនាគារ មានចំនួន 175,895,100 ដុល្លារអាមេរិក (នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2022៖ មានចំនួន 175,895,100 ដុល្លារអាមេរិក)។ នាការិយបរិច្ឆេទបន្ទាប់នៅថ្ងៃទី15 ខែមករា ឆ្នាំ2024 ក្រុមប្រឹក្សាភិបាលបានអនុម័ត ក្នុងការបង្កើនដើមទុនចុះបញ្ជីពីចំនួន 175,895,100 ដុល្លារអាមេរិកទៅ 275,895,100 ដុល្លារអាមេរិក។ គិតត្រឹម កាលបរិច្ឆេទនៃរបាយការណ៍នេះ ធនាគារកំពុងរៀបចំធ្វើវិសោធនកម្មលើអនុស្សរណៈ និងលក្ខន្តិកៈ ដើម្បីទទួល ការអនុម័តពី ធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្ម។

ពុំមានការផ្លាស់ប្តូរជាសារវន្ត លើភាគទុនិក និងរចនាសម្ព័ន្ធភាគហ៊ុនរបស់ធនាគារ នៅក្នុងអំឡុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះទេ។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តនៃទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុង របាយការណ៍ហិរញ្ញវត្ថុនេះ។

## ការលុបចោល និងសំវិធានធនសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ

នៅមុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្រប ដើម្បីធ្វើឱ្យប្រាកដថាសកម្មភាពត្រូវបានធ្វើឡើងទាក់ទិននឹងការលុបចោលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានរំពឹងទុកថានឹងមិនអាចប្រមូលបានមកវិញនូវលំហូរទឹកប្រាក់តាមកិច្ចសន្យាទាំងស្រុង ឬផ្នែកណាមួយរបស់វា និងការផ្តល់សំវិធានធនសម្រាប់ការខាតបង់ឥណទានដែលរំពឹងទុកនៃទ្រព្យសកម្មហិរញ្ញវត្ថុនោះ ហើយជឿជាក់ថារាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលរំពឹងទុកថាមិនមានទទួលបានសាច់ប្រាក់មកវិញតាមកិច្ចសន្យា ត្រូវបានលុបចោល ហើយសំវិធានធនលើការខាតបង់ឥណទានដែលរំពឹងទុកលើទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានធ្វើឡើងយ៉ាងគ្រប់គ្រាន់។

គិតត្រឹមកាលបរិច្ឆេទនៃរបាយកាណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងអាចបណ្តាលឱ្យចំនួននៃសំវិធានធនសម្រាប់ការខាតបង់ឥណទានដែលរំពឹងទុករបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ របស់ធនាគារ មានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះឡើយ។

## ទ្រព្យសកម្ម

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមស្រប ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្ម (លើកលែងតែបំណុល) ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ធនាគារ ដែលទំនងជាមិនអាចប្រមូលមកវិញបាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានបន្ថយឱ្យនៅស្មើត្រឹមតម្លៃដែលរំពឹងថាអាចនឹងប្រមូលបានជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយកាណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងធ្វើឱ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារថា មានភាពមិនត្រឹមត្រូវ ជាសារវន្តណាមួយនោះឡើយ។

## វិធីសាស្រ្តកំណត់តម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយកាណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្រ្តដែលមានកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

## បំណុលយថាភាព និងបំណុលផ្សេងៗទៀត

នាកាលបរិច្ឆេទនៃរបាយកាណ៍នេះ ពុំមាន៖

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ធនាគារ ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទហិរញ្ញវត្ថុមក ក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះធនាគារ ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារនោះឡើយ។

ក្រុមប្រឹក្សាភិបាលយល់ឃើញថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ធនាគារដែលធនាគារត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងអំឡុងពេលដប់ពីរខែ បន្ទាប់ពីថ្ងៃបញ្ចប់ការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ដែលអាចនឹងបង្កឱ្យមានផលប៉ះពាល់ ជាសារវន្តដល់លទ្ធភាពរបស់ធនាគារ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់សងឡើយ។

## ការប្រែប្រួលសភាពការណ៍

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលរបស់ធនាគារ ពុំបានពិនិត្យឃើញសភាពការណ៍ណាមួយដែលមិនបានរៃកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលអាចនឹងបណ្តាលឱ្យមានតួលេខនៃចំនួនណាមួយនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានភាពមិនត្រឹមត្រូវ ជាសារវន្តណាមួយនោះឡើយ។

## ប្រតិបត្តិការមិនប្រក្រតី

តាមមតិរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ធនាគារក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនរង ផលប៉ះពាល់ជាសារវន្តពីសកម្មភាពប្រតិបត្តិការ ព្រឹត្តិការណ៍ ឬធាតុណាមួយដែលមានលក្ខណៈមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានសកម្មភាពប្រតិបត្តិការ ព្រឹត្តិការណ៍ ឬធាតុណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើង ដែលអាចនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ធនាគារ ក្នុងការិយបរិច្ឆេទដែលរបាយការណ៍ហិរញ្ញវត្ថុនេះបានរៀបចំឡើងនោះទេ។

## ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលដែលបានបម្រើការងារនៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅថ្ងៃដែលចេញរបាយការណ៍នេះ រួមមាន៖

| Name | Position |
|---|---|
| លោក Sung Wook Jung | Chairman |
| លោកស្រី Fiona Michelle Whyte | Member |
| លោក Ky Buntrean | Member |
| លោក Kwang Hui Ku | Member |
| លោក Hong Ju Kim | Member and Chief Executive Officer |

## ភាគកម្មរបស់ក្រុមប្រឹក្សាភិបាល

ព័ត៌មានស្តីពីការកាន់កាប់ភាគហ៊ុនរបស់ធនាគារ និងក្រុមប្រឹក្សាភិបាលរបស់ខ្លួនគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 មានដូចខាងក្រោម៖

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 |
|---|---|---|
| | (%) ភាគរយនៃម្ចាស់កម្មសិទ្ធ | (%) ភាគរយនៃម្ចាស់កម្មសិទ្ធ |
| Mr. Hong Ju Kim | 0.00001% | 0.00001% |

ក្រៅពីការបង្ហាញខាងលើនេះ ពុំមានអភិបាលផ្សេងណាដែលកាន់កាប់ភាគហ៊ុននៅក្នុងធានាគារ ឬនៅក្រុមហ៊ុន ពាក់ព័ន្ធណាមួយឡើយ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ គឺមិនមានកិច្ចព្រមព្រៀងណាមួយដែលធនាគារជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះអាចផ្តល់លទ្ធភាពដល់សមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ឱ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ធនាគារ ឬ សាជីវកម្មដទៃទៀតនោះឡើយ។

នៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍នេះ ពុំមានអភិបាលណាម្នាក់របស់ធនាគារបានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានរួមបញ្ចូលនៅក្នុងបរិលាភសរុបដែលទទួលបាន ឬដល់កាលកំណត់ដែលត្រូវទទួលបានដោយក្រុមប្រឹក្សាភិបាល ដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយធនាគារ ឬដោយក្រុមហ៊ុនពាក់ព័ន្ធជាមួយនឹងធនាគារ ដែលក្រុមប្រឹក្សាភិបាលនោះជាសមាជិករបស់សាជីវកម្ម ឬក៏ជាមួយក្រុមហ៊ុនដែលមានអភិបាលជាសមាជិកដែលមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយនៅទំព័រទី11 ដល់ទី145 បានរៀបចំឡើងយ៉ាងត្រឹមត្រូវលើរាល់ទិដ្ឋភាពជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

(I) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្របនានា ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព

(II) អនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“ស.រ.ទ.ហ.អ.ក”) ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះ ដើម្បីបង្ហាញនូវភាពពិត និងត្រឹមត្រូវ គឺត្រូវតែបង្ហាញ ពន្យល់ និងកំណត់បរិមាណឱ្យបានច្បាស់លាស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(III) ត្រួតពិនិត្យប្រព័ន្ធដំណើរការនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និងរក្សាទុកនូវបញ្ជីគណនេយ្យឱ្យបាន គ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព

(VI) វាយតម្លៃនូវលទ្ធភាពរបស់ធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាព នៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការធនាគារ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ និង

(V) ត្រួតពិនិត្យ និងដឹកនាំធនាគារឱ្យមានប្រសិទ្ធភាព លើរាល់សេចក្តីសម្រេចដែលមានសារៈសំខាន់ទាំងអស់ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ធនាគារ ហើយត្រូវប្រាកដថា កិច្ចការនេះត្រូវបាន ឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា បានអនុវត្តនូវរាល់តម្រូវការ ដូចមានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ ហិរញ្ញវត្ថុរបស់ធនាគារ។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយថា បានបង្ហាញនូវភាពត្រឹមត្រូវលើ រាល់ទិដ្ឋភាពជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និង លំហូរទឹកប្រាក់របស់ធនាគារសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ស.រ.ទ.ហ.អ.ក)។

*ចុះហត្ថលេខាតំណាងឱ្យក្រុមប្រឹក្សាភិបាលដោយយោងទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និង ភាគទុនិក៖*

លោក Hong Ju Kim

*សមាជិកក្រុមប្រឹក្សាភិបាល និងអគ្គនាយកប្រតិបត្តិ*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី 26 ខែ មីនា ឆ្នាំ 2024

2023

# ធនាគារ អ៊ូរី (ខេមបូឌា) ម.ក


អគារលេខ 398 មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកង1 ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ

www.wooribank.com.kh

info@wooribank.com.kh

(+855) 23 963 333 | 81 331 333

Woori Bank Cambodia